សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Économiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# របបសោធនក្នុងវិស័យឯកជនតាមរបបភាគទានជាភាតព្វកិច្ចនៅក្នុងប្រទេសកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **ឃួន មុន្នីនិត្យា**
លោក **តាំងនី ប៊ុនណារិទ្ធ**

ណែនាំដោយ
លោក **ហេង លីណា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ឃួន មុន្នីទិត្យា និង តាំងនី ប៊ុនណារិទ្ធ ជានិស្សិតថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២២ ២០២៣។

**យើងខ្ញុំសូមថ្លែងអំណរគុណ និងសូមសម្តែងនូវការគោរពយ៉ាងខ្ពង់ខ្ពស់ និងកត្តញ្ញូតាធម៌ដ៏ជ្រាលជ្រៅចំពោះ៖**

- **លោកអ្នកមានគុណទាំងពីរ** ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅតាំងតែពីតូចរហូតមកដល់សព្វថ្ងៃ និងព្យាយាមលើកទឹកចិត្ត និងផ្តល់ជាកម្លាំងចិត្តដល់យើងខ្ញុំ ទាំងការរស់នៅប្រចាំថ្ងៃក៏ដូចជាការសិក្សាផងដែរ ហើយថែមទាំងបានបណ្តុះគោលគំនិត យើងខ្ញុំក្នុងការរស់នៅប្រកប ដោយ សីលធម៌ និងជាពលរដ្ឋល្អដើម្បីតបស្នងដល់សង្គមជាតិ។ បន្ថែមលើសពីនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណដល់សមាជិកក្នុងក្រុមគ្រួសារ ដែលតែងតែជួយទូន្មាន និងដាស់តឿនបន្ថែមទៀត ឲ្យខិតខំសិក្សារៀនសូត្ររហូតទទួលបាននូវសមិទ្ធផលដ៏ល្អមួយនេះ។

- **ឯកឧត្តមសាកលវិទ្យាធិកា សាកលវិទ្យាធិការង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ** ដែលបានសហការគ្នាបង្កើតកម្មវិធីសិក្សានេះឡើង ហើយលោកព្យាយាមរិះរកគំនិត បទពិសោធន៍ និងវិធីសាស្ត្រផ្សេងៗទៀតដើម្បីចែករំលែក បង្ហាត់បង្រៀន និងជួយកែលំអរាល់ចំណុចខ្វះខាតរបស់យើងខ្ញុំ។ ជាពិសេសខ្ញុំសូមថ្លែងអំណរគុណដល់ **លោក សាស្ត្រាចារ្យ ហេង លីណា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការចែករំលែកនូវបទពិសោធន៍ ចំណេះដឹង និងបានដឹកនាំយើងខ្ញុំ ដើម្បីធ្វើការស្រាវជ្រាវ និងបានសម្រេចនូវគម្រោងបញ្ចប់ការសិក្សាជាស្ថាពរ ដោយមិនគិតពីការនឿយហត់ និងភាពមមាញឹករបស់លោកគ្រូផ្ទាល់។ អ្វីដែលពិសេសទៅទៀតនោះ គឺលោកគ្រូតែងតែផ្តល់នូវមតិរិះគន់ ដើម្បីស្ថាបនា កែសម្រួល ផ្តល់ជាឯកសារដែល ពាក់ព័ន្ធក្នុងការស្រាវជ្រាវ និងបានជម្រុញលើកទឹកចិត្តយើងខ្ញុំ តាំងពីចាប់ផ្តើមរហូតដល់បញ្ចប់ការងារបានជោគជ័យដោយក្តីសោមនស្សរីករាយ។

# អារម្ភកថា

បន្ទាប់ពីបានធ្វើការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសេដ្ឋកិច្ចអស់រយៈពេល៤ឆ្នាំកន្លងមក ដោយកិច្ចខិតខំប្រឹងប្រែងក្នុងការរៀនសូត្រដើម្បីទទួលបាននូវចំណេះដឹងពី លោក លោកស្រីសាស្ត្រាចារ្យនៅក្នុងសាកលវិទ្យាល័យ យើងខ្ញុំទាំងពីររូបត្រូវបានលើកទឹកចិត្ត និងទទួលបានការអនុញ្ញាតិពីសាកលវិទ្យាល័យដើម្បីសរសេរសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ "របបសោធនក្នុងវិស័យឯកជននៅក្នុងប្រទេសកម្ពុជា"។

សារណាបញ្ចប់ការសិក្សាមួយនេះផ្តោតសំខាន់ទៅលើនីតិវិធី និង លក្ខខណ្ឌដើម្បីទទួលបានតាវកាលិកពីប្រាក់សោធនក្នុងវិស័យឯកជន។ លើសពីនេះទៅទៀត សារណាមួយនេះអាចលេចចេញជារូបរាងឡើងដោយសារមានការជួយជ្រោមជ្រែងណែនាំតម្រង់ទិសពីសំណាក់ លោកគ្រូ សាស្ត្រាចារ្យ **ហេង លីណា** ដែលបានចំណាយពេលដ៏មានតម្លៃក្នុងការចែករំលែកចំណេះដឹង បទពិសោធន៍ និងដំបូន្មានល្អៗសម្រាប់ជាពុទ្ធិដល់យើងខ្ញុំ។ ក្នុងនាមយើងខ្ញុំជាអ្នករៀបចំសារណានេះក៏សង្ឃឹមថាឯកសារនេះនឹងអាចក្លាយជាប្រយោជន៍ និងជាវិភាគទានព្រមទាំងផ្តល់ចំណេះដឹងបន្ថែមសម្រាប់ជាគន្លឹះ និង ជំនួយស្មារតីដល់ប្អូនៗជំនាន់ក្រោយៗទៀតអាចធ្វើការសិក្សាស្រាវជ្រាវបន្តទៀតបាន។ តែទោះជាយ៉ាងណាក៏ដោយ ដោយសារតែចំណេះដឹង និង បទពិសោធន៍ក្នុងការស្រាវជ្រាវនៅមានកម្រិតសារណានេះច្បាស់ជាមាននៅចំណុចខ្វះខាត និង កំហុសជាក់ជាមិនខាន។ ហេតុនេះហើយមតិយោបល់ និង ការរិះគន់ដើម្បីកែលម្អនូវចំណុចខ្វះខាតទាំងអស់នេះ គឺពិតជាមានសារៈសំខាន់ណាស់ ហើយពួកយើងសូមអភ័យទោសទុកជាមុនរាល់កំហុសឆ្គងទាំងឡាយ និង សូមស្វាគមន៍នូវមតិយោបល់រិះគន់ដើម្បីស្តាបនាទាំងអស់ដោយសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........ ១

ក. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

ខ. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

គ. គោលបំណងនៃការស្រាវជ្រាវ ........ ២

ឃ. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣

ង. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

ច. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៤

ឆ. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤

**ជំពូកទី ១**

**របបសន្តិសុខសង្គមផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច**

**កថាខណ្ឌទី១. នីតិវិធី និងលក្ខណ្ឌនៃការចុះបញ្ជីផ្នែកប្រាក់សោធន** ........ ៥

ក. បញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ........ ៥

ខ. នីតិវិធី និងបែបបទនៃបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ........ ៦

គ. អត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ........ ៨

**កថាខណ្ឌទី២. នីតិវិធីក្នុងការបង់ភាគទាន** ........ ៩

ក. ការបង់ភាគទានដោយផ្ទាល់ ........ ១០

ខ. ការបង់ភាគទានដោយមិនផ្ទាល់ ........ ១០

គ. ការបង់ភាគទានប្រចាំខែ ........ ១២

ឃ. ការបង់ភាគទានប្រចាំឆ្នាំ ........ ១២

**កថាខណ្ឌទី៣. ស្ថាប័នទទួលបន្ទុកការងាររបបសន្តិសុខសង្គមផ្នែកប្រាក់សោធន** ........ ១២

ក. ក្រុមប្រឹក្សាជាតិគាំពារសង្គម ........ ១៤

ខ. និយ័តករសន្តិសុខសង្គម ........ ១៦

គ. ប្រតិបត្តិករសន្តិសុខសង្គម ........ ១៧

## ជំពូកទី២
## តាវកាលិកផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច

**កថាខណ្ឌទី១. ការផ្ដល់តាវកាលិកផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច** ២០
ក. សោធនជរាភាព ........ ២០
១. លក្ខខណ្ឌដើម្បីទទួលបានតាវកាលិកផ្នែកប្រាក់សោធនជរាភាពតាមរបបភាគទានជាកាតព្វកិច្ច .... ២០
២. ការគណនាចំនួនប្រាក់សោធនជរាភាព ........ ២១
ខ. សោធនទុព្វលភាព ........ ២៣
១. លក្ខខណ្ឌដើម្បីទទួលបានតាវកាលិកផ្នែកប្រាក់សោធនទុព្វលភាពតាមរបបភាគទានជាកាតព្វកិច្ច ២៣
២. ការគណនាចំនួនប្រាក់សោធនទុព្វលភាព ........ ២៤
គ. សោធនឧត្តរជីវី ........ ២៦
១. លក្ខខណ្ឌដើម្បីទទួលបានតាវកាលិកផ្នែកប្រាក់សោធនឧត្តរជីវីតាមរបបភាគទានជាកាតព្វកិច្ច ..... ២៦
២. សិទ្ធិវន្តនៃសោធនឧត្តរជីវី ........ ២៦
៣. ការផុតរលត់នៃសិទ្ធិវន្តនៃឧត្តរជីវី ........ ២៧
៤. ការគណនាចំនួនប្រាក់សោធនឧត្តរជីវី ........ ២៧
ឃ. វិភាជន៍បូជាសព ........ ២៨
១. ការផ្ដល់វិភាជន៍បូជាសព ........ ២៨
**សេចក្ដីសន្និដ្ឋាន** ........ ៣០
**អនុសាសន៍** ........ ៣២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ក. លំនាំបញ្ហានៃការស្រាវជ្រាវ

ជាទូទៅប្រជាជនកម្ពុជាមិនមានទំលាប់រៀបចំផែនការហិរញ្ញវត្ថុសម្រាប់ខ្លួនឯងនៅពេលអនាគតនោះទេ ដោយពឹងផ្អែកទៅលើកូនចៅទាំងស្រុង ដែលទម្លាប់នេះជម្រុញឲ្យប្រជាជនងាយនឹងធ្លាក់ចូលទៅក្នុងភាពក្រីក្រ នៅពេលចូលដល់វ័យចាស់ជរារហូតមកដល់ពេលនេះមានតែមន្ត្រីរាជការយោធិននិងនគរបាលបម្រើការក្នុងវិស័-យសាធារណៈចំនួនប្រមាណ៧ភាគរយនៃប្រជាជនសរុប ប៉ុណ្ណោះដែលទទួលបានប្រាក់សោធននៅពេលចូលនិវត្តន៍ដែលជាផ្នែកមួយនៃរបបសន្តិសុខសង្គម។

របបសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជាបង្កើតឡើងក្នុងគោលបំណងធានាឲ្យមានសមធម៌ និងសាមគ្គីធម៌សង្គមរួមទាំងលើកកំពស់សុខមាលភាព និងជីវភាពប្រជាពលរដ្ឋ[1]។ បន្ថែមពីនេះច្បាប់ស្តីពីរបបសន្តិសុខសង្គមក៏មានគោលដៅបែបបទក្នុងការអនុវត្ត និងប្រពន្ធ័គ្រប់គ្រងរបបសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជាដែលរួមមានផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកនិកម្មភាពការងារ[2]។

របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលវិស័យសាធារណៈត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលរដ្ឋ និងបុគ្គលនៃវិស័យសាធារណៈ មានកាតព្វកិច្ចរួមគ្នាក្នុងការបង់ភាគទាន[3]។ បន្ថែមពីនេះ ក្នុងពេលថ្មីៗនេះ ដោយមានការគិតគូរពីសុខទុក្ខរបស់កម្មករនិយោជិត រាជរដ្ឋាភិបាលបានសម្រេចដាក់ឱ្យដំណើរការនូវរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនដោយបេឡាជាតិសន្តិសុខសង្គម (**ប.ស.ស**) មានកាតព្វកិច្ចក្នុងការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកប្រាក់សោធននេះ ឱ្យមានប្រសិទ្ធភាព ព្រមទាំងមានកាតព្វកិច្ចប្រមូលភាគទានផ្នែកប្រាក់សោធន សម្រាប់ជាប្រយោជន៍ដល់កម្មករនិយោជិតនៅពេលចាស់ចាប់ពីអាយុ ៦០ឆ្នាំឡើង ឱ្យមានប្រាក់ចូលនិវត្តន៍។ ក្រៅពីនេះក៏មានស្ថាបន័មានសមត្ថកិច្ចដូចជា ក្រុមប្រឹក្សាជាតិគាំពារសង្គមដែលជាស្ថាប័នតាមដានសម្របសម្រួល និងតម្រង់ទិសរាល់ប្រត្តិបត្តិការសន្តិសុខសង្គម[4] និងមាននិយ័តករសន្តិសុខសង្គមដែលមានតួនាទីក្នុងការតាមដានស្ថានភាពហិរញ្ញវត្ថុរបស់ស្ថាប័ន **ប.ស.ស** ថែមទាំងបង្កើតយន្តការការពារសមាជិក និងផ្សះផ្សារពេលមានទំនាស់និងដើម្បីធានាថាការផ្តល់សេវាសន្តិសុខសង្គមប្រព្រឹត្តទៅដោយតម្លាភាព គណនេយ្យភាពនិង ចីរភាពហិរញ្ញវត្ថុ[5]។

[1] អនុលោមតាមមាត្រា១ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម។

[2] អនុលោមតាមមាត្រា២ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម។

[3] អនុលោមតាមមាត្រា៩ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម។

[4] អនុលោមតាមមាត្រា១០ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម។

[5] អនុលោមតាមមាត្រា១១ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម។

ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ ២០១៦-២០២៥ ផ្តោតលើសសរស្តម្ភចំនួនពីរគឺ ប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម[៦]។ ប្រព័ន្ធសន្តិសុខសង្គមផ្តល់ការគាំពារហានិភ័យលើផ្នែកសោធន ថែទាំសុខភាព ហានិភ័យការងារ និកម្មភាព និងពិការភាព ដល់ក្រុមប្រជាជននៃវិស័យសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រព័ន្ធ។ មិនតែប៉ុណ្ណោះប្រព័ន្ធសន្តិសុខសង្គមជាប្រព័ន្ធសម្រាប់គ្រប់គ្រងកម្មវិធីសន្តិសុខសង្គមដែលរៀបចំឡើងដើម្បីជួយដល់ប្រជាជនក្នុងការការពារពួកគាត់ពីការធ្លាក់ចុះភ្លាមៗនៃប្រាក់ចំណូលដែលបណ្តាលមកពីជំងឺ លំហែមាតុភាព គ្រោះថ្នាក់ការងារ និកម្មភាព ទុព្វលភាព ជរាភាព (ឬចូលនិវត្តន៍) និងមរណភាពអ្នកដែលរកចំណូលសម្រាប់គ្រួសារ។ របបសន្តិសុខសង្គមតម្រូវឲ្យសមាជិក និង/ឬ ភាគីពាក់ព័ន្ធបង់ភាគទានជាកាតព្វកិច្ចទៅតាមអត្រាជាក់លាក់ពេលគឺទាមទារឲ្យមានការចូលរួមពី សំណាក់និយោជិត និងនិយោជកទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន និងពីនិវត្តជនព្រមទាំងប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធផងដែរ។ តែទោះជាយ៉ាងណារាជរដ្ឋាភិបាលប្រកាន់ខ្ជាប់លើគោលការណ៍ផ្តល់ឧបត្ថម្ភធនជូនដល់ប្រជាជនដែលមិនមានលទ្ធភាពបង់ភាគទានពោលគឺប្រជាពលរដ្ឋក្រីក្រ និង ងាយរងគ្រោះ។

## ខ. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីជាភាពងាយស្រួលដល់ការអនុវត្តផ្នែកប្រាក់សោធននៅក្នុងវិស័យឯកជននៃព្រះរាជាណាចក្រកម្ពុជាឲ្យកាន់តែមានប្រសិទ្ធិភាព និងមានភាពរីកចម្រើនយើងអាចចោទជាសំណួរសួរថា៖

1. ដើម្បីទទួលបានប្រាក់សោធនក្នុងវិស័យឯកជន តើកម្មករនិយោជិតត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ?
2. តើកម្មករនិយោជិតដែលបានបំពេញលក្ខណ្ឌតាមលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមានអាចទទួលបានតាវកាលិកផ្នែកប្រាក់សោធនអ្វីខ្លះ?

## គ. គោលបំណងនៃការស្រាវជ្រាវ

កម្មវត្ថុនៃការស្រាវជ្រាវប្រធានបទខាងលើនេះគឺចង់ផ្តោតសំខាន់ទៅលើការផ្តល់ប្រាក់សោធនទៅឲ្យកម្មករនិយោជិតដែលបម្រើការងារនៅក្នុងវិស័យឯកជន ឬ សម្រាប់ឲ្យនិយោជក និងកម្មករនិយោជិតបានយល់ដឹងឲ្យកាន់តែច្បាស់លាស់អំពីអត្ថប្រយោជន៍នៃប្រាក់សោធន និង នីតិវិធីក្នុងការបង់ភាគទាន។ បន្ថែមពីនេះទៅទៀតប្រសិនបើកម្មករនិយោជិត និងនិយោជកបានយល់ដឹងអំពីរបបសោធនក្នុងវិស័យឯកជនកាន់តែច្បាស់លាស់ នោះពួកគេនឹងមិនត្រូវខាតបង់នូវអត្ថប្រយោជន៍ណាមួយបន្ទាប់ពីពួកគេចូលនិវត្តន៍ ពោលគឺនៅពេលដែលសាមីជនដល់អាយុចូលនិវត្តន៍ វ័យកាន់តែចាស់ សុខភាពចុះខ្សោយមិនអាចប្រកបរបរ ឬធ្វើការពេញលេញដើម្បីរកប្រាក់ចំណូលបាននោះសោធនិកនឹងប្រឈមហានិភ័យខ្ពស់ អាចធ្លាក់ចូលក្រោមបន្ទាត់ភាពក្រីក្រ

[៦]អនុលោមតាម ក្របខណ្ឌ័គោលនយោបាយជាតិគាំពារសង្គមឆ្នាំ ២០១៦ ដល់ ២០២៥។

ព្រោះនៅពេលដែលឈឺគ្មានថវិកាដើម្បីព្យាបាល ប៉ុន្តែនៅពេលដែលសោធនិកទទួលបាននូវផលប្រយោជន៍ពីប្រាក់សោធននេះ សាមីជននឹងទទួលបានប្រាក់ចូលនិវត្តន៍ រួមទាំងការថែទាំសុខភាពដោយឥតគិតថ្លៃផងដែរ។

## ឃ. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

មុនឆ្នាំ២០២២ ប្រទេសកម្ពុជាយើងពុំមានរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលិកនៃវិស័យឯកជនទេគឺមានតែវិស័យសាធារណៈប៉ុណ្ណោះ ប៉ុន្តែក្នុងឆ្នាំ២០២២ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានដាក់ឱ្យអនុវត្តរបបសន្តិសុខផ្នែកប្រាក់សោធន នៅថ្ងៃទី១ ខែកក្កដា ដែលស្របតាមមាត្រា ៣៩ នៃអនុក្រឹត្យចុះថ្ងៃទី ៤មីនា ឆ្នាំ២០២១ ដែលបានចែងពីកាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកសោធននិវត្តន៍សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារត្រូវកំណត់ដោយប្រកាសរួម រវាងក្រសួងការងារបណ្តុះបណ្តាល និងវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងការបង្កើតឲ្យមានរបបសោធននេះដែរក្នុងគោលបំណងសំខាន់ចង់បង្ហាញថាប្រសិនបើគ្មានរបបសន្តិសុខសង្គមផ្នែកប្រាក់សោធននេះទេ នៅពេលដែលដល់អាយុចូលនិវត្តន៍ វ័យកាន់តែចាស់ សុខភាពចុះខ្សោយមិនអាចប្រកបរបរ ឬធ្វើការពេញលេញដើម្បីរកប្រាក់ចំណូលបាននោះនឹងប្រឈមហានិភ័យខ្ពស់ អាចធ្លាក់ចូលក្រោមបន្ទាត់ភាពក្រីក្រព្រោះនៅពេលដែលឈឺគ្មានថវិកាដើម្បីព្យាបាល ប៉ុន្តែនៅពេលដែលបុគ្គលមានផ្នែកប្រាក់សោធននោះពួកគាត់នឹងទទួលបានប្រាក់ចូលនិវត្តន៍ រួមទាំងការថែទាំសុខភាពដោយឥតគិតថ្លៃផងដែរ។ ច្បាប់ស្តីពីរបបសន្តិសុខសង្គមគ្របដណ្តប់លើផ្នែកប្រាក់សោធនទាំងវិស័យឯកជននិងវិស័យសាធារណៈ ដែលរបបសោធននេះដែរក៏មានសម្រាប់បុគ្គលស្វ័យនិយោជន៍[7]ផងដែរ ដែលប្រាក់សោធនសម្រាប់បុគ្គលស្វ័យនិយោជន៍ត្រូវកំណត់ដោយអនុក្រឹត្យ[8]។

## ខ. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃការស្រាវប្រធានបទខាងលើនេះ គឺចង់ផ្តល់នូវការចែករំលែកចំណេះដឹងបន្ថែមទៅដល់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយជាពិសេសចំពោះសាធារណជនទូទៅ។ នៅក្នុងសារណាស្រាវជ្រាវមួយនេះ យើងផ្តោតសំខាន់បំផុតនោះទៅលើបុគ្គលដែលជាកម្មករនិយោជិត និង និយោជក ព្រោះសារណាស្រាវជ្រាវមួយនេះបានស្វែងយល់ពីលក្ខខណ្ឌ និងនីតិវិធីនៃការទាមទារ និងផ្តល់តាវកាលិកផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ចនៅក្នុងវិស័យឯកជន។ បន្ថែមពីនេះទៅទៀត ការស្រាវជ្រាវប្រធានបទនេះឡើងគឺដើម្បីចូលរួមដល់ការអភិវឌ្ឍន៍វិស័យការងារក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យកាន់តែមានភាពរីកចម្រើន។

---

[7] អនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមបុគ្គលស្វ័យនិយោជន៍ គឺសំដៅដល់ជនដែលប្រកបការងារ ឬមុខរបររកចំណូលផ្ទាល់ខ្លួនដោយមិនពាក់ព័ន្ធនឹងប្រាក់ឈ្នួល ឬប្រាក់បៀវត្សដែលផ្តល់ដោយនិយោជន ឬរដ្ឋតាមកិច្ចសន្យាការងារ ហើយក៏មិនមានប្រើប្រាស់កម្មករនិយោជិតនៅក្នុងសកម្មភាពការងារ ឬមុខរបររបស់ខ្លួន។

[8] អនុលោមតាមមាត្រា៥ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម ជំពូកពីរគោលការណ៍ទូទៅនៃរបបសន្តិសុខសង្គម។

## ច. វិធីសាស្ត្រនៃការស្រាវជ្រាវ

ជាការពិតណាស់ប្រធានបទខាងលើយើងខ្ញុំបានខិតខំសិក្សាស្រាវជ្រាវ ដើម្បីស្វែងរក និងប្រមូលឯកសារច្បាប់ក្នុងនោះច្បាប់ស្ដីពីរបបសន្តិសុខសង្គមជាទិន្នន័យយ៉ាងសំខាន់ក្នុងការស្រាវជ្រាវសារណាមួយនេះ និងរួមទាំងច្បាប់ និងលិខិតបទដ្ឋានដែលពាក់ព័ន្ធមួយចំនួនបន្ថែមទៀត ព្រមទាំងឯកសារដែលស្វែងរកតាមប្រព័ន្ធអ៊ីនធឺណិត តាមរយៈគេហទំព័រផ្លូវការរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ជាពិសេសនោះការផ្តល់ការណែនាំបន្ថែមពីសាស្ត្រាចារ្យណែនាំដើម្បីចងក្រងសរសេរនូវសារណាមួយនេះ។

## ឆ. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដោយផ្អែកតាមរយៈលទ្ធផលនៃការចងក្រងសរសេរសារណានេះយើងបែងចែករចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះជា ២(ពីរ) ជំពូកធំៗដើម្បីឆ្លើយតបនឹងចំណោទបញ្ហាគតិយុត្តខាងលើ៖

- **ជំពូកទី១ របបសន្តិសុខសង្គមផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច**
- **ជំពូកទី២ ភាពកាលិកផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច**

# ជំពូកទី១

# របបសន្តិសុខសង្គមផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច

# ជំពូកទី ១

# របបសន្តិសុខសង្គមផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច

## កថាខណ្ឌទី១. នីតិវិធី និងលក្ខណ្ឌនៃការចុះបញ្ជីផ្នែកប្រាក់សោធន

ដើម្បីឲ្យយល់ដឹងកាន់តែលម្អិតពីនីតិវិធី និងលក្ខណ្ឌនៃការចុះបញ្ជីផ្នែកប្រាក់សោធនរបស់ក្រុមហ៊ុនស្ថិតក្រោមច្បាប់ស្តីពីការងារយើងគប្បីធ្វើការសិក្សាពី (ក.) បញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត (ខ.) នីតិវិធី និងបែបបទនៃបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត រួមទាំង (គ.) អត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត

### ក. បញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត

ជាទូទៅការចុះបញ្ជីជាកាតព្វកិច្ចនិយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលប្រើប្រាស់កម្ម-ករនិយោជិតចាប់ពី ១(មួយ)នាក់ឡើង ត្រូវមានកាតព្វកិច្ចចុះបញ្ជីក្នុង បេឡាជាតិសន្តិសុខសង្គម (**ប.ស.ស**) ផ្នែកប្រាក់សោធនក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃបន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន លើកលែងតែសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងផ្នែកហានិភ័យការងាររួចហើយ[៩]។ ទម្រង់ និងបែបបទនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវមានកាតព្វកិច្ចចុះបញ្ជីកម្មករនិយោជិតក្នុង **ប.ស.ស** យ៉ាងយូរ៣(បី)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចូលបម្រើការងារ លើកលែងតែកម្មករនិយោជិតដែលបានចុះបញ្ជីរួចហើយ។ ការចុះបញ្ជីកម្មករនិយោជិតត្រូវអនុលោមតាមទិន្នន័យក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនសម្រាប់កម្មករនិយោជិតបរទេស[១០]។

**ប.ស.ស.** ត្រូវចេញប័ណ្ណសមាជិកដល់កម្មករនិយោជិតទាំងអស់ដែលបានចុះបញ្ជីដោយអនុលោមតាមទិន្នន័យក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ លិខិតឆ្លងដែនសម្រាប់តែកម្មករនិយោជិតបរទេសប៉ុណ្ណោះ។

ប័ណ្ណសមាជិក **ប.ស.ស.** ត្រូវផ្តល់ជូនដោយឥតគិតថ្លៃ។ ក្នុងករណីបាត់ ឬខូចខាត សមាជិក **ប.ស.ស.** ត្រូវជូនដំណឹងជាបន្ទាន់ទៅនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ឬ **ប.ស.ស.** និង ស្នើសុំប័ណ្ណទុតិយតា (**ប.ស.ស.**) ត្រូវកំណត់ដោយប្រកាសយ៉ាងយូរ៣០(សាមសិប)ថ្ងៃ[១១]។

---

[៩]អនុលោមតាម មាត្រា៥ នៃអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

[១០]អនុលោមតាមមាត្រា៦ នៃអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

[១១]អនុលោមតាមមាត្រា៧ នៃអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

និយោជក[12] ឬ ម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចមកចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត[13]របស់ខ្លួនក្នុង ប.ស.ស.។

រយៈពេលកំណត់នៃការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន មានដូចតទៅ៖

- ចំពោះសហគ្រាស គ្រឹះស្ថាន ដែលកំពុងដំណើរការ ត្រូវមកចុះបញ្ជិកាក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប)ថ្ងៃ បន្ទាប់ពីប្រកាសលេខ ៤៤៨ ក.ប/ប្រ.ក.ប.ស.ស. ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និង កម្មករនិយោជិតក្នុង ប.ស.ស. ចូលជាធរមាន។
- ចំពោះសហគ្រាស គ្រឹះស្ថាន ដែលបើកដំណើរការថ្មី ក្រោយកាលបរិច្ឆេទចូលជាធរមាននៃប្រកាសលេខ ៤៤៨ ក.ប/ប្រ.ក.ប.ស.ស. ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុង **ប.ស.ស** ត្រូវមកចុះបញ្ជិកាក្នុងរយៈពេលយ៉ាងយូរ ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមបើកសហគ្រាសគ្រឹះស្ថានជាស្ថាពរ។[14]

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះកម្មករនិយោជិតនៅក្នុងសហគ្រាសរបស់ខ្លួនមក **ប.ស.ស.** ដើម្បីចុះបញ្ជិកាក្នុង **ប.ស.ស.**។ ការភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះកម្មករនិយោជិតត្រូវធ្វើក្នុងពេលដំណាលគ្នា និង ទម្រង់បញ្ជិកាសហគ្រាស គ្រឹះស្ថាន។

### ខ. នីតិវិធី និងបែបបទនៃបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត

ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ត្រូវធ្វើតាមទម្រង់ "បញ្ជិកាសហគ្រាស គ្រឹះស្ថាន" ឬហៅថាទម្រង់ **១.០១** ដែលមានចែងក្នុងឧបសម្ព័ន្ធ១ នៃប្រកាសលេខ ៤៤៨ ក.ប/ប្រ.ក.ប.ស.ស. ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុង **ប.ស.ស.**។ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវភ្ជាប់មកជាមួយទម្រង់ **១.០១** នូវវិញ្ញាបនបត្របញ្ជិកាពាណិជ្ជកម្ម ដែលចេញដោយក្រសួងពាណិជ្ជកម្ម ឬលិខិតតូបករណ៍គតិយុត្តសមមូលដទៃទៀត។

[12] អនុលោមតាម ច្បាប់ស្តីពីរបបសន្តិសុខសង្គម និយោជក សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលជាសាធារណៈឬឯកជន ដែលបើកម្មករនិយោជិតម្នាក់ ឬច្រើននាក់ ទោះជាកម្មករនិយោជិតជាប់លាប់ ឬម្តងម្កាល។

[13] អនុលោមតាមអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ កម្មករនិយោជិត សំដៅដល់ជនគ្រប់ភេទនិងគ្រប់សញ្ជាតិដែលបានចុះកិច្ចសន្យាយកកំរៃជាសាធារណៈ ឬឯកជន។

[14] ប្រកា៥ នៃប្រកាសលេខ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ វិច្ឆិកា ២០១៧ ស្តីពីបញ្ជិកាសហគ្រាសគ្រឹះស្ថាននិងកម្មករនយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។

ទម្រង់**១.០១** មានចំណុចសំខាន់ៗចំនួន ៦ មានដូចជាៈ ១. ឈ្មោះសហគ្រាស គ្រឹះស្ថាន ២. អាស័យដ្ឋាន ទីស្នាក់ការកណ្តាល ៣. អាស័យដ្ឋាននៃកន្លែងធ្វើការ ៤. លេខបញ្ជីពាណិជ្ជកម្ម ៥. ឈ្មោះនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ៦. ឈ្មោះអ្នកគ្រប់គ្រងឬ អ្នកតំណាងនិយោជក។

និយោជក ឬម្ចាស់សហគ្រាស ត្រូវមានកាតព្វកិច្ចជូនដំណឹងមក **ប.ស.ស** ក្នុងរយៈពេលយ៉ាងយូរ ៣០ ថ្ងៃបន្ទាប់ពីមានការព្យួរ បិទ ឬផ្អាកសកម្មភាពអាជីវកម្ម ការប្តូរនិយោជក ឬ ម្ចាស់សហគ្រាស ឬ អ្នកតំណាងអាស័យដ្ឋាន ឬនាមករណ៍សហគ្រាស។[15]

ការចុះបញ្ជិកាកម្មករនិយោជិតត្រូវធ្វើតាមនីតិវិធី និងបែបបទដូចខាងក្រោមៈ

**១. ចំពោះសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិកានៅ ប.ស.ស.**

និតិវិធី និងបែបបទនៃការចុះបញ្ជិកាកម្មករនិយោជិតមកក្នុងបេឡាជាតិសន្តិសុខសង្គមត្រូវធ្វើតាមទម្រង់សលាកប័ត្រព័ត៌មាន សម្រាប់ផ្តល់អត្តសញ្ញាណសមាជិក **ប.ស.ស.** ឬ ហៅថាទម្រង់ **១.០២**"[16]។ ទម្រង់ **១.០២** មានចំណុចគោលសំខាន់ៗចំនួន ៣ ដែលត្រូវបំពេញគឺ ព័ត៌មានផ្ទាល់ខ្លួន ព័ត៌មានការងារ និងព័ត៌មានគ្រួសារ ចំពោះគម្រូអាចមើលបានក្នុងឧបសម្ព័ន្ធ។

- **ក១**. ការចុះបញ្ជិកា កម្មករនិយោជិតត្រូវធ្វើតាមទម្រង់ សាលាកប័ត្រព័ត៌មានទម្រង់ សម្រាប់ផ្តល់អត្តសញ្ញាណសមាជិក **ប.ស.ស.**
- **ក២. ប.ស.ស.** នឹងផ្តល់កាលបរិច្ឆេទសម្រាប់ការចុះកំណត់អត្តសញ្ញាណសមាជិក **ប.ស.ស** នៅតាមមូលដ្ឋានសហគ្រាស គ្រឹះស្ថាន។
- **ក៣**.និយោជក ឬម្ចាស់សហគ្រាសគ្រឹះស្ថានត្រូវមានកាតព្វកិច្ចបំពេញព័ត៌មានកម្មករនិយោជិតឱ្យបានត្រឹមត្រូវ នៅក្នុងសលាកប័ត្រព័ត៌មាន ដោយភ្ជាប់មកជាមួយនូវ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដោយឡែក ចំពោះកម្មករនិយោជិតបរទេសត្រូវមានលិខិតឆ្លងដែន។
- **ក៤**.ប.ស.ស. នឹងផ្តល់លេខអត្តសញ្ញាណ និងប័ណ្ណសមាជិក **ប.ស.ស.** ជូនទៅកម្មករនិយោជិតតាមរយៈនិយោជក ឬតំណាងដោយឥតគិតថ្លៃ[17]។

[15]ប្រការ៦ នៃប្រកាសលេខ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ វិច្ឆិកា ២០១៧ស្តីពីបញ្ជិកាសហគ្រាសគ្រឹះស្ថាននិងកម្មករនយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។

[16]ប្រការ៨ នៃប្រកាស លេខ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ វិច្ឆិកា ២០១៧ស្តីពីបញ្ជិកាសហគ្រាសគ្រឹះស្ថាននិងកម្មករនយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។

[17]ប្រការ១០ នៃប្រកាស លេខ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ វិច្ឆិកា ២០១៧ ស្តីពីបញ្ជិកាសហគ្រាសគ្រឹះស្ថាននិងកម្មករនយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**២. ចំពោះសហគ្រាស គ្រឹះស្ថាន ដែលចុះបញ្ជិកាថ្មី**

**ខ១**.ការចុះបញ្ជិកាកម្មករនិយោជិតត្រូវធ្វើក្នុងពេលដំណាលគ្នានឹងការចុះបញ្ជិកាសហគ្រាសគ្រឹះស្ថាន។

**ខ២**.សហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតចាប់ពី ១០០នាក់ឡើង **ប.ស.ស** និងផ្តល់កាលបរិច្ឆេទចុះទៅកំណត់អត្តសញ្ញាណកម្មករនិយោជិត។ និយោជកត្រូវអនុវត្តកាតព្វកិច្ចដូចមានចែងនៅក្នុងចំណុច ក៣ ខាងលើ។

**ខ៣**.សហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតក្រោម ៥០នាក់ **ប.ស.ស** នឹងផ្តល់កាលបរិច្ឆេទ និងអញ្ជើញនិយោជក ឬតំណាង និងកម្មករនិយោជិតមកកំណត់អត្តសញ្ញាណកម្មករនិយោជិតនៅ **ប.ស.ស** ដោយភ្ជាប់មកជាមួយនូវឯកសារដូចមានចែងក្នុងចំណុច **ក៣** ខាងលើ បន្ទាប់ពីបានបំពេញសលាកប័ត្រព័ត៌មានរួច។

**ខ៤**.ប.ស.ស. នឹងផ្តល់លេខអត្តសញ្ញាណ និង ប័ណ្ណសមាជិក ប.ស.ស. ជូនកម្មករនិយោជិតតាមរយៈនិយោជក ឬតំណាង។

**គ. អត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត**

**ប.ស.ស** ត្រូវផ្តល់លេខអត្តសញ្ញាណសម្រាប់សហគ្រាស គ្រឹះស្ថាននីមួយៗ បន្ទាប់ពីទទួលបានទម្រង់ "បញ្ជិកាសហគ្រាស គ្រឹះស្ថាន"។ **ប.ស.ស.** ត្រូវផ្តល់ "វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន" ជូនទៅសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិការួច។[18]

និយោជកត្រូវដាក់តាំង " វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន" នៅនឹងការិយាល័យបើកប្រាក់ឈ្នួលរបស់សហគ្រាស គ្រឹះស្ថាន។ បន្ទាប់ពីទទួលបានទម្រង់បញ្ជិកាកម្មករនិយោជិត **ប.ស.ស.** ត្រូវផ្តល់លេខអត្តសញ្ញាណ និងចេញប័ណ្ណ សមាជិក **ប.ស.ស.** ជូនកម្មករនិយោជិតម្នាក់ៗដោយឥតគិតថ្លៃ។ ប័ណ្ណសមាជិក **ប.ស.ស.** ត្រូវប្រគល់ជូនទៅកម្មករនិយោជិតតាមរយៈនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន។ ក្នុងករណីដែល "ប័ណ្ណសមាជិក **ប.ស.ស.**" ខូច ឬបាត់បង់ សាមីជនដែលជាម្ចាស់ប័ណ្ណត្រូវជូនដំណឹងជាបន្ទាន់ទៅនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន និងត្រូវស្នើសុំទុតិយតាក្នុងរយៈពេលយ៉ាងយូរ ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងខាងលើ។ ការផ្តល់ប័ណ្ណទុតិយតា (គម្រូប័ណ្ណទុតិយតាមានបង្ហាញក្នុងឧបសម្ព័ន្ធ) តម្រូវឱ្យសាមីជនបង់ប្រាក់ចំនួន ២,០០០(ពីរពាន់)រៀល ជូនទៅ **ប.ស.ស.**។[19]

---

[18] ប្រការ៩ នៃប្រកាស លេខ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ វិច្ឆិកា ២០១៧ ស្តីពីបញ្ជិកាសហគ្រាសគ្រឹះស្ថាននិងកម្មករនយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។

[19]ប្រការ១០ នៃប្រកាស លេខ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ វិច្ឆិកា ២០១៧ ស្តីពីបញ្ជិកាសហគ្រាសគ្រឹះស្ថាននិងកម្មករនយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។

### ១. របាយការណ៍ចំនួនកម្មករនិយោជិត

រៀងរាល់ខែ និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវផ្តល់របាយការណ៍អំពីចំនួនកម្មករនិយោជិត ទៅ **ប.ស.ស.** យ៉ាងយូរបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់[20]។ របាយការណ៍អំពីចំនួនកម្មករនិយោជិត ត្រូវបញ្ជាក់អំពីចំនួនកម្មករនិយោជិតទាំងអស់ដែលមាននៅក្នុងខែត្រូវរាយការណ៍។ របាយការណ៍អំពីចំនួនកម្មករនិយោជិតដែលត្រូវផ្តល់ជូន **ប.ស.ស.** អាចតាម "ទម្រង់ក្រដាស" ឬ" ទម្រង់អេឡិចត្រូនិច" ដោយមានភ្ជាប់លិខិតបញ្ជូនចុះហត្ថលេខាដោយនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន[21]។ ចំណុចសំខាន់ៗដែលត្រូវបំពេញក្នុងរបាយការណ៍កម្មករនិយោជិតមានដូចជា ឈ្មោះសហគ្រាសគ្រឹះស្ថាន លេខអត្តសញ្ញាណសហគ្រាស និង ឈ្មោះសហគ្រាសជាអក្សរឡាតាំង និងចំណុចសំខាន់ៗមួយចំនួនទៀតដែលអាចមើលតាមគម្រូក្នុងឧបសម្ព័ន្ធ។

ចំពោះកម្មករនិយោជិត ដែលទើបចូលបម្រើការងារថ្មី ហើយមិនទាន់មានលេខអត្តសញ្ញាណ **ប.ស.ស** (លេខ១៥ខ្ទង់) និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវមានកាតព្វកិច្ចបញ្ជូនកម្មករនិយោជិតថ្មីនេះ មកចុះបញ្ជិកានៅ ប.ស.ស. តាមទម្រង់សលាកប័ត្រព័ត៌មានយ៉ាងយូររយៈពេល ០៣(បី) ថ្ងៃ បន្ទាប់ពីអនុញ្ញាតឱ្យចូលធ្វើការ ដើម្បីទទួលបានលេខអត្តសញ្ញាណ **ប.ស.ស** (លេខ១៥ខ្ទង់)។

## កថាខណ្ឌទី២. នីតិវិធីក្នុងការបង់ភាគទាន

បន្ទាប់ពីការចុះបញ្ជី កម្មករនិយោជិតជាសមាជិក **ប.ស.ស** រួចមកកម្មករនិយោជិតត្រូវជាប់កាតព្វកិច្ចមួយផ្សេងទៀតគឺការបង់ភាគទាន។ ភាគទានផ្នែកប្រាក់សោធនវិញ គឺសំដៅលើភាគទានដែលសមាជិក **ប.ស.ស** ត្រូវបង់ចូលមក **ប.ស.ស** ជារៀងរាល់ខែ ដោយការប្រមូលភាគទានផ្នែកប្រាក់សោធននេះ ធ្វើឡើងក្នុងគោលបំណងទុកសម្រាប់ចំណាយក្នុងការផ្តល់តាវកាលិកដល់សមាជិក **ប.ស.ស** និងចំណាយលើប្រតិបត្តិការនៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន នៅពេលសមាជិក **ប.ស.ស** ដល់អាយុ ៦០ឆ្នាំឡើងទៅ ឬករណីជរាភាព ឬករណីមានជំងឺមិនអាចធ្វើការបានមុនអាយុ ៦០ឆ្នាំ ឬករណីមរណភាពជាអាទ៍។ តាវកាលិកផ្នែកប្រាក់សោធនមានដូចជា សោធនជរាភាព វិភាជន៍ជរាភាព សោធនទុព្វលភាព សោធនចំពោះអ្នកនៅក្នុងបន្ទុក និងវិភាជន៍អ្នកនៅក្នុងបន្ទុក។ ជាមួយគ្នានេះ ភាគទានផ្នែកប្រាក់សោធន គឺជាកាតព្វកិច្ចរួមរបស់និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត[22]។ ភាគទាននេះ ត្រូវបង់ជាប្រចាំខែកំណត់ជាអត្រា ៤%(បួនភាគរយ) នៃ

[20] អនុលោមតាមមាត្រា១០ នៃអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

[21] ប្រការ១១ នៃប្រកាស លេខ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ វិច្ឆិកា ២០១៧ ស្តីពីបញ្ជិកាសហគ្រាសគ្រឹះស្ថាននិងកម្មករនយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។

[22] អនុលោមតាម មាត្រា៨ នៃអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

ប្រាក់ឈ្នួលជាប់ភាគទានរបស់កម្មករនិយោជិតម្នាក់ៗក្នុងអំឡុង ៥ឆ្នាំដំបូងដោយនិយោជកមានកាតព្វកិច្ចទទួលបន្ទុក ២% ហើយនិយោជិតមានកាតព្វកិច្ចទទួលបន្ទុក ២%(ពីរភាគរយ)[23]។ សម្រាប់ការបង់ភាគទានផ្នែកប្រាក់សោធននាទ៥ឆ្នាំដំបូងគឺតម្រូវតែ៤ភាគរយ ពីខាងនិយោជក និងកម្មករនិយោជិតប៉ុណ្ណោះប៉ុន្តែតម្លៃនៃការបង់នេះ នឹងកើនឡើងជាបន្តបន្ទាប់នាឆ្នាំទៅមុខទៀត សម្រាប់រយៈពេល ៥ឆ្នាំបន្ទាប់ កម្មករនិយោជិត និងនិយោជកត្រូវបង់ ៨ភាគរយ ហើយ១០ឆ្នាំបន្ទាប់ទៀតត្រូវបង់ ១០,៧៥ភាគរយ រហូតដល់១០ឆ្នាំបន្តបន្ទាប់ទៀតត្រូវបង់បូក ២,៧៥ភាគរយសម្រាប់ការបង់វិភាគទានកាតព្វកិច្ចរបស់និយោជន និងកម្មករនិយោជិត។




និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវបង់ភាគទានចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី១៥ និងផ្ញើ ឬដាក់ឯកសារមក **ប.ស.ស** យ៉ាងយូរត្រឹមថ្ងៃទី២០នៃខែនីមួយៗ និងអាចបង់តាមពីរបៀប:

**ក. ការបង់ភាគទានដោយផ្ទាល់**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានអាចស្វែងរកការបង់ភាគទានបានតាមនៅទីស្នាក់ការកណ្តាល **ប.ស.ស.** ឬតាមសាខា **ប.ស.ស.** រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

សម្រាប់ការបង់ភាគទានមក **ប.ស.ស** ត្រូវមានឯកសារដូចជា៖

- លិខិតប្រកាសបង់ភាគទាន (ក្រដាសពណ៌លឿង)
- របាយការណ៍ចំនួនកម្មករនិយោជិត (E-Form)
- បង្កាន់ដៃបង់ភាគទាននៅធនាគារ (Bank Slip)
- លិខិតបញ្ជាក់ចំនួនកម្មករនិយោជិត (Form-B)
- តារាងបើកប្រាក់ឈ្នួលប្រចាំខែ។

**ខ. ការបង់ភាគទានដោយមិនផ្ទាល់**

ក្រៅពីការបង់ភាគទាននៅទីស្នាក់ការផ្ទាល់និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថានអាចបង់ភាគទានបានតាមរយៈប្រព័ន្ធធនាគារដែលមាន ៖

[23] អនុលោមតាម មាត្រា៨ នៃអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

១. ធនាគារ អេស៊ីលីដា(ACLEDA BANK PLC.) គណនី 0001 10465889 18។

២. ធនាគារ កាណាឌីយ៉ា(CANADIA BANK PLC.) គណនី 0010 0043 48333។

៣. ធនាគារ ឯកទេសវីងWING(CAMBODIA) គណនី 9119។

៤. ធនាគារ វឌ្ឍនៈអាស៊ីចំកាត់ ABA BANK គណនី 001256087។

៥. ក្រុមហ៊ុន លី ហួរ ផេ ប្រ៉ូ ភីអិលស៊ី(លី ហ៊ួរ វេរលុយ)LY HOUR PAY PRO PLC. គណនី22002

៦. ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់(JTRUST ROYAL BANK LTD.) គណនី 4364180។

៧. ធនាគារ វឌ្ឍនៈ VATTANAC BANK គណនី 0500 15000003 15។

៨. ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក (PHNOM PENH COMMERCIAL BANK PLC "PPCBANK")
គណនី 1110 0001 23724។

គណនី 1110 0001 23724។

៩. ធានាគារ ពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា (FOREIGN TRADE BANK OF CAMBODIA "FTB") លេខគណនី 1000 12245957។

១០. ធនាគារ អេស ប៊ី អាយ លីហួរ ម.ក (SBI LY HOUR BANK PLC.) គណនីលេខ 000114898

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានដែលបានដាក់ឯកសារបង់ភាគទានតាម E-mail មិនអាចមកយកវិក្កយបត្រច្បាប់ដើមបានទេ គឺវិក្កយបត្រត្រូវស្កេនជូនតាម E-mail ត្រឡប់ទៅវិញ។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានអាចទទួលបានព័ត៌មានពី ប.ស.ស. តាមរយៈទូរស័ព្ទមកមជ្ឈមណ្ឌលព័ត៌មាន ប.ស.ស. (Call Center) លេខ ១២៨៦ គេហទំព័រ ប.ស.ស (www.nssf.gov.kh)បណ្តាញសង្គម Facebook Telegram និង Youtube "បេឡាជាតិសន្តិសុខសង្គម"។

- **សមាជិកប.ស.ស អាចដឹងពីចំនួនភាគទានបានតាមវិធីដូចជា៖**

– ទូរស័ព្ទមកមជ្ឈមណ្ឌលព័ត៌មាននៃ ប.ស.ស. ទំនាក់ទំនងមកលេខ hotline ១២៨៦ឬ ផ្ញើរសារ ចូលតេលេក្រាម (Telegram) ឬ បណ្តាញសង្គមហ្វេសបុក (Facebook) page "បេឡាជាតិសន្តិសុខសង្គម"

– ប្រើប្រាស់កម្មវិធីទូរស័ព្ទដែលមានឈ្មោះ "**NSSF Member App**"ដែលអាចទាញយកបានតាម Play store និង App store។

- **លក្ខណ្ឌពិសេសមួយចំនួនក្នុងការបង់ភាគទាន**

– ករណីដែលកម្មករនិយោជិតទើបចូលបម្រើការងារថ្មីមិនទាន់មានប័ណ្ណសមាជិក ប.ស.ស. ត្រូវបង់ភាគទានមក ប.ស.ស ដោយប្រើប្រាស់ ID 0 ជបណ្តោះអាសន្ន[24]។

[24] គេហទំព័របេឡាជាតិសន្តិសុខសង្គម។

- បើសហគ្រាសបើកប្រាក់ឈ្នួលជារូបិយប័ណ្ណបរទេសប្រាក់ឈ្នួលប្រចាំខែត្រូវគិតជាប្រាក់រៀលតាមអត្រាប្តូរប្រាក់មធ្យមប្រចាំខែដោយផ្អែកតាមអត្រាប្តូរប្រាក់ធនាគារជាតិនៃកម្ពុជា ដែលជូនដំណឹងដោយ **ប.ស.ស**
- បើសិនជាសហគ្រាស គ្រឹះស្ថាន បង់ភាគទាន ឬដាក់ឯកសារយឺតតាមកាលកំណត់អាចនឹងត្រូវពិន័យអន្តរការណ៍ពី ១០ដង ទៅ ៣០ដងនៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ និងត្រូវបង់បន្ថែមនូវការប្រាក់ប្រចាំខែតាមអត្រា ១,៥ភាគរយ។

ការបង់ភាគទានមាន២យ៉ាងគឺ (គ)ការបង់ភាគទានប្រចាំខែ និងការបង់ភាគទានប្រចាំឆ្នាំ(ឃ)។

**គ. ការបង់ភាគទានប្រចាំខែ**

ការបង់ភាគទានអាចបង់បានប្រចាំខែ និងប្រចាំឆ្នាំក្នុងករណីការបង់ភាគទានផ្នែកប្រាក់សោធនដែលធ្វើជាប្រចាំខែ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ត្រូវមានកាតព្វកិច្ចប្រមូល និងបង់ភាគទានផ្នែកប្រាក់សោធននៃចំណែករបស់ខ្លួន និងជាចំណែករបស់កម្មករនិយោជិត មកក្នុងគណនី **ប.ស.ស** នៃធនាគារដៃគូ យ៉ាងយូរត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់[25]។

**ឃ. ការបង់ភាគទានប្រចាំឆ្នាំ**

ក្នុងករណីនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងឡាយណាដែលមានបំណងបង់ភាគទាននេះប្រចាំឆ្នាំ ត្រូវមានកាតព្វកិច្ចផ្តល់របាយការណ៍អំពីចំនួនកម្មករនិយោជិតទាំងអស់មក **ប.ស.ស** យ៉ាងយ៉ូរត្រឹមថ្ងៃទី២០(ម្ភៃ) នៃខែបន្ទាប់ តាមកាលកំណត់។ ក្នុងករណីមិនមានចលនាចេញ ចូលបុគ្គលិករបស់ខ្លួន និយោជកត្រូវរាយការណ៍រៀងរាល់១២(ដប់ពីរ) ខែម្តង ប៉ុន្តែក្នុងករណីមានចលនាចេញចូល បុគ្គលិករបស់ខ្លួននិយោជកត្រូវរាយការណ៍យ៉ាងយ៉ូរ១៥(ដប់ប្រាំ)ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៃបម្រែបម្រួល។ អត្រាភាគទានផ្នែកប្រាក់សោធនត្រូវដំឡើងតាមវិធីសាស្ត្របុព្វលាភជណ្តើរ[26]ឬ វិធីសាស្ត្រមួយសមរម្យតាមការកំណត់របស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។[27]

## កថាខណ្ឌទី៣. ស្ថាប័នទទួលបន្ទុកការងាររបបសន្តិសុខសង្គមផ្នែកប្រាក់សោធន

រាជរដ្ឋាភិបាលបានសម្រេចដាក់ឱ្យដំណើរការនូវរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន កាលពីខែ តុលា ឆ្នាំ ២០២២ ដោយបេឡាជាតិសន្តិសុខសង្គម (**ប.ស.ស**) មានកាតព្វកិច្ចក្នុងការគ្រប់គ្រង និងចាត់ចែងរបប

[25] អនុលោមតាមមាត្រា៨ នៃច្បាប់ស្តីពីបេឡាជាតិសន្តិសុខសង្គម។

[26] វិធីសាស្ត្របុព្វលាភជណ្តើរ សំដៅដល់វិធីកំណត់កំណើនអត្រាភាគទាន ផ្នែកប្រាក់សោធនក្នុងរយៈពេលជាកំណត់មួយ។

[27] អនុលោមតាម មាត្រា១៩ នៃច្បាប់ស្តីពីបេឡាជាតិសន្តិសុខសង្គម។

សន្តិសុខសង្គមផ្នែកប្រាក់សោធននេះព្រមទាំងមានកាតព្វកិច្ចប្រមូលភាគទានផ្នែកប្រាក់សោធន សម្រាប់ជាប្រយោជន៍ដល់កម្មករនិយោជិតនៅពេលចាស់ទៅ ចាប់ពីអាយុ ៦០ឆ្នាំឡើង ឱ្យមានប្រាក់ចូលនិវត្តន៍។

ប្រព័ន្ធសោធននៅកម្ពុជា បានចាប់ផ្តើមឡើងដោយមានលក្ខណៈដាច់ដោយឡែកពីគ្នាទៅតាមប្រភេទនៃសមាជិកគោលដៅ។ តាមរយៈព្រះរាជក្រឹត្យស្តីពីរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងព្រះរាជក្រឹត្យស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល រាជរដ្ឋាភិបាលបានបង្កើតគ្រឹះស្ថានសាធារណៈចំនួនពីរគឺ បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (**ប.ជ.ស**) និងបេឡាជាតិអតីតយុទ្ធជន (**ប.ជ.អ**) ដែលបច្ចុប្បន្នស្ថិតក្រោមការគ្រប់គ្រង របស់ ប្រព័ន្ធជំនួយសង្គម ដើម្បីគ្រប់គ្រង និងបើកផ្តល់ប្រាក់សោធនសម្រាប់មន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ដែលជាមន្ត្រីនគរបាលជាតិ និងយោធិន។ យោងតាមបទប្បញ្ញត្តិនេះ **ប.ជ.ស** និង **ប.ជ.អ** ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការបង្កើតឱ្យមានរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនថ្មីនេះ គឺ ជាការរួមចំណែកយ៉ាងសំខាន់ក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីកាត់បន្ថយភាពក្រីក្រ ជាពិសេសកាត់បន្ថយនូវគម្លាតប្រាក់ចំណូលរវាងអ្នកមាន និងអ្នកក្រដើម្បីធានាឱ្យមានស្ថិរភាព និងភាពសុខដុមរមនានៅក្នុងសង្គម។

ស្ថាប័នប្រតិបត្តិកររបបសោធនបច្ចុប្បន្នគឺ **ប.ជ.ស ប.ជ.អ** និង **ប.ស.ស** ដែលមានមុខងារ និងភារកិច្ចស្ទើរតែដូចគ្នាទាំងស្រុង ដែលមានភាពខុសគ្នាតែលើសមាជិកគោលដៅប៉ុណ្ណោះ។ ការដាក់ឲ្យដំណើរការគ្រឹះស្ថានសាធារណៈផ្សេងៗគ្នា ដើម្បីគ្រប់គ្រង និងចាត់ចែងរបបសោធនទៅតាមសមាជិកគោលដៅរៀងខ្លួនបែបនេះ នាំឲ្យមានចំណាយខ្ពស់លើដំណើរប្រតិបត្តិការស្ថាប័ន (ទាំងការឧបត្ថម្ភបុគ្គលិក និងការរៀបចំប្រព័ន្ធព័ត៌មានវិទ្យាជាដើម)។

ប្រព័ន្ធសន្តិសុខសង្គម គឺជាប្រព័ន្ធបង់ភាគទានដែលទាមទារឲ្យមានការចូលរួមពីសំណាក់និយោជិត និងនិយោជក ទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន និងពីនិវត្តជន ព្រមទាំង ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធផងដែរ។ ទោះជាយ៉ាងណា រាជរដ្ឋាភិបាលនឹងរ៉ាប់រងលើការបង់ភាគទានជំនួសប្រជាជនក្រីក្រងាយរងគ្រោះ និង ក្រុមប្រជាជនគោលដៅផ្សេងទៀត ដែលរាជរដ្ឋាភិបាលយល់ថាចាំបាច់ដើម្បីលើកកម្ពស់ជីវភាពជនទាំងនោះទៅ តាមលទ្ធភាពនៃការទ្រទ្រង់បាននៃថវិកាជាតិ។ការរ៉ាប់រងលើការបង់ភាគទានជំនួសទាំងស្រុង ឬមួយភាគ ត្រូវអនុវត្តដោយ ផ្អែកលើលក្ខខណ្ឌសមស្រប និងច្បាស់លាស់ ដើម្បីជៀសវាងការកើតឡើងនូវ "ហានិភ័យចិត្តសាស្រ្ត" (Moral hazard) ដែលមិនលើកទឹកចិត្តដល់ប្រជាជនឲ្យមានការសន្សំសម្រាប់គាំពារហានិភ័យជាយថាហេតុ និង/ឬ ដែលអាចមានផលប៉ះពាល់ជាអវិជ្ជមានទៅលើផលិតភាពការងារ។ ដោយផ្អែកលើហេតុផលនេះ ក៏ដូចជាកត្តាសំខាន់ដទៃទៀតនៅរយៈកាលវែងទៅអនាគត និងនៅពេលលក្ខខណ្ឌសេដ្ឋកិច្ច-

សង្គមសមស្រប រាជរដ្ឋាភិបាលនឹងដកខ្លួនបន្តិចម្តងៗពីការធ្វើហិរញ្ញប្បទានរបបសន្តិសុខ សង្គមជាក់លាក់មួយចំនួន។ ដូចនេះ ប្រព័ន្ធសន្តិសុខសង្គមត្រូវពឹងផ្អែកលើប្រភពហិរញ្ញប្បទានពីការបង់ភាគទាន ព្រមទាំង ចំណូលពីការវិនិយោគ ធនធានហិរញ្ញវត្ថុដែល ត្រូវបានប្រមូលផ្តុំនោះ។

ចក្ខុវិស័យរយៈពេលវែងសម្រាប់ការអភិវឌ្ឍប្រព័ន្ធសោធននៅកម្ពុជា គឺការសម្រេចបាននូវប្រព័ន្ធសោធនដែលមានការគ្របដណ្តប់ជាសកល។ រាជរដ្ឋាភិបាលកំពុងដំណើរការកំណែទម្រង់ប្រព័ន្ធសោធនឲ្យមានលក្ខណៈប្រមូលផ្តុំ ដោយឈរលើគោលការណ៍បីគឺ៖ ភាពដែលអាចទ្រទ្រង់បាន សក្តិសិទ្ធិភាព និងចីរភាព[28]។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម សំដៅជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឲ្យកាន់តែរឹងមាំ និងល្អប្រសើរ ដែលក្នុងសសរស្តម្ភប្រព័ន្ធគាំពារសង្គម ក៏មានប្រព័ន្ធសន្តិសុខសង្គម ដែលផ្តល់ការគាំពារហានិភ័យលើផ្នែកប្រាក់សោធន រួមជាមួយនឹង និយ័តករសន្តិសុខសង្គមដែលជាស្ថាប័ន គ្រប់គ្រងរាល់ប្រត្តិបត្តិការរបបសន្តិសុខសង្គម។

ដើម្បីយល់ដឹងកាន់តែលម្អិតពីស្ថាប័នគ្រប់គ្រងរាល់ប្រត្តិបត្តិការសន្តិសុខសង្គម គប្បីធ្វើការសិក្សា (ក) ក្រុមប្រឹក្សាជាតិគាំពារសង្គម (ខ) និយ័តករសន្តិសុខសង្គម (គ) ប្រត្តិបត្តករសន្តិសុខសង្គម។

### ក. ក្រុមប្រឹក្សាជាតិគាំពារសង្គម

ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឲ្យកាន់តែប្រសើរឡើងនឹងតម្រូវការបន្សុយុទ្ធសាស្ត្រ គោលនយោបាយ និងសកម្មភាពគាំពារសង្គមនានា រាជរដ្ឋាភិបាលនឹងបង្កើត "ក្រុមប្រឹក្សាជាតិគាំពារសង្គម" ដែលមានតួនាទីជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការសម្របសម្រួល និងតម្រង់ទិសជាយុទ្ធសាស្ត្ររួម លើការងាររៀបចំគោលនយោបាយគាំពារសង្គមដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។

#### ១. ក្របខណ្ឌគោលនយោបាយជាតិគាំពាំរសង្គម

ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦ ដល់ ២០២៥ មានវិសាលភាពគ្របដណ្តប់លើប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម។ វិសាលភាពដ៏ទូលំទូលាយនេះ ផ្តល់នូវក្របខ័ណ្ឌសម្រាប់ការតភ្ជាប់ទំនាក់ទំនងរវាងប្រព័ន្ធទាំងពីរ ដែលមានលក្ខណៈបំពេញគ្នាទៅវិញទៅមក។ ប្រព័ន្ធជំនួយសង្គម ជាប្រព័ន្ធសម្រាប់គ្រប់គ្រងកម្មវិធីជំនួយសង្គម ដែលរួមបញ្ចូលអន្តរាគមន៍សម្រាប់ជាប្រយោជន៍ដល់ប្រជាជនក្រីក្រ និងងាយរងគ្រោះ ដែលធ្វើហិរញ្ញប្បទានដោយចំណូលថវិកាជាតិ និង/ឬជំនួយអភិវឌ្ឍន៍ផ្លូវការ។ ប្រព័ន្ធជំនួយសង្គមនៅកម្ពុជាមានធាតុផ្សំ ៤ រួមមាន៖ (១) **ការឆ្លើយតបទៅនឹងគ្រោះអាសន្ន** (២) **ការអភិវឌ្ឍមូលធនមនុស្ស** (៣) **ការបណ្តុះបណ្តាលវិជ្ជាជីវៈ** និង(៤) **សុខុមាលភាពសម្រាប់ប្រជាជនងាយរងគ្រោះ**។ ប្រព័ន្ធសន្តិសុខ

[28] គេហទំព័រផ្លូវការ ក្រុមប្រឹក្សាជាតិគាំពារសង្គម

សង្គម ជាប្រព័ន្ធសម្រាប់គ្រប់គ្រងកម្មវិធីសន្តិសុខសង្គម ដែលរួមបញ្ចូលកម្មវិធីដែលរៀបចំឡើងដើម្បីជួយដល់ប្រជាជន ក្នុងការការពារពួកគាត់ពីការធ្លាក់ចុះភ្លាមៗនៃប្រាក់ចំណូលដែលបណ្តាលមកពីជំងឺ លំហែមាតុភាព គ្រោះថ្នាក់ការងារ និកម្មភាព ទុព្វលភាព ជរាភាព (ឬចូលនិវត្តន៍) និងមរណភាពនៃអ្នកដែលរកចំណូលសម្រាប់គ្រួសារ។ របបសន្តិសុខសង្គមតម្រូវឲ្យសមាជិក និង/ឬ ភាគីពាក់ព័ន្ធបង់ភាគទានជាកាតព្វកិច្ចទៅតាមអត្រាជាក់លាក់។ រាជរដ្ឋាភិបាលប្រកាន់ខ្ជាប់លើគោលការណ៍ផ្តល់ឧបត្ថម្ភធនជូនដល់ប្រជាជនដែលមិនមានលទ្ធភាពបង់ភាគទាន ពោលគឺប្រជាជនក្រីក្រ និងងាយរងគ្រោះ។ ប្រព័ន្ធសន្តិសុខសង្គមនៅក្នុងប្រទេសកម្ពុជាមានធាតុផ្សំ(១) សោធន(២) ថែទាំសុខភាព (៣) ហានិភ័យការងារ (៤) និកម្មភាព និង (៥) ពិការភាព។

កន្លងមក រាជរដ្ឋាភិបាលតែងផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ដែល(**ប.ស.ស**) បេឡាជាតិសន្តិសុខស្តែងចេញពីការដាក់ឲ្យដំណើរការបេឡាជាតិរបបសន្តិសុខសង្គមសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (**ប.ជ.ស**) បេឡាជាតិអតីតយុទ្ធជន (**ប.ជ.អ**) និងមូលនិធិជនពិការ(**ម.ជ.ព**) ព្រមទាំង ការអនុម័តយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងងាយរងគ្រោះ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការដាក់ឲ្យដំណើរការកម្មវិធីជាតិជំនួយសង្គមមួយចំនួន។ សម្រាប់អាណត្តិទី៥នេះរាជរដ្ឋាភិបាលបានដាក់ចេញគោលនយោបាយកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យក្នុងនោះយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍនជាតិ២០១៤-២០១៨បានកំណត់យក "ការបន្តពង្រឹង និងអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឲ្យមានលក្ខណៈប្រមូលផ្តុំ សង្គតិភាព និងប្រសិទ្ធភាព" ជាគោលដៅអាទិភាព។ នៅក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ សំដៅជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឲ្យកាន់តែរឹងមាំ និងល្អប្រសើរឡើងព្រមទាំង អាចគ្របដណ្តប់ប្រជាជនគ្រប់រូប ជាពិសេសប្រជាជនក្រីក្រ និងងាយរងគ្រោះ។ ចក្ខុវិស័យរយៈកាលវែងរបស់រាជរដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម គឺការកសាងប្រព័ន្ធគាំពារសង្គមប្រកបដោយបរិយាប័ន្ន ប្រសិទ្ធភាព និងចីរភាពហិរញ្ញវត្ថុដែលជាឧបករណ៍បម្រើដល់ការកាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព ហើយរួមចំណែកដល់ការអភិវឌ្ឍន៍ និងគាំពារធនធានមនុស្សកាន់តែទូលំទូលាយ និងជំរុញកំណើនសេដ្ឋកិច្ច។

ចំពោះផ្នែកសន្តិសុខសង្គម បច្ចុប្បន្ន មន្ត្រីសាធារណៈទទួលបានការគាំពារនៅពេលចូលនិវត្តន៍និងពេលបាត់បង់សមត្ថភាពការងារពី **ប.ជ.ស** និង **ប.ជ.អ**។ រីឯ កម្មករនិយោជិតទទួលបានការថែទាំសុខភាពជម្ងឺរិដ្ឋាជីវៈ និងគ្រោះថ្នាក់ការងារពី **ប.ស.ស**។ ដោយឡែក ការថែទាំសុខភាពទូទៅសម្រាប់សេវាសាធារណៈ និងកម្មករនិយោជិត ព្រមទាំង ប្រជាជនទូទៅ នៅមានភាពខ្វះចន្លោះនៅឡើយ។ ជាមួយគ្នានេះ កម្មករនិយោជិត និងប្រជាជនទូទៅ ក៏មិនទាន់ទទួលបានការគាំពារសម្រាប់ពេលចូលនិវត្តន៍ពីការងារឬពេលឈានចូលវ័យជរានៅឡើយ។

ចំណែក ហានិភ័យក្នុងការបាត់បង់ការងារ ក៏មិនទាន់មានការការពារ។ រូបភាពខាងក្រោមបង្ហាញពីវឌ្ឍនភាព និងភាពខ្វះចន្លោះនៃប្រព័ន្ធគាំពារសង្គមទាំងមូលទៅតាមវដ្តជីវិតរបស់មនុស្ស។

ដើម្បីធានានូវការបំពេញភារកិច្ចសម្របសម្រួលពហុវិស័យ ប្រកបដោយប្រសិទ្ធភាពខ្ពស់ "ក្រុមប្រឹក្សាជាតិគាំពារសង្គម" នេះ នឹងត្រូវបង្កើតឡើងដោយមានសមាសភាពជាឥស្សរជនមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាល។ ក្រុមប្រឹក្សាជាតិនេះ ត្រូវមានសមាសភាពមកពីក្រសួង-ស្ថាប័នសំខាន់ៗរួមមាន៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងផែនការ ក្រសួងយុត្តិធម៌ និងក្រសួងមុខងារសាធារណៈជាដើម។ ក្រុមប្រឹក្សាជាតិគាំពារសង្គម មានមុខងារ (១) សម្របសម្រួលការរៀបចំគោលនយោបាយអភិវឌ្ឍន៍ប្រព័ន្ធគាំពារសង្គមរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ឲ្យមានលក្ខណៈជាគោលនយោបាយរួមដើម្បីដាក់ស្នើសុំការអនុម័តពីប្រមុខរាជរដ្ឋាភិបាល (២) ពិនិត្យ និងតាមដានលើវឌ្ឍនភាព និងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយគាំពារសង្គម ដើម្បីជំរុញឲ្យការអនុវត្តប្រព្រឹត្តទៅដោយរលូនមានសង្គតិភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព និង (៣) ផ្សារភ្ជាប់ និងបន្សាំប្រព័ន្ធជំនួយសង្គមជាមួយនឹងប្រព័ន្ធសន្តិសុខសង្គម ដើម្បីធានាសង្គតិភាព និងបំពេញបន្ថែមសកម្មភាពចាំបាច់ នៅក្នុងចក្ខុវិស័យរួមនៃប្រព័ន្ធគាំពារសង្គម និងផ្តល់លទ្ធភាពសម្រាប់ការផ្ទេរក្រុមគោលដៅពីប្រព័ន្ធមួយទៅប្រព័ន្ធមួយទៀតនៅពេលដែលឱកាសផ្តល់ឲ្យ។ ក្រុមប្រឹក្សាជាតិគាំពារសង្គម មានអគ្គលេខាធិការដ្ឋានដើម្បីទទួលបន្ទុកការងារប្រចាំថ្ងៃ។ អគ្គលេខាធិការដ្ឋាននេះ ត្រូវបង្កើតឡើងក្រោមចំណុះក្រសួង-ស្ថាប័នសមស្របមួយរបស់រាជរដ្ឋាភិបាល ដោយឈរលើគោលការណ៍ ប្រសិទ្ធភាព និងសក្តិសិទ្ធិភាពនៃការគ្រប់គ្រង និងការសម្របសម្រួលស្ថាប័ន។

### ខ. និយ័តករសន្តិសុខសង្គម

រាជរដ្ឋាភិបាលបានបង្កើតនិងដាក់ឲ្យដំណើរការ និយ័តករសន្តិសុខសង្គមដែលជាសេនាធិកានៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធានាគារ ដើម្បីធ្វើនិយ័តកម្ម និង ត្រួតពិនិត្យលើប្រតិ្តការក្នុងប្រព័ន្ធសន្តិសុខសង្គម។

វត្តមានរបស់និយ័តករសន្តិសុខសង្គមមានសារៈសំខាន់ណាស់ក្នុងការធានាថាកិច្ចដំណើរការគ្រប់គ្រង និងការចាត់ចែងក្នុងរបបសន្តិសុខសង្គមនានាត្រូវអនុវត្តដោយភាពត្រឹមត្រូវ តម្លាភាព និងគណនេយ្យភាពចំពោះសាធារណៈជន ជាពិសេសនិយោជិត និងនិយោជកដែលបានបង់ភាគទានរួមគ្នា។ បេឡាជាតិសន្តិសុខសង្គម (**ប.ស.ស.**) ជាប្រតិបត្តិករតែមួយគត់ក្នុងការធ្វើប្រតិបត្តិការរបបសន្តិសុខសង្គមស្របតាមបទបញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមស្ថិតក្រោមនិយ័តកម្ម ឬក្របខណ្ឌត្រួតពិនិត្យ របស់និយ័តករសន្តិសុខសង្គម(**ន.ស.ស.**)[29]។

[29] អនុលោមតាម មាត្រា៦ នៃអនុក្រឹត្យលេខ១៦០ អនក្រ.បក ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ ២០២២ ស្តីពីនិយ័តកម្មប្រព័ន្ធសន្តិសុខសង្គម រាជរដ្ឋាភិបាលកម្ពុជា។

បច្ចុប្បន្ន **ប.ស.ស.** កំពុងគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ។ នាពេលខាងមុខ **ប.ស.ស.** ក៏នឹងគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនផងដែរ។

**ន.ស.ស.** មានសមត្ថកិច្ចក្នុងការស្នើនូវបទប្បញ្ញត្តិសម្រាប់ការធ្វើនិយ័តកម្មប្រព័ន្ធសន្តិសុខសង្គម ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ពាក់ព័ន្ធជាធរមាន និងអនុក្រឹត្យនេះជូនដល់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីអនុម័ត និងដាក់ឱ្យអនុវត្ត។ **ន.ស.ស.** មានសមត្ថកិច្ចត្រួតពិនិត្យប្រតិបត្តិការសន្តិសុខសង្គម ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ **ន.ស.ស.** ត្រូវចាត់មន្ត្រីដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍ប្រតិបត្តិការ និងឯកសារពាក់ព័ន្ធនានារបស់ប្រតិបត្តិករសន្តិសុខសង្គម មូលដ្ឋានសុខាភិបាលឯកជនដែលបានចុះកិច្ចព្រមព្រៀងជាមួយប្រតិបត្តិករសន្តិសុខសង្គម តួអង្គបុគ្គល និង/ឬ ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ក្នុងប្រតិបត្តិការសន្តិសុខសង្គម។ ប្រតិបត្តិករសន្តិសុខសង្គម មូលដ្ឋានសុខាភិបាលឯកជនដែលបានចុះកិច្ចព្រមព្រៀងជាមួយប្រតិបត្តិករសន្តិសុខសង្គម តួអង្គ បុគ្គល និង/ឬ ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ក្នុងប្រតិបត្តិការសន្តិសុខសង្គម មានកាតព្វកិច្ចផ្តល់របាយការណ៍ និងឯកសារតាមការស្នើសុំរបស់មន្ត្រី **ន.ស.ស.** ដើម្បីបំពេញការងារនិយ័តកម្ម[30]។

**គ. ប្រតិបត្តិករសន្តិសុខសង្គម**

របបសន្តិសុខសង្គមត្រូវបានបង្កើតឡើងក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៥៥ យោងតាមព្រះរាជក្រឹត្យលេខ ៥៥ និង៣០៦។ តែគួរឲ្យសោកស្តាយកំឡុងពេលរបប ប្រល័យពូជសាសន៍ (១៩៧៥-១៩៧៩) សន្តិសុខសង្គមនេះត្រូវបានបំផ្លាញចោលទាំងស្រុង។ ពីឆ្នាំ១៩៧៩-១៩៩៣ ប្រជាជនបានទទួលសេវាថែទាំសុខភាពដោយ ឥតគិតថ្លៃ។ បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ នាយកដ្ឋានសន្តិសុខសង្គមត្រូវបានបង្កើតឡើង។

នាយកដ្ឋាននេះទទួលខុសត្រូវការរៀបចំទាំងអស់នៃប្រកាសសម្រាប់ ការអនុវត្តកិច្ចគាំពារសន្តិសុខសង្គមដល់ប្រជាជនដែលធ្វើការក្នុងវិស័យឯកជន។ ជាលទ្ធផលការកែប្រែបទប្បញ្ញត្តិស្តីពីច្បាប់ការងារឆ្នាំ ១៩៩២ ដែលជាច្បាប់ការងារ កម្ពុជា បច្ចុប្បន្នដែលអនុម័តក្នុងឆ្នាំ១៩៩៧ ត្រូវបានអនុវត្តដោយនាយកដ្ឋានការងារ (ថ្មីៗនេះប្តូរទៅជាអគ្គនាយកដ្ឋានការងារ)។ បន្ទាប់ពីនោះមក ច្បាប់សន្តិសុខសង្គម ត្រូវបានអនុម័តដោយសភានៅខែកញ្ញា ឆ្នាំ២០០២ ដែលថ្មីៗត្រូវបានគេស្គាល់ថា ច្បាប់របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃ ច្បាប់ស្តីពីការងារ។ អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គមត្រូវបានអនុម័ត នៅឆ្នាំ២០០៧ ដែលបង្កើតឡើងដើម្បីជំនួសនាយកដ្ឋានសន្តិសុខសង្គម។ **ប.ស.ស**

[30]អនុលោមតាម មាត្រា៥ នៃអនុក្រឹត្យលេខ១៦០ អនក្រ.បក ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ ២០២២ ស្តីពី និយ័តកម្មប្រពន្ធ័សន្តិសុខសង្គម រាជរដ្ឋាភិបាល។

ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងផ្នែកកិច្ចគាំពារ សន្តិសុខសង្គមឱ្យស្របទៅតាមច្បាប់សន្តិសុខសង្គមជាតិ និង បទប្បញ្ញត្តិសន្តិសុខសង្គមអនុលោមតាម អនុក្រឹត្យ។ ក្រោយពីការរៀបចំដ៏ធំទូលាយនេះ **ប.ស.ស** ត្រូវបាន ដំណើរការនៅចុងឆ្នាំ២០០៨ ។

ឈរលើការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពប្រកបដោយ ជោគជ័យ និងធានាឱ្យមានភាពសង្គតិភាពក្នុងការគាំពារសង្គមទាំងវិស័យឯកជន និងមន្ត្រីរាជការ ក្នុងវិស័យសាធារណៈ រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចឱ្យ **ប.ស.ស** ជាអ្នករៀបចំ និងគ្រប់គ្រងការដាក់ឱ្យដំណើរការរបបសន្តិសុខ សង្គមផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីត មន្ត្រីរាជការ និងអតីតយុទ្ធជនចាប់ពី ឆ្នាំ២០១៧តទៅ។

ពីមុនមកក្នុងវិស័យឯកជនពុំទាន់មានប្រាក់ចូលនិវត្តន៍ដូចមន្ត្រីរាជការនៅឡើយ ទើបតែឆ្នាំ២០២២នេះ ទេជារបត់ថ្មី និងជាប្រវត្តិសាស្ត្រ ដែលរាជរដ្ឋាភិបាលដាក់ចេញបន្ថែមគោលនយោបាយថ្មីជូនបុគ្គលិកក្នុងវិស័យ ឯកជនឱ្យទទួលបានប្រាក់ចូលនិវត្តន៍ដូចទៅនឹងមន្ត្រីរាជការដែរ ហើយផ្នែកប្រាក់សោធនវិស័យឯកជននេះជា របបសន្តិសុខសន្តិសង្គមថ្មី ដែលតម្រូវឲ្យមានការចូលរួមពីសំណាក់និយោជក និងកម្មករនិយោជិត **ប.ស.ស.** ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានការចូលរួមត្រីភាគីរវាងភាគីរដ្ឋាភិបាល តំណាងនិយោជក និង តំណាងកម្មករនិយោជិត ហើយ **ប.ស.ស.** ជាប្រតិបត្តិករសន្តិសុខសង្គមរបស់រដ្ឋជាប្រព័ន្ធដែលមាននិរន្តន៍ភា- ព។ ប្រព័ន្ធសន្តិសុខសង្គម គឺជាប្រព័ន្ធ បង់ភាគទាន ដែលទាមទារឲ្យមានការចូលរួមពីសំណាក់និយោជិត និង និយោជក ទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន និងពីនិវត្តជន ព្រមទាំង ប្រជាជននៃវិស័យសេដ្ឋកិច្ច ក្រៅប្រព័ន្ធផងដែរ។ ទោះជាយ៉ាងណា រាជរដ្ឋាភិបាលនឹងរ៉ាប់រងលើការបង់ភាគទានជំនួសប្រជាជនក្រីក្រងាយ រងគ្រោះ និង ក្រុមប្រជាជនគោលដៅផ្សេងទៀត ដែលរាជរដ្ឋាភិបាលយល់ថាចាំបាច់ដើម្បីលើកកម្ពស់ជីវភាពជន ទាំងនោះទៅ តាមលទ្ធភាពនៃការទ្រទ្រង់បាននៃថវិកាជាតិ។

របបសន្តិសុខសង្គមផ្នែកប្រាក់សោធនគឺជាប្រាក់ចូលនិវត្តន៍រៀងរាល់ខែដែលនឹងទទួលបាននៅពេល ចូលនិវត្តន៍ចាប់ពីអាយុ៦០ឆ្នាំឡើងទៅ ប្រសិនបើជាសមាជិកនៃរបបសន្តិសុខសង្គមផ្នែកមួយនេះ។ របបសន្តិ សុខសង្គមផ្នែកប្រាក់សោធន បានរួមចំណែកយ៉ាងសំខាន់បំផុតក្នុងការបង្កើន ស្មារតីទទួលខុសត្រូវខ្ពស់ ខិតខំ បំពេញការងារប្រកបដោយស្ថិរភាព និងភាពយូរអង្វែងរបស់ កម្មករនិយោជិត ឈានដល់ការបង្កើតផលិតភាព ជូនសហគ្រាស គ្រឹះស្ថានរបស់ខ្លួន។ របបសន្តិសន្តិសុខសង្គមផ្នែកប្រាក់សោធនថ្មីនេះ គឺឱ្យកម្មករនិយោជិត ទាំងអស់ក្នុងវិស័យ ឯកជនទទួលបានប្រាក់ចូលនិវត្តន៍នៅពេលចាស់ធ្វើការលែងកើត ដូចទៅនឹងមន្ត្រី រាជកា រដែរ។ ការវិនិយោគមូលនិធិសន្តិសុខសង្គម ត្រូវគោរពតាមគោលការណ៍ប្រុងប្រយ័ត្ន រួមមានការរក្សាសុវត្ថិភាព មូលនិធិវិនិយោគ ភាពរឹងមាំផ្នែកហិរញ្ញវត្ថុ និងផលចំណូលនៃការវិនិយោគមូលនិធិ។ការវិនិយោគមូលនិធិសន្តិ

សុខសង្គម ត្រូវអនុលោមតាមគោលការណ៍ណែនាំ ស្តីពីការវិនិយោគមូលនិធិសន្តិសុខសង្គម[31]។ យន្តការគ្រប់គ្រងមូលនិធិសន្តិសុខសង្គម[32] និង គោលការណ៍ណែនាំស្តីពីការវិនិយោគមូលនិធិសន្តិសុខសង្គម ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

[31]អនុលោមតាម មាត្រា២២ នៃអនុក្រឹត្យលេខ១៦០ អនក្រ.បក ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ ២០២២ ស្តីពី និយ័តកម្មប្រពន្ធ័សន្តិសុខសង្គម រាជរដ្ឋាភិបាល។

[32] មូលនិធិសន្តិសុខសង្គម សំដៅដល់បណ្តុំនៃមូលនិធិដែលប្រមូលបានពីការបង់ភាគទានតាមផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម ដែលមានដូចជាមូលនិធិសន្តិសុខសង្គមផ្នែកប្រាក់សោធន មូលនិធិសន្តិសុខសង្គមផ្នែកថែទាំសុខភាព មូលនិធិសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងមូលនិធិសន្តិសុខសង្គមផ្នែកនិកម្មភាពការងារ (អនុក្រឹត្យស្តីពី និយ័តកម្មប្រពន្ធ័សន្តិសុខសង្គម រាជរដ្ឋាភិបាល)។

# ជំពូកទី២

# តាចការលិកផ្ដែកប្រាក់សោធនតាម

# របបភាគទានជាកាតព្វកិច្ច

# ជំពូកទី២

# តាវកាលិកផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច

## កថាខណ្ឌទី១. ការផ្តល់តាវកាលិកផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច

តាវកាលិកនៃប្រាក់សោធនសំដៅដល់អត្ថប្រយោជន៍ក្នុងផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម ដែលត្រូវផ្តល់ឲ្យដល់សមាជិក បេឡាជាតិសន្តិសុខសង្គមនៅពេលដែលសាមីជនត្រូវដល់ពេលចូលនិវត្តន៍ ឬ ជួបប្រទះនៃហានិភ័យការងារដែលនាំអោយបាត់បង់លទ្ធភាពបំពេញការងារដើម្បីរកប្រាក់ចំណូលបន្ថែម។ អត្ថប្រយោជន៍នៃប្រាក់សោធនតាមរបបភាគទានដែលផ្តល់ដោយ បេឡាជាតិសន្តិសុខសង្គមមានដូចជា៖ សោធនជរាភាព សោធនទុព្វលភាព សោធនឧត្តរជីវី និង វិភាជន៍បូជាសព។

ប្រាក់សោធននៃតាវកាលិកដែលបានផ្តល់អោយដែលមានដូចជា៖ សោធនជរាភាព សោធនទុព្វលភាព សោធនឧត្តរជីវី និង វិភាជន៍បូជាសព ត្រូវធ្វើការគណនាជាប្រចាំខែ[33]។ បេឡាជាតិសន្តិសុខសង្គមត្រូវរៀបចំបើកផ្តល់តាវកាលិកប្រចាំខែផ្នែកប្រាក់សោធនជាអឌ្ឍមាស[34]ពោលគឺ ដោយការបើកជាអឌ្ឍមាសទី១ យ៉ាងយូរនៅថ្ងៃទី ១៥ នៃខែនីមួយៗ ចំណែកឯអឌ្ឍមាសលើកទី ២ ត្រូវធ្វើការបើកយ៉ាងយូរត្រឹមរយៈពេល ៣០ ថ្ងៃ នៃខែនីមួយៗ។ ក្នុងករណីបើសិនកាលបរិច្ឆេទនៃកាលចូលនិវត្តន៍មិនស្ថិតចំដើមខែ នោះថ្ងៃដែលនៅសល់ត្រូវបូកសរុបនៅថ្ងៃបន្ទាប់។

ដើម្បីជាវិភាគទានក្នុងការបកស្រាយអំពីតាវកាលិកនៃប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ចនៅក្នុងវិស័យឯកជនដែលស្ថិតនៅក្រោមច្បាប់ការងារឲ្យកាន់តែច្បាស់លាស់យើងគប្បីធ្វើការសិក្សាពី (ក) សោធនជរាភាព (ខ) សោធនទុព្វលភាព (គ) សោធនឧត្តរជីវី និង (ឃ) វិភាជន៍បូជាសព។

### ក. សោធនជរាភាព

សោធនជរាភាព គឺជាប្រាក់ដែលត្រូវផ្តល់ជូនទៅឲ្យបុគ្គលដែលជាសមាជិកប្រតិបត្តិករនៃបេឡាជាតិសន្តិសុខសង្គម ( ប.ស.ស ) នៅពេលសាមីជនមានអាយុយ៉ាងតិច ៦០ (ហុកសិប) ឆ្នាំ ពោលគឺនឹងត្រូវដាក់ឲ្យចូលនិវត្តន៍នៅពេលដល់អាយុ ៦០(ហុកសិប) ឆ្នាំ។

#### ១. លក្ខខណ្ឌដើម្បីទទួលបានតាវកាលិកផ្នែកប្រាក់សោធនជរាភាពតាមរបបភាគទានជាកាតព្វកិច្ច

[33] អនុលោមតាមមាត្រា២៧ នៃអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។

[34] អឌ្ឍមាស មានន័យថាពាក់កណ្តាលខែ។

ជាការពិតណាស់សោធនជរាភាពគឺជាប្រាក់បៀវត្សសម្រាប់បុគ្គលដែលមានវ័យចំណាស់ហើយនៅពេលដែលសាមីជនបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីទទួលបានសោធនជរាភាពនៅពេលដែលដល់អាយុដែលត្រូវចូលនិវត្តន៍នោះពួកគេនឹងទទួលបាននូវអត្ថប្រយោជន៍ដូចជា៖

- សាមីជនទទួលបានប្រាក់សោធនជរាភាព ប្រាក់ចូលនិវត្តន៍ អស់មួយជីវិតដោយមានសិទ្ធិអាចបើកបាន ២ដង ក្នុង ១ខែ
- សាមីជនទទួលបានការព្យាបាល និង ថែទាំសុខភាពនៅមន្ទីរពេទ្យដៃគូរបស់បេឡាជាតិសន្តិសង្គម (ប.ស.ស) ដោយមិនគិតប្រាក់
- សាមីជនទទួលបានប្រាក់វិភាជន៍បូជាសព នៅពេលទទួលមរណភាព
- ទទួលបានប្រាក់សោធនឧត្តរជីវី (ពេលដែលអ្នកចូលនិវត្តន៍ទទួលមរណភាព ប្តី ឬប្រពន្ធ និងកូននៅក្នុងបន្ទុកនឹងទទួលបានប្រាក់ ៤៥% នៃប្រាក់ចូលនិវត្តន៍របស់អ្នកចូលនិវត្តន៍)។

ទន្ទឹមនឹងនេះដើម្បីទទួលបាននូវអត្ថប្រយោជន៍ពីសោធនជរាភាពលុះត្រាតែសាមីជនមានអាយុយ៉ាងតិច ៦០ឆ្នាំ ហើយសាមីជនបានបំពេញនូវលក្ខខណ្ឌដូចជា[35]៖

- សាមីជនបានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន
- ព្រមទាំងបានបង់ភាគទានផ្នែកប្រាកសោធនចំនួនយ៉ាងតិច១២ខែ។

### ២. ការគណនាចំនួនប្រាក់សោធនជរាភាព

អត្រាសមាច័យនៃប្រាក់សោធនជរាភាពមានអតិបរមាស្មើនឹង១,៧៥% (មួយក្បៀសចិតសិបប្រាំភាគរយ) ក្នុងមួយឆ្នាំនៃភាគទាន។ ចំណែកឯប្រាក់បៀវត្សចំពោះកម្មករនិយោជិតដែលបានបំពេញលក្ខខណ្ឌដើម្បីទទួលបានតាវកាលិកនៃប្រាក់សោធនជរាភាពនឹងត្រូវធ្វើការគណនាជាអនុគមន៍នៃប្រាក់ឈ្នួលមធ្យមដែលសាមីជនបានបង់ភាគទាន។ សោធនជរាភាពដែលផ្តល់អោយសាធនិកត្រូវគណនាតាមរូបមន្តដូចខាងក្រោម[36]៖

| តាមរូបមន្ត៖ សជ[37] = អស[38] x បឈម[39] |
|---|

- **ដើម្បីគណនារកចំនួនប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទាន ( បឈម )**

---

[35] អនុលោមតាម មាត្រា៣១ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម។

[36] អនុលោមតាម មាត្រា១៣ នៃអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។

[37] សជ គឺជាសោធនជរាភាពរបស់សាមីជនដែលត្រូវទទួលបាន។

[38] អស គឺជាអត្រាសោធនដែលទទួលបាន។

[39] បឈម គឺជាប្រាក់ឈ្នួលមធ្យមដែលសាមីជនបានបង់ភាគទានក្នុងរយៈពេលមិនលើស ១២០ខែ ចុងក្រោយមុនកាលបរិច្ឆេទមានសិទ្ធិទាមទារតាវកាលិក។

➢ នាំឲ្យប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទាន = $\frac{\text{ប្រាក់ឈ្នួលជាប់ភាគទានដែលបានប្រកាសមក ប.ស.ស}}{\text{១២០ខែ}}$

❖ **ដើម្បីគណនារកចំនួនអត្រាសោធនដែលទទួលបាន ( អស )**

➢ នាំឲ្យ អត្រាសោធនដែលទទួលបាន= $\frac{\text{ចំនួនឆ្នាំដែលសមាជិក ប.ស.ស បានបង់ភាគទានក្នុងផ្នែកសោធន}}{\text{១២ខែ}}$

**ចំណាំ** បើផលចែកនៃឆ្នាំភាគទាន[40] មានសំណល់លើសពី ៦ (ប្រាំមួយ)ខែ នោះយើងត្រូវបូកបង្គ្រប់ថែម ១ឆ្នាំ។ ប៉ុន្តែបើសិនផលចែកនៃឆ្នាំភាគទានមានសំណល់តូចជាង ៦ (ប្រាំមួយ)ខែចុះនោះយើងត្រូវរក្សាចំនួនឆ្នាំភាគទានដដែល។

**ឧទាហរណ៍៖** បើយើងគណនាឃើញឆ្នាំភាគទានចំនួន ៣០ឆ្នាំ ៨ខែ នោះឆ្នាំភាគទានត្រូវបង្គ្រប់ស្មើនឹង ៣១ឆ្នាំ ព្រោះសំណល់នៃផលចែកលើស ៦ខែ ដូច្នេះយើងត្រូវបូកបង្គ្រប់ឆ្នាំ។

**ឧទាហរណ៍នៃការគណនា៖** លោកស្រី ដារី ចាប់ផ្តើមសន្សំក្នុងភាគទាន ប.ស.ស. ផ្នែកប្រាក់សោធនតាំងពីអាយុ២៥ឆ្នាំ ហើយបានបង់ចំនួន ៤០០ ខែហើយ គិតត្រឹមថ្ងៃគាត់ចូលនិវត្តន៍។

ប្រាក់ឈ្នួលជាប់ភាគទាន (យក១២០ខែចុងក្រោយមុនពេលចូលនិវត្តន៍) របស់គាត់គឺ៖

- ២០០$ ចំនួន៤០ខែ = ៨ ០០០$
- ២៥០$ ចំនួន៤០ខែ = ១០ ០០០$
- ៣០០$ ចំនួន៤០ខែ = ១២ ០០០$

សរុបបង់ក្នុងរយៈពេល ១២០ខែ = ៣០ ០០០$។

**ដើម្បីគណនារកចំនួនប្រាក់ចូលនិវត្តន៍ដែលអ្នកស្រី ដារី នឹងទទួលបាន**

តាមរូបមន្ត៖ សជ = អស x បឈម

**រកចំនួនអត្រាសោធនដែលទទួលបាន** (**អស**)

នាំឲ្យ អត្រាសោធនដែលទទួលបាន= $\frac{\text{ចំនួនឆ្នាំដែលសមាជិក ប.ស.ស បានបង់ភាគទានក្នុងផ្នែកសោធន}}{\text{១២ខែ}}$

ដោយអ្នកស្រីដារីបានបង់ភាគទានក្នុងផ្នែកសោធនចំនួន ៤០០ខែ នោះយើងបាន៖

➢ យើងបាន អស = $\frac{\text{៤០០}}{\text{១២}}$ = ៣៣.៣៣ ដោយផលចែកមានសំណល់តូចជាង ៦ នោះអត្រាសោធនដែលទទួលបានគឺ ៣៣ ឆ្នាំ ដែលនាំអោយអត្រាសោធនទទួលបាន = ៤៨.៧៥%។

**រកចំនួនប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទាន ( បឈម )**

ប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទាន = $\frac{\text{ប្រាក់ឈ្នួលជាប់ភាគទានដែលបានប្រកាសមក ប.ស.ស}}{\text{១២០ខែ}}$

[40] ឆ្នាំភាគទាន សម្តៅដល់ឆ្នាំដែលសមាជិក ប.ស.ស បានបង់ភាគទានក្នុងផ្នែកសោធន។

ដោយប្រាក់ឈ្នួលជាប់ភាគទានរបស់អ្នកស្រីដារីបានបង់មក ប.ស.ស (យក១២០ខែចុងក្រោយមុនពេលចូលនិវត្តន៍) របស់គាត់គឺ៖

- ២០០$ ចំនួន៤០ខែ = ៨ ០០០$
- ២៥០$ ចំនួន៤០ខែ = ១០ ០០០$
- ៣០០$ ចំនួន៤០ខែ = ១២ ០០០$

សរុបបង់ក្នុងរយៈពេល ១២០ខែ = ៣០ ០០០$។

↳ នាំឲ្យ បឈម = $\frac{៣០០០០}{១២០}$ = ២៥០$

↳ សជ = អស x បឈម

= ៤៤.៧៥ x ២៥០

= ១២១. ៨៨$

ដូចនេះ លោកស្រី ដារី ពេលចូលនិវត្តន៍ អាចទទួលបានគឺ ១២១. ៨៨$/ខែ អស់មួយជីវិត។

**ខ. សោធនទុព្វលភាព**

សោធនទុព្វលភាពសម្តៅដល់ប្រាក់សោធនដែលត្រូវផ្តល់ជូនបុគ្គលដែលបានបាត់បង់សមត្ថភាពការងារដែលមិនបណ្តាលមកពីហានិភ័យការងារ ពោលគឺអាចត្រូវជាជនដែលទទួលរងនូវទុព្វលភាពលុះត្រាតែសាមីជនមានជម្ងឺ ឬ រងភាពពិការដែលនាំអោយអស់សមត្ថភាពរកប្រាក់ចំណូលដែលកំណត់នៅក្នុងខ្សែបន្ទាត់ក្រីក្ររបស់ព្រះរាជាណាចក្រកម្ពុជា។

**១. លក្ខខណ្ឌដើម្បីទទួលបានភាពការលិកផ្នែកប្រាក់សោធនទុព្វលភាពតាមរបបភាគទានជាភាគព្វកិច្ច**

កម្មករនិយោជិតដែលបានចុះឈ្មោះក្នុងបញ្ជីនៅ បេឡាជាតិសន្តិសុខសង្គម (ប.ស.ស) ក្នុងផ្នែកសោធនក្នុងវិស័យឯកជននៅពេលបាត់បងសមត្ថភាពការងារដែលមិនបណ្តាលពីគ្រោះថ្នាក់ការងារ និងមានសិទ្ធិទទួលបានអត្ថប្រយោជន៍ដូចជា៖

- កម្មករនិយោជិតទទួលបានប្រាក់ចូលនិវត្តន៍អស់មួយជីវិតដោយធ្វើការបើក ២ដងក្នុងរយៈពេល១ខែ
- ទទួលបានប្រាក់ឧបត្ថម្ភ ៥០% នៃប្រាក់សោធនជូនទៅអ្នកថែទាំសោធនិក
- ទទួលបានការព្យាបាល និង ថែទាំសុខភាពនៅមន្ទីរពេទ្យដៃគូនៃបេឡាជាតិសន្តិសុខសង្គម (ប.ស.ស)
។

លើសពីនេះកម្មករនិយោជិតទាំងអស់នៃ សហគ្រាសគ្រឹះស្ថានក្នុងវិស័យឯកជននឹងទទួលបាននូវតាវកាលិកបន្ទាប់ពីពួកគេបានបំពេញនូវលក្ខខណ្ឌដូចជា[41]៖

- កាលណាសាមីជនបានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន
- ហើយសាមីជនបានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិចចំនួន ៦០ខែ មុនកាលបរិច្ឆេទទទួលទុព្វលភាព។

គួរបញ្ជាក់ផងដែរនៅក្នុង១ឆ្នាំអត្រាសមាច័យនៃសោធនទុព្វលភាពមានអតិបរមាស្មើនឹង ១,៧៥% (មួយក្បៀសចិតសិបប្រាំភាគរយ) ហើយកម្រិតអប្បបរមានៃសោធនទុព្វលភាពត្រូវកំណត់ស្មើនឹង ៤៥% (សែសិបប្រាំភាគរយ) នៃប្រាក់ឈ្នួលមធ្យមដែលសាមីខ្លួនបានបង់ភាគទាន។

### ២. ការគណនាចំនួនប្រាក់សោធនទុព្វលភាព

ម្យ៉ាងវិញទៀតប្រាក់សោធនដែលទទួលបាននូវពេលបាត់បង់សមត្ថភាពការងារដែលមិនបណ្ដាលពីគ្រោះថ្នាក់ការងារត្រូវគណនាជាអនុគមន៍នៃប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទានរបស់សាមីខ្លួនដោយកំណត់បាននូវរូបមន្តដូចខាងក្រោម[42]៖

| តាមរូបមន្ត: | សទ[43] | = | អស [44] x បឈម[45] |
|---|---|---|---|

- **ដើម្បីគណនារកចំនួនប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទាន** ( **បឈម** )

➷ នាំឲ្យប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទាន = $\frac{\text{ប្រាក់ឈ្នួលជាប់ភាគទានដែលបានប្រកាសមក ប.ស.ស}}{\text{១២០ខែ}}$

- **ដើម្បីគណនារកចំនួនអត្រាសោធនដែលទទួលបាន** ( **អស** )

➷ នាំឲ្យ អត្រាសោធនដែលទទួលបាន= $\frac{\text{ចំនួនឆ្នាំដែលសមាជិក ប.ស.ស បានបង់ភាគទានក្នុងផ្នែកសោធន}}{\text{១២ខែ}}$

**ចំណាំ**៖ ក្នុងករណីបើសមាជិកបេឡាជាតិសន្តិសុខសង្គមបានបង់ភាគទានតិចជាង ៣០ឆ្នាំ នោះឆ្នាំភាគទានដែលបានបង់នឹងសន្មត់ថាបានបង់ចំនួន ៣០ឆ្នាំ (សាមសិបឆ្នាំ) ដោយមានអត្រាសោធនស្មើនឹង ៤៥% (សែសិបប្រាំភាគរយ)។

[41] អនុលោមតាម មាត្រា៣២ នៃច្បាប់ស្ដីពីរបបសន្តិសុខសង្គម។
[42] មាត្រា១៤ នៃអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។
[43] សទ គឺជាប្រាក់សោធនទុព្វលភាពរបស់សាមីជនដែលត្រូវទទួលបាន។
[44] អស គឺជាអត្រាសោធនដែលទទួលបាន។
[45]បឈម គឺជាប្រាក់ឈ្នួលមធ្យមដែលសាមីជនបានបង់ភាគទានក្នុងរយៈពេលមិនលើស ១២០ខែ ចុងក្រោយមុនកាលបរិច្ឆេទមានសិទ្ធិទាមទារតាវកាលិក។

**ឧទាហរណ៍៖** លោកស្រី ដាវី បានចាប់ផ្តើមសន្សំក្នុងភាគទាន ប.ស.ស. ផ្នែកប្រាក់សោធន តាំងពីអាយុ២៥ឆ្នាំ ហើយបានបង់ចំនួន១៨០ខែហើយ គិតត្រឹមបច្ចុប្បន្នពេលគាត់បាត់បង់សមត្ថភាពធ្វើការ (ដែលមិនបណ្តាលមកពីគ្រោះថ្នាក់ការងារ)។

ដោយប្រាក់ឈ្នួលជាប់ភាគទានរបស់អ្នកស្រីដាវីបានបង់មក ប.ស.ស (យក១២០ខែចុងក្រោយមុនពេលចូលនិវត្តន៍) របស់គាត់គឺ៖

- ២០០$ ចំនួន៤០ខែ = ៨ ០០០$
- ២៥០$ ចំនួន៤០ខែ = ១០ ០០០$
- ៣០០$ ចំនួន៤០ខែ = ១២ ០០០$

សរុបបង់ក្នុងរយៈពេល ១២០ខែ = ៣០ ០០០$។

**គណនារកចំនួនប្រាក់ទុព្វលភាពរបស់អ្នកស្រី ដាវី**

តាមរូបមន្ត៖ សទ = អស x បឈម

**រកចំនួនអត្រាសោធនដែលទទួលបាន** ( **អស** )

រូបមន្ត៖ អត្រាសោធនដែលទទួលបាន= $\frac{\text{ចំនួនឆ្នាំដែលសមាជិក ប.ស.ស បានបង់ភាគទានក្នុងផ្នែកសោធន}}{\text{១២ខែ}}$

ដោយចំនួនឆ្នាំដែលអ្នកស្រី ដាវីបានបង់ភាគទានស្មើនឹង ១៨០ខែ។

➢ នាំអោយ អត្រាសោធនដែលទទួលបាន = $\frac{១៨០}{១២}$ = ១៥ឆ្នាំ ក្នុងករណីសន្សំក្នុងភាគទានផ្នែកសោធនតិចជាង៣០ឆ្នាំ នោះរដ្ឋជួយបំពេញបង្គ្រប់ ៣០ឆ្នាំតែម្តង នាំអោយអត្រាសោធនស្មើនឹង ៤៥%។

**រកចំនួនប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទាន** ( **បឈម** )

ប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទាន = $\frac{\text{ប្រាក់ឈ្នួលជាប់ភាគទានដែលបានប្រកាសមក ប.ស.ស}}{\text{១២០ខែ}}$

ដោយប្រាក់ឈ្នួលជាប់ភាគទានរបស់អ្នកស្រីដាវីបានបង់មក ប.ស.ស (យក១២០ខែចុងក្រោយមុនពេលចូលនិវត្តន៍) របស់គាត់គឺ៖

- ២០០$ ចំនួន៤០ខែ = ៨ ០០០$
- ២៥០$ ចំនួន៤០ខែ = ១០ ០០០$
- ៣០០$ ចំនួន៤០ខែ = ១២ ០០០$

សរុបបង់ក្នុងរយៈពេល ១២០ខែ = ៣០ ០០០$។

➢ យើងបាន បឈម = $\frac{៣០០០០}{១២០}$ = ២៥០$

សទ = ៤៥ x ២៥០$ = ១១២,៥ $

| |
|---|
| ដូចនេះ លោកស្រី ដារី ទទួលបានប្រាក់សោធនទុព្វលភាពចំនួន ១១២, ៥$/ខែ អស់មួយជីវិត។ |

**គ. សោធនឧត្តរជីវី**

សោធនឧត្តរជីវី សំដៅដល់ប្រាក់សោធនដែលត្រូវផ្តល់ជូនបុគ្គលនៅក្នុងបន្ទុកផ្ទាល់នៃសោធនិកជរាភាព ឬ ទុព្វលភាព ឬសមាជិកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) ដែលបានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិចប្រាំឆ្នាំ ទទួលមរណភាព។

**១. លក្ខខណ្ឌដើម្បីទទួលបានតាវកាលិកផ្នែកប្រាក់សោធនឧត្តរជីវីតាមរបបភាគទានជាភាតព្វកិច្ច**

នៅក្នុងរបបសន្តិសុខសង្គមសិទ្ធិវន្តដែលអាចមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍នៃសោធនឧត្តរជីវីដែលត្រូវផ្តល់ទៅឲ្យបុគ្គលដែលជា សហព័ទ្ធ ឬ កូនរបស់សោធនិកលុះត្រាតែ សោធនិកបានទទួលមរណភាព និងបានធ្វើការបង់ភាគទានយ៉ាងតិច៦០ខែ[46]។

បន្ទាប់ពីសោធនិកបានទទួលមរណភាពក្រោយពីបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់នៃសោធនឧត្តរជីវីដើម្បីទទួលបាននូវតាវកាលិកនោះ សហព័ទ្ធ និងកូននៅក្នុងបន្ទុកនឹងទទួលបាននូវអត្ថប្រយោជន៍ដូចជា៖

- ចំពោះសហព័ទ្ធទទួលបានពាក់កណ្តាលនៃប្រាក់ ៤៥% នៃប្រាក់ចូលនិវត្តន៍
- ចំពោះកូនទទួលបានពាក់កណ្តាលនៃប្រាក់ ៤៥% នៃប្រាក់ចូលនិវត្តន៍
- ក្នុងករណីប្រសិនបើសោធនិកមានតែ ប្តី ឬ ប្រពន្ធ រឺ កូននៅក្នុងបន្ទុកនោះសាមីជនដែលរស់នៅនឹងទទួលបាន ១០០% នៃប្រាក់ ៤៥% នៃប្រាក់ចូលនិវត្តន៍របស់សោធនិក។ ប៉ុន្តែបើសិនកូនមានជម្ងឺរ៉ាំរ៉ៃ ឬ ពិការភាពនោះសាមីជននឹងទទួលបានប្រាក់ចូលនិវត្តន៍អស់ ១ជីវិត។

**២. សិទ្ធិវន្តនៃសោធនឧត្តរជីវី**

គួរកត់សម្គាល់ផងដែរទោះបីជាសាមីជនដែលជាសហព័ទ្ធ ឬ កូនរបស់សោធនិកមានសិទ្ធិទទួលបាននូវតាវកាលិកនៃសោធនឧត្តរជីវីក៏ដោយគឺត្រូវកំណត់នូវគោលការណ៍មួយចំនួនទៀតដើម្បីបញ្ជាក់ពីការទទួលបាននូវសិទ្ធិចំពោះសហព័ទ្ធ ឬ កូន ដែលគោលការណ៍ទាំងនោះមានដូចជា[47]៖

**ចំពោះសហព័ទ្ធ**

- ប្តី ឬ ប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍តម្រូវឲ្យមានសំបុត្រអាពាហ៍ពិពាហ៍ដែលមានកាលបរិច្ឆេទមុនពេលដែលសោធនិកធ្លាក់ខ្លួនឈឺ រឺជួបគ្រោះថ្នាក់ដែលជាយថាហេតុដែលនាំឲ្យកើតមានមរណភាព។

[46] អនុលោមតាម មាត្រា៣៣ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម។

[47] អនុលោមតាម មាត្រា២០ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម។

- សាមីជនមិនមានប្រកបការងារ ឬ មុខរបរដែលបានប្រាក់ចំណូលលើបន្ទាត់ក្រីក្រ។

**ចំពោះកូន**

- សាមីជនដែលជាកូននូវពុំទាន់រៀបអាពាហ៍ពិពាហ៍
- សាមីជនត្រូវមានអាយុលើសមិនលើសពី ១៨ឆ្នាំ (ដប់ប្រាំបីឆ្នាំ) ហើយនៅក្នុងករណីកូនមានពិការភាព រឺមានជម្ងឺរ៉ាំរ៉ៃនឹងត្រូវផ្តល់ប្រាក់សោធនអស់មួយជីវិត។ សូមបញ្ជាក់ផងដែរ ដើម្បីកំណត់ស្ថានភាពពិការភាព ឬមានជំងឺរ៉ាំរ៉ៃតម្រូវអោយមានការបញ្ជាក់ពីក្រុមគ្រូពេទ្យឯកទេស ជាពិសេសត្រូវមានការយល់ព្រមពីក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃបេឡាជាតិសន្តិសុខសង្គម (ប.ស.ស)
- សាមីជនមិនមានប្រកបមុខរបរដែលមានប្រាក់ចំណូលលើបន្ទាត់ភាពក្រីក្រ។

### ៣. ការផុតរលត់នៃសិទ្ធិវន្តនៃឧត្តរជីវី

សិទ្ធិដែលទទួលបាននូវសោធនឧត្តរជីវីនឹងផុតរលត់កាលណា៖

- សិទ្ធិវន្តដែលជាសហព័ទ្ធ ឬ កូន បានទទួលមរណភាព
- សហព័ទ្ធបានរៀបការជាថ្មីស្របតាមនីតិវិធីច្បាប់។ ក្នុងករណីនេះដែរសាមីជនត្រូវជូនដំណឹងមកបេឡា-ជាតិសន្តិសុខសង្គម (ប.ស.ស) យ៉ាងយូរ ៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការរៀបអាពាហ៍ពិពាហ៍សារជាថ្មី។

### ៤. ការគណនាចំនួនប្រាក់សោធនឧត្តរជីវី

នៅក្នុងបេឡាជាតិសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារការគណនាប្រាក់សោធនឧត្តរជីវីដែលផ្តល់ឲ្យមានអត្រាសោធនឧត្តរជីវីអប្បបរមាដែលត្រូវកំណត់ស្មើនឹង ៤៥% (សែសិបប្រាំភាគរយ) នៃប្រាក់សោធនជរាភាព ឬ ទុព្វលភាពរបស់សាមីជន។ ប្រាក់សោធនដែលបានផ្តល់អោយត្រូវគណនាតាមរូបមន្តដូចខាងក្រោម[48]៖

| | | | |
|---|---|---|---|
| តាមរូបមន្ត៖ | សជវ[49] | = | ៤៥% x សជ[50]ឬ ៤៥% x សទ[51] |

**ឧទាហរណ៍**៖ អ្នកស្រីដាវី សន្សំបង់ភាគទាននៃប្រាក់សោធនបានចំនួន៤០០ខែ ដែលមានអត្រា-សោធនស្មើនឹង ៣៣ឆ្នាំ (សាមសិបបីឆ្នាំ) = ៤៨,៧៥% (សែសិបប្រាំបីក្បៀសចិតសិបប្រាំភាគរយ) ដោយនៅ

[48]អនុលោមតាម មាត្រា១៥ នៃអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។

[49] សជវ គឺជាសោធនឧត្តរជីវីដែលសិទ្ធិវន្តទទួលបាន។

[50] សជ គឺជាចំនួនប្រាក់សោធនជរាភាព។

[51] សទ គឺជាចំនួនប្រាក់សោធនទុព្វលភាព

ក្នុងលក្ខខណ្ឌសោធនឧត្តរជីវីតម្រូវឲ្យសាមីជនបង់ភាគទានចំនួន ៦០ខែ (ហុកសិបខែ)។ ចូលរកចំនួនប្រាក់សោធនឧត្តរជីវីរបស់អ្នកស្រីដារី។

**គណនារកចំនួនប្រាក់សោធនឧត្តរជីវីរបស់អ្នកស្រីដារី**

**តាមរូបមន្តៈ** សោធនឧត្តរជីវី = ៤៥% x សោធនជរាភាព ឬ ៤៥% x សោធនទុព្វលភាព

ដោយយោងតាមឧទាហរណ៍ខាងលើការគណនារកចំនួនប្រាក់សោធនជរាភាពរបស់អ្នកស្រីដារីស្មើនឹង ១២១, ៨៨$ ក្នុង១ខែ។

➢ នាំឲ្យសោធនឧត្តរជីវី = 0,៤៥ x ១២១,៨៨ = ៥៤,៨៥$

ដូចនេះប្រាក់សោធនឧត្តរជីវីរបស់អ្នកស្រីដារីមានចំនួន ៥៤,៨៥$ នឹងត្រូវបែងចែកដូចខាងក្រោមៈ

ក្នុងករណីអ្នកស្រីដារីមានទាំងប្តី ឬ កូនក្នុងបន្ទុកដែលនៅរស់នោះប្រាកសោធនឧត្តរជីវីត្រូវបែងចែកពាក់កណ្តាលអោយទៅប្តី និង កូន។

- ដោយប្តីទទួលបានប្រាក់សោធនឧត្តរជីវីចំនួន ២៧,៤ដុល្លារ ក្នុង១ខែ។
- ចំណែកកូនទទួលបានប្រាក់សោធនឧត្តរជីវីចំនួន ២៧,៤ដុល្លារ ក្នុង១ខែផងដែរ។

**ឃ. វិភាជន៍បូជាសព**

វិភាជន៍បូជាសព គឺជាប្រាក់ឧបត្ថម្ភដែលផ្តល់ឲ្យសាមីជនដែលជាសមាជិកនៃបេឡាជាតិសន្តិសុខសង្គមសម្រាប់ចាត់ចែងដល់សោធនិកក្រោយទទួលមរណភាព។ ដោយឡែកសិទ្ធិវន្តនៃសោធនឧត្តរជីវីមានសិទ្ធិទទួលបានអត្ថប្រយោជន៍ពីវិភាជន៍បូជាសពបន្ទាប់ពីសោធនិកជរាភាព រឺ ទុព្វលភាពបានទទួលមរណភាពប៉ុន្តែបើសិនបុគ្គលដែលមិនសិទ្ធិទទួលបានវិភាជន៍បូជាសពមិនបានបំពេញករណីយកិច្ចរបស់ខ្លួននោះសិទ្ធិវន្តនៃវិភា-ជន៍បូជាសពនឹងផ្តល់អោយជនណាដែលជាអ្នកចាត់ចែងបូជាសពសោធនិកដែលបានទទួលមរណភាព។

**១. ការផ្តល់វិភាជន៍បូជាសព**

តាវកាលិកនៃវិភាជន៍បូជាសពដែលត្រូវផ្តល់អោយទៅសិទ្ធិវន្តនៃសោធនិកជរាភាព ឬ សោធនិកទុព្វលភាពត្រូវបានកំណត់ស្មើនឹង ៥(ប្រាំ) ខែចុងក្រោយនៃប្រាក់សោធនជរាភាព រឺ ប្រាក់សោធនទុព្វលភាពរបស់សាមីជនដែលបានទទួលមរណភាពហើយវិភាជន៍ដែលត្រូវផ្តល់ឲ្យសិទ្ធិវន្តមានចំនួនទឹកប្រាក់យ៉ាងតិចស្មើនឹង ២.000.000(ពីរលាន) រៀល[52]។

ប្រសិនបើ សាមីជននៃសោធនជរាភាព ឬ ទុព្វលភាពទទួលមរណភាព ឬ ក៏ក្នុងករណីដែលសមាជិក **ប.ស.ស** ទទួលមរណភាព ហើយដែលនៅក្នុងកាលបរិច្ឆេទនៃមរណភាពនេះ ជននោះ បានបំពេញលក្ខខណ្ឌ

[52]អនុលោមតាម ប្រការ៤ នៃប្រកាសលេខ១៦៩/២២ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០២២ ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់វិភាជន៍បូជាសពនៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។

គ្រប់គ្រាន់ សម្រាប់ការទទួល យកអត្ថប្រយោជន៍ពីសោធនជរាភាព ឬទុព្វលភាព ឬក៏បានបង់ភាគទានចំនួនមួយរយប៉ែតសិប(១៨០)ខែ សម្រាប់របបសន្តិសុខសង្គមរួចហើយកសិទ្ធិវន្តនៃជនទាំងនោះមានសិទ្ធិទទួលបាននូវសោធនចំពោះអ្នកនៅក្នុងបន្ទុក។

តាវកាលិកនៃវិភាជន៍បូជាសពនឹងត្រូវទទួលបានដោយបានកំណត់ជាមួយនឹងលក្ខខណ្ឌដូចជា[53]៖

- សិទ្ធិវន្តត្រូវជូនដំណឹងមកកាន់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស) អំពីមរណភាពរបស់សោធនិកជរាភាព ឬ ទុព្វលភាពក្នុងរយៈពេលយ៉ាងយូរ ២សប្តាហ៍ គិតចាប់ពីថ្ងៃដែលសោធនិកបានទទួលមរណភាព។
- សិទ្ធិវន្តនៃវិភាជន៍បូជាសពដែលចាត់ចែងបូជាសពរបស់សោធនិកជរាភាព ឬសោធនិកទុព្វលភាពត្រូវបំពេញទម្រង់ទាមទារវិភាជន៍បូជាសពក្នុងអំឡុងពេល ៣(បី) ខែបន្ទាប់ពីកាលបរិច្ឆេទទទួលមរណភាពរបស់សោធនិក។
- សិទ្ធិវន្តត្រូវបំពេញទម្រង់ស្នើសុំវិភាជន៍បូជាសពដោយភ្ជាប់មកជាមួយនូវសំបុត្របញ្ជាក់ពីមរណភាព ឬឯកសារដែលទទួលស្គាល់ដោយបេឡាជាតិសន្តិសុខសង្គម។ ទាក់ទិននឹងបញ្ហានេះដែរបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) ត្រូវចេញសេចក្តីសម្រេចផ្តល់វិភាជន៍បូជាសពដល់សិទ្ធិវន្តក្នុងរយៈពេលមិនលើស ២(ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលសិទ្ធិវន្តបានដាក់ពាក្យស្នើសុំ។

[53]អនុលោមតាម មាត្រា១៦ នៃអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ប្រព័ន្ធសន្តិសុខសង្គមជាប្រព័ន្ធសម្រាប់គ្រប់គ្រងកម្មវិធីសន្តិសុខសង្គមដែលរួមបញ្ចូលកម្មវិធីដែលរៀបចំឡើងដើម្បីជួយដល់ប្រជាជនក្នុងការការពារពួកគាត់ពីការធ្លាក់ចុះភ្លាមៗនៃប្រាក់ចំណូលដែលបណ្តាលមកពីជំងឺលំហែមាតុភាព គ្រោះថ្នាក់ការងារ និកម្មភាព ទុព្វលភាព ជរាភាព (ឬចូលនិវត្តន៍) និងមរណភាពនៃអ្នកដែលរកចំណូលសម្រាប់គ្រួសារ។ របបសន្តិសុខសង្គមតម្រូវឲ្យសមាជិករាជរដ្ឋាភិបាលប្រកាន់ខ្ជាប់លើពេលគឺប្រជាជន និង/ឬភាគីពាក់ព័ន្ធបង់ភាគទានជាកាតព្វកិច្ចទៅតាមអត្រាជាក់លាក់។ រាជរដ្ឋាភិបាលប្រកាន់ខ្ជាប់លើគោលការណ៍ផ្តល់ឧបត្ថម្ភជូនដល់ប្រជាជនដែលមិនមានលទ្ធភាពបង់ភាគទានពេលគឺប្រជាជនក្រីក្រ និងងាយរងគ្រោះ។ ប្រព័ន្ធសន្តិសុខសង្គមនៅក្នុងប្រទេសកម្ពុជាមានធាតុផ្សំ ៥ គឺ (១) សោធន(២) ថែទាំសុខភាព (៣) ហានិភ័យការងារ (៤) និកម្មភាព និង (៥) ពិការភាព។ ប្រព័ន្ធសន្តិសុខសង្គម៖ ការដាក់ឲ្យដំណើរការរបបសន្តិសុខសង្គមមួយចំនួន រួមមាន៖ បេឡាជាតិសន្តិសុខសង្គម បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បេឡាជាតិអតីតយុទ្ធជន និង មូលនិធិជនពិការ។ ស្ថាប័នទាំងនេះមានគោលដៅផ្តល់ការគាំពារសន្តិសុខប្រាក់ចំណូល ដែលអាចបណ្តាលមកពីការឈឺថ្កាត់ គ្រោះថ្នាក់ការងារ ពិការភាពមាតុភាព និងចាស់ជរា ជាដើម សម្រាប់ក្រុមគោលដៅមួយចំនួនដូចជា មន្ត្រីរាជការស៊ីវិលអតីតយុទ្ធជន ជនពិការ និងកម្មករនិយោជិត។

របបសន្តិសុខសង្គមផ្នែកប្រាក់សោធន បានរួមចំណែកយ៉ាងសំខាន់បំផុតក្នុងការបង្កើន ស្មារតីទទួលខុសត្រូវខ្ពស់ ខិតខំបំពេញការងារប្រកបដោយស្ថិរភាព និងភាពយូរអង្វែងរបស់ កម្មករនិយោជិត ឈានដល់ការបង្កើតផលិតភាពជូនសហគ្រាស គ្រឹះស្ថានរបស់ខ្លួន។ របបសន្តិសុខសង្គមផ្នែកប្រាក់សោធនថ្មីនេះ គឺឱ្យកម្មករនិយោជិតទាំងអស់ក្នុងវិស័យ ឯកជនទទួលបានប្រាក់ចូលនិវត្តន៍នៅពេលចាស់ធ្វើការលែងកើត ដូចទៅនឹងមន្ត្រីរាជការដែរ។ ការបង្កើតឱ្យមានរបបសន្តិសុខសង្គមផ្នែក ប្រាក់សោធននេះឡើង គឺជាការយកចិត្តទុកដាក់ខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលកម្ពុជា ទៅលើជីវភាពរស់នៅ ក្នុងន័យកាត់បន្ថយភាពក្រីក្រ និងធានានូវសុខុមាលភាពរបស់បងប្អូនប្រជាពលរដ្ឋ ពិសេសបងប្អូនកម្មករនិយោជិត។ ចំពោះការចុះឈ្មោះចូលជាសមាជិក **ប.ស.ស.** ផ្នែកប្រាក់សោធន មិនមែនជាការស្ម័គ្រចិត្តនោះទេ ប៉ុន្តែវាជាកាតព្វកិច្ចរបស់ភាគីនិយោជក និងភាគីនិយោជិតដែលត្រូវអនុវត្តន៍ស្របទៅតាមច្បាប់ស្តីពីរបបសន្តិសុខសង្គម ដែលបានដាក់ចេញដោយ រាជរដ្ឋាភិបាលកម្ពុជា។ ជាមួយគ្នានេះ រដ្ឋាភិបាល ក៏កំពុងរៀបចំគោលការណ៍ប្រាក់សោធននិវត្ត សម្រាប់ពលករដែលកំពុងធ្វើការនៅក្រៅប្រទេស ដើម្បីឲ្យពួកគេទទួលបានអត្ថប្រយោជន៍ ក្រោយពីអស់លទ្ធភាពបំពេញការងារ នាពេលអនាគត។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្លាប់បាននិយាយថា គោលការណ៍សោធនិវត្តន៍ត្រូវបានរដ្ឋាភិបាលកំពុងសហការជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ាន ដើម្បីរៀបចំលើគោលការណ៍រួមនេះ។ បេឡាជាតិសន្តិសុខសង្គម ដែលហៅថា **ប.ស.ស** គឺជា ស្ថាប័ន ប្រតិបត្តិករ តែមួយគត់ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងនិងចាត់ចែង

របបសន្តិសុខសង្គម ផ្នែកប្រាក់សោធន។ បើយោងតាម អនុក្រឹត្យនេះសម្រាប់ រយៈពេល៥ ឆ្នាំ ដំបូង ភាគទាននេះ ត្រូវ កំណត់ ក្នុង អត្រា ស្មើនឹង ៤ភាគរយ នៃប្រាក់ឈ្នួលជាប់ ភាគទាន ។ ក្នុងនោះ ២ភាគ រយ ជាបន្ទុកនិយោជកនិង ២ភាគ រយ ជា បន្ទុក កម្មករនិយោជិត ។ ការបង់ ភាគទានផ្នែកប្រាក់សោធនត្រូវធ្វើជាប្រចាំខែ ឬប្រចាំឆ្នាំ ។ ប្រព័ន្ធសន្តិសុខសង្គមនឹងជំរុញឲ្យប្រជាជនគ្រប់រូបចូលរួមសន្សំប្រាក់ (បង់ភាគទាន) នៅក្នុងមូលនិធិរួមមួយ ដើម្បីការពារហានិភ័យពីការធ្លាក់ចូលក្នុងភាពក្រីក្រនៅពេលចាស់ជរា និងនៅពេលមានតម្រូវការសេវាថែទាំសុខភាព ព្រមទាំង ហានិភ័យផ្សេងៗទៀត។ ចំពោះក្រុមប្រជាជនក្រីក្រនិងងាយរងគ្រោះដែលគ្មានលទ្ធភាពបង់ភាគទាន រាជរដ្ឋាភិបាលនឹងពិនិត្យលទ្ធភាពក្នុងការបង់ភាគទានជំនួស។ យន្តការគៀរគរភាគទាននៅក្នុងប្រព័ន្ធសន្តិសុខសង្គម និងបង្កើតជាប្រភពហិរញ្ញវត្ថុក្នុងស្រុកសម្រាប់ការវិនិយោគទៅលើមូលបត្ររដ្ឋ ដែលទុកលទ្ធភាពឲ្យរាជរដ្ឋាភិបាលអាចយកប្រភពហិរញ្ញវត្ថុនេះទៅធ្វើការវិនិយោគសាធារណៈបាន។ យន្តការនេះ គឺជាមធ្យោបាយដ៏ប្រសើរ ក្នុងការដកខ្លួនចេញពីការពឹងផ្អែកទាំងស្រុងលើហិរញ្ញប្បទានក្រៅប្រទេស ព្រមទាំងជួយជំរុញការអភិវឌ្ឍទីផ្សារទុនក្នុងស្រុកផងដែរ។

ក្រៅពី **ប.ស.ស** ក៏មានស្ថាប័ន ផ្សេងទៀតដូចជានិយ័តកររបបសន្តិសុខសង្គម និងក្រុមប្រឹក្សាជាតិគាំពារសង្គម ដែលរួមចំណែកយ៉ាងសំខាន់ក្នុងធ្វើឲ្យរបបសោធន មានចីរភាព និងដំណើរការទៅដោយរលូន។ ដែលក្រុមប្រឹក្សាជាតិគាំពារសង្គម មានមុខងារសម្របសម្រួលការរៀបចំគោលនយោបាយអភិវឌ្ឍន៍ប្រព័ន្ធគាំពារសង្គមរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ឲ្យមានលក្ខណៈជាគោលនយោបាយរួមដើម្បីដាក់ស្នើសុំការអនុម័តពីប្រមុខរាជរដ្ឋាភិបាល ពិនិត្យ និងតាមដានលើវឌ្ឍនភាព និងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយគាំពារសង្គម ដើម្បីជំរុញឲ្យការអនុវត្តប្រព្រឹត្តទៅដោយរលូនមានសង្គតិភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព និងផ្សារភ្ជាប់ និងបន្សាំប្រព័ន្ធជំនួយសង្គមជាមួយនឹងប្រព័ន្ធសន្តិសុខសង្គម ដើម្បីធានាសង្គតិភាព និងបំពេញបន្ថែមសកម្មភាពចាំបាច់ នៅក្នុងចក្ខុវិស័យរួមនៃប្រព័ន្ធគាំពារសង្គម និងផ្តល់លទ្ធភាពសម្រាប់ការផ្ទេរក្រុមគោលដៅពីប្រព័ន្ធមួយទៅប្រព័ន្ធមួយទៀតនៅពេលដែលឱកាសផ្តល់ឲ្យ។ ក្នុងនោះនិយ័តករសន្តិសុខសង្គមមានសារៈសំខាន់ណាស់ក្នុងការធានាថាកិច្ចដំណើរការគ្រប់គ្រងនិងការចាត់ចែងក្នុងរបបសន្តិសុខសង្គមនានាត្រូវ អនុវត្តដោយភាពត្រឹមត្រូវ តម្លាភាព និងគណនេយ្យភាពចំពោះសាធារណៈជន ជាពិសេសនិយោជិត និងនិយោជកដែលបានបង់ភាគទានរួមគ្នា។

# អនុសាសន៍

# អនុសាសន៍

ផ្អែកតាមការបកស្រាយសិក្សាស្រាវជ្រាវប្រធានបទនេះរួចមក យើងអាចសន្និដ្ឋានបានថានៅក្នុងសង្គមជាក់ស្តែង ទោះបីជាមានច្បាប់ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនក្នុងវិស័យសាធារណៈដែលបានចូលជាធរមានជាយូរមកហើយក៏ដោយ ប៉ុន្តែរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់វិស័យឯកជនទើបតែមាននៅក្នុងឆ្នាំ ២០២២ នេះប៉ុណ្ណោះ។ ហើយកម្មករនិយោជិតភាគច្រើនពុំទាន់មានការយល់ដឹងច្បាស់លាស់អំពីអត្ថប្រយោជន៍នៃប្រាក់សោធន និងពីរបៀបនៃការទទួលបាននូវតាវកាលិកទាំងអស់នេះបន្ទាប់ពីពួកគាត់ដល់អាយុដែលត្រូវចូលនិវត្តន៍ពីការងារ ឬ បាត់បង់សមត្ថភាពការងារដែលមិនបណ្តាលមកពីគ្រោះថ្នាក់ការងារ ពោលគឺកម្មករនិយោជិតទាំងអស់ភាគច្រើនចុះកិច្ចសន្យាការងារជាមួយនឹងនិយោជកដែលមានគោលបំណងចម្បង គឺពួកគាត់ទទួលបានការងារធ្វើដោយពួកគាត់ពុំបានផ្តោតទៅលើសោធនដែលពួកគាត់នឹងទទួលបាន បន្ទាប់ពីចូលនិវត្តន៍ពីការងារ និងការបង់ភាគទានចូលមកបេឡាជាតិសន្តិសុខសង្គម ( ប.ស.ស )។ ហេតុផលនេះពួកគាត់ដែលជាកម្មករនិយោជិតនៅពេលដល់អាយុចូលនិវត្តន៍ និងមានសុខភាពចុះខ្សោយដែលនាំអោយមិនអាចប្រកបរបរ ឬ ធ្វើការពេញលេញដើម្បីរកប្រាក់ចំណូលបន្ថែមដែលធ្វើឲ្យកម្មករនិយោជិតទាំងអស់ អាចធ្លាក់ចូលក្រោមបន្ទាត់ភាពក្រីក្រព្រមទាំងពុំបានទទួលបានសេវាថែទាំសុខភាពពី ប.ស.ស ថែមទៀតផង។

ជុំវិញបញ្ហានេះដែរ រាជរដ្ឋាភិបាល និង ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈគប្បីគួរផ្សព្វផ្សាយអំពីរបបសោធនដែលទើបតែដាក់បញ្ចូលនៅក្នុងវិស័យឯកជនឲ្យបានទូលំទូលាយដើម្បីផ្តល់ព័ត៌មាន និងចំណេះដឹងដល់និយោជក និងកម្មករនិយោជិតដើម្បីអោយពួកគាត់បានយល់ដឹងកាន់តែច្បាស់អំពីសារប្រយោជន៍នៃរបបសោធនដែលមិនបណ្តាលឲ្យពួកគាត់ខាតបង់នូវអត្ថប្រយោជន៍ទាំងអស់នេះនៅពេលចូលនិវត្តន៍។

ស្របគ្នានេះដែរ រាជរដ្ឋាភិបាលគួរតែផ្តល់ការអប់រំដោយឥតគិតថ្លៃជូនទៅដល់កម្មករនិយោជិត និងសាធារណជនទាំងឡាយអំពីរបបសោធនដែលមាននៅក្នុងប្រទេសកម្ពុជាដើម្បីពង្រឹង និងព្រមទាំងជួយដល់ការអភិវឌ្ឍធនធានមនុស្សឲ្យកាន់តែមានភាពប្រសើរឡើងដើម្បីអោយមានភាពងាយស្រួលនៅពេលដែលពួកគាត់ចូលនិវត្តន៍នាពេលអនាគត។ ជាពិសេសពង្រីកការផ្សព្វផ្សាយចំពោះការទទួលបានផ្នែកថែទាំសុខភាពពីបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) ដើម្បីឲ្យពួកគាត់ទទួលបានការព្យាបាលដោយឥតគិតថ្លៃនៅពេលដែលពួកគាត់មានបញ្ហាសុខភាព ឬ ជួបគ្រោះថ្នាក់ណាមួយដោយចៃដន្យ។

ជាការពិតណាស់ បើរាជរដ្ឋាភិបាលអនុវត្តចំណុចនេះបាន នោះពលរដ្ឋកម្ពុជា និងមានសង្ឃឹមថាអ្នកដឹកនាំនឹងដឹកនាំប្រទេសកម្ពុជាឆ្ពោះទៅរកភាពរីកចម្រើន និងការអភិវឌ្ឍដែលអាចជួយសម្រួលដល់បន្ទុកកម្មករនិយោជិតទាំងឡាយនៅពេលពួកគាត់ចូលនិវត្តន៍ ដើម្បីឲ្យពួកគាត់ជៀសផុតពីបន្ទាត់ក្រីក្រនាពេលអនាគត។

# ឯកសារយោង

# ឯកសារយោង

## ក. លិខិតបទដ្ឋានគតិយុត្ត

១. ច្បាប់ស្តីពីរបបសន្តិសុខសង្គម។

២. អនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ ២០២១ ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញាតិនៃច្បាប់ស្តីពីការងារ។

៣. អនុក្រឹត្យលេខ១៦០ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ ២០២១ ស្តីពីនិយ័តកម្មប្រព័ន្ធសន្តិសុខសង្គមរាជរដ្ឋាភិបាល។

៤. ប្រកាសលេខ១៦២/២២ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២២ ស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងការបង់ភាគទានសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញាតិស្តីពីការងារក្នុងបេឡាជាតិសន្តិសិខសង្គម។

៥. ប្រកាសលេខ១៦២/២២ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២២ ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់វិភាជន៍បូជាសពនៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញាតិនៃច្បាប់ស្តីពីការងារ។

៦. ប្រកាសលេខ ០២១/០៨ ក.ប.ក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៤ ស្តីពីបញ្ជិកាសហគ្រាសគ្រឹះស្ថាន និងកម្មករនយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។

## ខ. ឯកសារជាសៀវភៅ

១. ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ ២០១៦ ដល់ ២០២៥។

## គ. ព័ត៌មានតាមរយៈគេហទំព័រ

១. https://nspc.gov.kh/social-security-cambodia ។

២. http://www.nssf.gov.kh/ ។

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១. នៃប្រកាសលេខ: ១៦៨/២២ ក.ប/ប្រ.ក.ប.ស.ស. ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២២ ស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងការបង់ភាគទាន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងបេឡាជាតិសន្តិសុខសង្គម

**ទម្រង់ ១.០១**

# បញ្ជិកាសហគ្រាស គ្រឹះស្ថាន

| **សម្រាប់មន្ត្រី ប.ស.ស.** |
|---|
| **លេខអត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន:** ☐☐☐☐☐☐☐☐ |
| **ហត្ថលេខា:**............................ / / |

**១.** ឈ្មោះសហគ្រាស គ្រឹះស្ថាន:..................................................

ឈ្មោះជាអក្សរឡាតាំង:..................................................

**២.** អាសយដ្ឋានទីស្នាក់ការកណ្តាល:អគារ/ផ្ទះលេខ....................ផ្លូវ....................ភូមិ....................ឃុំ/សង្កាត់....................

ស្រុក/ខណ្ឌ/ក្រុង..............................រាជធានី/ខេត្ត..............................លេខទូរស័ព្ទ: ☐☐☐☐☐☐☐☐☐☐

លេខទូរសារ: ☐☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិក:..................................................

**៣.** អាសយដ្ឋាននៃកន្លែងធ្វើការងារ:អគារ/ផ្ទះលេខ....................ផ្លូវ....................ភូមិ....................ឃុំ/សង្កាត់....................

ស្រុក/ខណ្ឌ/ក្រុង..............................រាជធានី/ខេត្ត..............................លេខទូរស័ព្ទ: ☐☐☐☐☐☐☐☐☐☐

លេខទូរសារ: ☐☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិក:..................................................

(ប្រសិនបើអាសយដ្ឋានកន្លែងធ្វើការដូចគ្នាជាមួយនឹងអាសយដ្ឋានទីស្នាក់ការកណ្តាល ចំណុចលេខ ៣ នេះពុំចាំបាច់ត្រូវបំពេញទេ)

**៤.** លេខបញ្ជីពាណិជ្ជកម្ម: ☐☐☐☐☐☐☐☐☐☐☐☐ ប្រភេទសហគ្រាស គ្រឹះស្ថាន: ☐☐☐☐ **(សម្រាប់មន្ត្រី ប.ស.ស.)**

កាលបរិច្ឆេទបើកសហគ្រាស គ្រឹះស្ថាន: ........../........../.......... ចំនួនកម្មករនិយោជិតចុះបញ្ជីដំបូង:....................នាក់/ស្រី..............នាក់

**៥.** ឈ្មោះនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន:..............................................ភេទ:..............សញ្ជាតិ:....................

ឈ្មោះជាអក្សរឡាតាំង:..................................................

អត្តសញ្ញាណប័ណ្ណលេខ ឬលិខិតឆ្លងដែនលេខ:..................................................

អាសយដ្ឋានអចិន្ត្រៃយ៍:អគារ/ផ្ទះលេខ....................ផ្លូវ....................ភូមិ....................ឃុំ/សង្កាត់....................

ស្រុក/ខណ្ឌ/ក្រុង..............................រាជធានី/ខេត្ត..............................លេខទូរស័ព្ទ: ☐☐☐☐☐☐☐☐☐☐

លេខទូរសារ: ☐☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិក:..................................................

**៦.** ឈ្មោះអ្នកគ្រប់គ្រង ឬអ្នកតំណាងនិយោជក:..............................................ភេទ:..............សញ្ជាតិ:....................

ឈ្មោះជាអក្សរឡាតាំង:..................................................

អត្តសញ្ញាណប័ណ្ណលេខ ឬលិខិតឆ្លងដែនលេខ:..................................................

អាសយដ្ឋានអចិន្ត្រៃយ៍:អគារ/ផ្ទះលេខ....................ផ្លូវ....................ភូមិ....................ឃុំ/សង្កាត់....................

ស្រុក/ខណ្ឌ/ក្រុង..............................រាជធានី/ខេត្ត..............................លេខទូរស័ព្ទ: ☐☐☐☐☐☐☐☐☐☐

លេខទូរសារ: ☐☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិក:..................................................

ខ្ញុំសូមសន្យាថា រាល់ព័ត៌មានដែលផ្តល់ជូនខាងលើ ពិតជាត្រឹមត្រូវប្រាកដមែន។

....................ថ្ងៃទី..........ខែ..............ឆ្នាំ..............

**ហត្ថលេខា និងត្រានិយោជក**

| **ឯកសារថតចម្លងភ្ជាប់មកជាមួយ:** |
|---|
| - បញ្ជីពាណិជ្ជកម្ម |
| - ប័ណ្ណប៉ាតង់ |
| - លិខិតគូបករណ៍គតិយុត្តសមមូល |
| - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់និយោជក និងអ្នកតំណាងនិយោជក |
| - សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅរបស់និយោជក |

ឧបសម្ព័ន្ធ២. នៃប្រកាសលេខ: ១៦៨/២២ ក.ប/ប្រ.ក.ប.ស.ស. ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២២ ស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និង ការបង់ភាគទាន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងបេឡាជាតិសន្តិសុខសង្គម

**ទម្រង់ ១.០២**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សលាកប័ត្រព័ត៌មានសមាជិក ប.ស.ស.

លេខ៖ ..............................

**លេខអត្តសញ្ញាណសមាជិក ប.ស.ស.**

☐☐☐☐☐☐☐ - ☐☐☐☐☐☐☐ - ☐

## ក- ព័ត៌មានផ្ទាល់ខ្លួន

១- គោត្តនាម...................... នាម........................................ ជាអក្សរឡាតាំង..........................................................................

ភេទ......... សញ្ជាតិ.................... ថ្ងៃខែឆ្នាំកំណើត ......../........../........... អត្តសញ្ញាណប័ណ្ណលេខ.................................

២- ទីកន្លែងកំណើត ផ្ទះលេខ.............. ផ្លូវ................... ភូមិ/ក្រុម............................. ឃុំ/សង្កាត់...........................................

ស្រុក/ខណ្ឌ/ក្រុង.............................................. ខេត្ត/រាជធានី............................................................................................

៣- អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ............... ផ្លូវ.................. ភូមិ/ក្រុម........................... ឃុំ/សង្កាត់.................................

ស្រុក/ខណ្ឌ/ក្រុង................................ ខេត្ត/រាជធានី..................................... លេខទូរស័ព្ទ:......................................

## ខ- ព័ត៌មានការងារ

៤- សហគ្រាស គ្រឹះស្ថាន.................................................................. លេខអត្តសញ្ញាណស.ហ ☐☐☐☐☐☐☐☐

៥- មុខងារ...................................................... ប្រាក់ឈ្នួល......................... កាលបរិច្ឆេទចូលធ្វើការ........./........../..........

## គ- ព័ត៌មានគ្រួសារ

៦- ☐ នៅលីវ ☐ រៀបអាពាហ៍ពិពាហ៍ ☐ មេម៉ាយ/ពោះម៉ាយ

៧- គោត្តនាម-នាម.......................................................... សញ្ជាតិ...................... ថ្ងៃខែឆ្នាំកំណើត........./........../...........

មុខរបរសព្វថ្ងៃ.............................................................................................................................................

៨- អំពីកូន...........នាក់

១. គោត្តនាម-នាម ....................................... ភេទ....... កើតនៅថ្ងៃទី.......ខែ ....... ឆ្នាំ........... មុខរបរ ........................

២. គោត្តនាម-នាម ....................................... ភេទ....... កើតនៅថ្ងៃទី.......ខែ ....... ឆ្នាំ........... មុខរបរ ........................

៣. គោត្តនាម-នាម ....................................... ភេទ....... កើតនៅថ្ងៃទី.......ខែ ....... ឆ្នាំ........... មុខរបរ ........................

៤. គោត្តនាម-នាម ....................................... ភេទ....... កើតនៅថ្ងៃទី.......ខែ ....... ឆ្នាំ........... មុខរបរ ........................

ខ្ញុំបាទ/នាងខ្ញុំ សូមធានាទទួលខុសត្រូវចំពោះមុខច្បាប់ថា ព័ត៌មានបំពេញខាងលើនេះពិតជាត្រឹមត្រូវប្រាកដមែន ។

ធ្វើនៅ.............ថ្ងៃទី.........ខែ.............ឆ្នាំ២០...

**ស្នាមមេដៃស្តាំសាមីខ្លួន**

ធ្វើនៅ............ថ្ងៃទី..........ខែ...........ឆ្នាំ២០...

**ហត្ថលេខា និងឈ្មោះមន្ត្រីពិនិត្យ**

**ឯកសារដែលត្រូវភ្ជាប់ជាមួយ:**
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- លិខិតឆ្លងដែន
- លិខិតបញ្ជាក់ការងារពីនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន

ឧបសម្ព័ន្ធ៣. នៃប្រកាសលេខ ១១៨/២២ ក.ប/ប្រ.ក.ប.ស.ស. ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២២ ស្តីពីនីតិវិធីនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងការបង់ភាគទាន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងរបបសន្តិសុខសង្គម

**ទម្រង់ ១.០៣**

# របាយការណ៍កម្មករនិយោជិត

១. ឈ្មោះសហគ្រាស គ្រឹះស្ថាន:............................................................ ២. លេខអត្តសញ្ញាណសហគ្រាស: ☐☐☐☐☐☐☐☐

៣. ឈ្មោះសហគ្រាសជាអក្សរឡាតាំង:............................................................

| ល.រ | លេខអត្តសញ្ញាណសមាជិក ប.ស.ស. | លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | គោត្តនាម | នាម | ភេទ | ស្ថានភាព | ថ្ងៃខែឆ្នាំកំណើត | សញ្ជាតិ | ប្រាក់ឈ្នួល (រៀល) | ភាគទានផ្នែកហានិភ័យការងារ | ភាគទានផ្នែកថែទាំសុខភាព | ភាគទានផ្នែកប្រាក់សោធន | ភាគទានសរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |

ខ្ញុំសូមប្រកាសថាព័ត៌មានដែលផ្តល់ជូនខាងលើ ពិតជាត្រឹមត្រូវប្រាកដមែន។

..................ថ្ងៃទី..........ខែ..........ឆ្នាំ...........

**ហត្ថលេខា និងត្រានិយោជក**

ឧបសម្ព័ន្ធ ២. នៃប្រកាសលេខៈ ៤៤៩ កប/ប្រក ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងរបបជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ១.០២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ៖ ............................

## សលាកប័ត្រព័ត៌មាន
## កម្មករនិយោជិត

លេខអត្តសញ្ញាណប.ស.ស ☐☐☐☐☐☐☐ - ☐☐☐☐☐☐☐ - ☐

### ក- ព័ត៌មានផ្ទាល់ខ្លួន

១- គោត្តនាម........................ នាម .................................. ជាអក្សរឡាតាំង ..................................................

២- ភេទ......... សញ្ជាតិ................... ថ្ងៃខែឆ្នាំកំណើត ......./........./.......... អត្តសញ្ញាណប័ណ្ណលេខ...............................

៣- ទីកន្លែងកំណើត ផ្ទះលេខ............. ផ្លូវ.................. ភូមិ/ក្រុម............................ ឃុំ/សង្កាត់.......................................
ស្រុក/ខណ្ឌ/ក្រុង ............................................ ខេត្ត/រាជធានី ...................................................................

៤- អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ...............ផ្លូវ .................. ភូមិ/ក្រុម.......................... ឃុំ/សង្កាត់...............................
ស្រុក/ខណ្ឌ/ក្រុង ...............................ខេត្ត/រាជធានី ....................................លេខទូរស័ព្ទ:.....................................

### ខ- ព័ត៌មានការងារ

៥- ឈ្មោះសហគ្រាស.........................................................................លេខអត្តសញ្ញាណស.ហ.......................................

៦- លេខអត្តសញ្ញាណ ប.ស.ស ចាស់..........................................លេខអត្តសញ្ញាណ នៅស.ហ.................................

៧- មុខងារ .................................................. ប្រាក់ឈ្នួល ....................... កាលបរិច្ឆេទចូលធ្វើការ........./........./..........

### គ- ព័ត៌មានគ្រួសារ

៨- ☐ នៅលីវ ☐ រៀបអាពាហ៍ពិពាហ៍ ☐ មេម៉ាយ/ពោះម៉ាយ

៩- ប្រពន្ធ ឬប្តីឈ្មោះ....................................................... សញ្ជាតិ...................... ថ្ងៃខែឆ្នាំកំណើត........./........./..........
មុខរបរសព្វថ្ងៃ .........................................................................................................................

១០-អំពីកូន...........នាក់

១. ឈ្មោះ ...................................... ភេទ........ កើតនៅថ្ងៃទី.......ខែ ....... ឆ្នាំ.......... មុខរបរ ....................................

២. ឈ្មោះ ...................................... ភេទ........ កើតនៅថ្ងៃទី.......ខែ ....... ឆ្នាំ.......... មុខរបរ ....................................

៣. ឈ្មោះ ...................................... ភេទ........ កើតនៅថ្ងៃទី.......ខែ ....... ឆ្នាំ.......... មុខរបរ ....................................

| មេដៃខាងឆ្វេង | មេដៃខាងស្តាំ |
| --- | --- |

ខ្ញុំបាទ/នាងខ្ញុំ សូមធានាទទួលខុសត្រូវចំពោះមុខច្បាប់ថា ព័ត៌មានបំពេញខាងលើនេះពិតជាត្រឹមត្រូវប្រាកដមែន ។

ធ្វើនៅ...............ថ្ងៃទី.......ខែ..........ឆ្នាំ២០...

ធ្វើនៅ............ ថ្ងៃទី..........ខែ........... ឆ្នាំ២០...

**ហត្ថលេខា និង ឈ្មោះមន្ត្រីពិនិត្យ**

**ហត្ថលេខា ឬស្នាមម្រាមដៃសាមីខ្លួន**

**ឯកសារភ្ជាប់**
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- លិខិតឆ្លងដែន

ឧបសម្ព័ន្ធ ១. នៃប្រកាសលេខ:...២៤៨...ក.ប/ប្រ.ក ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ១.០១

# បញ្ជិកាសហគ្រាស គ្រឹះស្ថាន

| សម្រាប់មន្ត្រី ប.ស.ស | |
|---|---|
| លេខអត្តសញ្ញាណសហគ្រាសគ្រឹះស្ថាន: | ☐☐☐☐☐☐☐☐ |
| ហត្ថលេខា:........................ | / / |

១. ឈ្មោះសហគ្រាស គ្រឹះស្ថាន:.........................................................................

ឈ្មោះជាអក្សរឡាតាំង:.........................................................................

២. អាសយដ្ឋានទីស្នាក់ការកណ្តាល:អគារលេខ............ផ្លូវ............ឃុំ/សង្កាត់............................ស្រុក/ខណ្ឌ/ក្រុង.....................រាជធានី/ខេត្ត..................

ទូរស័ព្ទ: ☐☐☐☐☐☐☐☐☐☐ ទូរសារ: ☐☐☐☐☐☐☐☐☐☐ សារអេឡិកត្រូនិក:....................................

៣. អាសយដ្ឋានកន្លែងធ្វើការងារ: អគារលេខ............ផ្លូវ............ឃុំ/សង្កាត់.........................ស្រុក/ខណ្ឌ/ក្រុង.........................រាជធានី/ខេត្ត..................

ទូរស័ព្ទ: ☐☐☐☐☐☐☐☐☐☐ ទូរសារ: ☐☐☐☐☐☐☐☐☐☐ សារអេឡិកត្រូនិក:....................................

(ប្រសិនបើអាសយដ្ឋានកន្លែងធ្វើការដូចគ្នាជាមួយនឹងអាសយដ្ឋានទីស្នាក់ការកណ្តាល ចំណុចលេខ ៣ នេះពុំចាំបាច់ត្រូវបំពេញទេ)

៤. លេខបញ្ជិកាពាណិជ្ជកម្ម: ☐☐☐☐☐☐☐☐☐☐☐☐☐ ប្រភេទសហគ្រាស គ្រឹះស្ថាន: ☐☐☐☐ **(សម្រាប់មន្ត្រី ប.ស.ស)**

កាលបរិច្ឆេទបើកសហគ្រាស គ្រឹះស្ថាន:......../............/.............កាលបរិច្ឆេទមានកម្មករចាប់ពី ០១នាក់ ឡើង:............/.............../...............

៥. ឈ្មោះនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន:.........................................................ភេទ:..............សញ្ជាតិ:......................

ឈ្មោះជាអក្សរឡាតាំង:.........................................................................

អត្តសញ្ញាណប័ណ្ណលេខ ឬលិខិតឆ្លងដែនលេខ:.........................................................................

អាសយដ្ឋានអចិន្ត្រៃយ៍:អគារលេខ............ផ្លូវ............ឃុំ/សង្កាត់.........................ស្រុក/ខណ្ឌ/ក្រុង.........................រាជធានី/ខេត្ត..........................

ទូរស័ព្ទ: ☐☐☐☐☐☐☐☐☐☐ ទូរសារ: ☐☐☐☐☐☐☐☐☐☐ សារអេឡិកត្រូនិក:....................................

៦. ឈ្មោះអ្នកគ្រប់គ្រង/អ្នកតំណាងនិយោជក:.........................................................ភេទ:..............សញ្ជាតិ:......................

ឈ្មោះជាអក្សរឡាតាំង:.........................................................................

អត្តសញ្ញាណប័ណ្ណលេខ ឬលិខិតឆ្លងដែនលេខ:.........................................................................

អាសយដ្ឋានអចិន្ត្រៃយ៍:អគារលេខ............ផ្លូវ............ឃុំ/សង្កាត់.........................ស្រុក/ខណ្ឌ/ក្រុង.........................រាជធានី/ខេត្ត..........................

ទូរស័ព្ទ: ☐☐☐☐☐☐☐☐☐☐ ទូរសារ: ☐☐☐☐☐☐☐☐☐☐ សារអេឡិកត្រូនិក:....................................

ខ្ញុំសូមសន្យាថា រាល់ព័ត៌មានដែលផ្តល់ជូនខាងលើ ពិតជាត្រឹមត្រូវប្រាកដមែន ។

....................ថ្ងៃទី..........ខែ.............ឆ្នាំ...............

**ហត្ថលេខា និងត្រានាយក**

ឯកសារត្រូវយកភ្ជាប់មកជាមួយ:
- បញ្ជិកាពាណិជ្ជកម្ម
- ប័ណ្ណប៉ាតង់
- របាយការណ៍ប្រើប្រាស់កម្មករនិយោជិត
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់និយោជក និងអ្នកតំណាង

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៣២ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលនាំខឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៦១៧/៨៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៨៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៩៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែវិច្ឆិកា ឆ្នាំ២០២០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃបេឡាជាតិសន្តិសុខសង្គម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ --**

អនុក្រឹត្យនេះមានគោលបំណងដាក់ឲ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ តាមរយៈការកំណត់យន្តការ លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការចុះបញ្ជី ការបង់ភាគទាន អត្រាភាគទាន អត្រាសមាច័យ ការទាមទារ និងការផ្ដល់តាវកាលិក។

**មាត្រា២ --**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ ដោយរាប់បញ្ចូលទាំងបុគ្គលដែលធ្វើការចាប់ពី២(ពីរ)កន្លែងឡើងទៅ។

**មាត្រា៣ --**

វាក្យសព្ទបច្ចេកទេសដែលប្រើនៅក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

| | |
|---|---|
| កម្មករនិយោជិត | សំដៅដល់កម្មករនិយោជិតគ្រប់ប្រភេទនិងគ្រប់សញ្ជាតិនៃវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដែលរួមមានបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ។ |
| ប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទាន | សំដៅដល់ផលចែកមធ្យមភាគនៃប្រាក់ឈ្នួលជាប់ភាគទានក្នុងរយៈពេលមិនលើសពី១២០(មួយរយម្ភៃ)ខែចុងក្រោយមុនកាលបរិច្ឆេទមានសិទ្ធិទាមទារតាវកាលិកផ្នែកប្រាក់សោធន។ |
| ប្រាក់ឈ្នួលជាប់ភាគទាន | សំដៅដល់ប្រាក់ឈ្នួលមុនកាត់ពន្ធរបស់កម្មករនិយោជិតដែលត្រូវយកមកគណនាសម្រាប់ការបង់ភាគទាន។ |
| ប្រាក់ស្នើសុំជាប់ភាគទាន | សំដៅដល់ប្រាក់ដែលសមាជិក **ប.ស.ស.** បានស្នើសុំសម្រាប់ការគណនាភាគទានផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត។ |
| ភាគទានផ្នែកប្រាក់សោធន | សំដៅដល់ប្រាក់ដែលសមាជិក **ប.ស.ស.** និងនិយោជកបានបង់មក **ប.ស.ស.** ដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ដែលជាទូទៅគិតជាភាគរយនៃប្រាក់ឈ្នួលរបស់សមាជិកម្នាក់ៗ ទុកសម្រាប់ការចំណាយក្នុងការផ្ដល់តាវកាលិកដល់សមាជិក និងការចំណាយប្រតិបត្តិការនៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន។ |
| មត៌ក | ទ្រព្យសម្បត្តិជាកេរទាំងឡាយដែលបុគ្គលម្នាក់(មតកជន)បានបន្សល់ទុកក្រោយពេលស្លាប់។ |

| | |
|---|---|
| មតកជន | ជនដែលបានស្លាប់ទៅហើយ។ មតកជនក្នុងអនុក្រឹត្យនេះ សំដៅដល់សោធននិវត្តជន ពិការភាព ទុព្វលភាព ឬសមាជិក **ម.ស.ស.** ទទួលមរណភាព។ |
| របបសន្តិសុខសង្គមផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត | សំដៅដល់របបសន្តិសុខសង្គមផ្នែកសោធនដែលសមាជិកជាប់កាតព្វកិច្ចក្នុងរបបភាគទានកាតព្វកិច្ចស្ម័គ្រចិត្តបង់ក្នុងករណី៖<br>១) សមាជិក **ម.ស.ស.** ដែលបាត់បង់ការងារដែលមានប្រាក់ឈ្នួលមុនអាយុ៦០(ហុកសិប)ឆ្នាំ និងមានលទ្ធភាពបន្ត។<br>២) សមាជិក **ម.ស.ស.** ដែលមានអាយុ៦០(ហុកសិប)ឆ្នាំ និងមានបំណងបង់ភាគទានបន្តដើម្បីទទួលបានសោធននិវត្តន៍ខ្ពស់ជាងសោធននិវត្តន៍ជាក់ស្តែង ដែលសាមីជនត្រូវទទួលបានតាមរបបភាគទានជាកាតព្វកិច្ច។<br>៣) សមាជិក **ម.ស.ស.** ដែលមានប្រាក់ចំណូលខ្ពស់ជាងប្រាក់ឈ្នួលពិតាន ដែលសាមីជនជាប់កាតព្វកិច្ចក្នុងរបបភាគទានជាកាតព្វកិច្ច និងដែលការបង់ភាគទានក្នុងផ្នែកនេះត្រូវអនុវត្តចំពោះតែចំណែកនៃប្រាក់ឈ្នួលដែលខ្ពស់ជាងប្រាក់ឈ្នួលពិតានតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញក្នុង **ម.ស.ស.** ឬអាចចូលរួមជាមួយប្រតិបត្តិករផ្សេង។ |
| វិភាជន៍ជរាភាព | សំដៅដល់ប្រាក់ឧបត្ថម្ភដែលបើកផ្តល់ជូនដល់សមាជិក **ម.ស.ស.** តែម្តងគត់ នៅពេលសាមីជនមិនបានបំពេញលក្ខខណ្ឌទទួលបានសោធនជរាភាព។ |
| សន្តតិជន | សំដៅដល់ជនដែលទទួលបន្តនូវសិទ្ធិនិងករណីយកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម ដែលមានចែងនៅក្នុងទម្រង់នៃការស្នើសុំចូលរួមដោយស្ម័គ្រចិត្តតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញ។ |
| សន្តតិកម្ម | ការផ្ទេរនូវសិទ្ធិនិងករណីយកិច្ចរបស់មតកជនទៅឲ្យសន្តតិជនម្នាក់ឬច្រើននាក់តាមឆន្ទៈ ដែលមានកំណត់ក្នុងអនុក្រឹត្យនេះ។ |
| អវសិដ្ឋ | ភាពកាលិកដែលឧកទានមិនបានទាមទារក្នុងករណីប្រធានសក្តិ។ |

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤ --**

បេឡាជាតិសន្តិសុខសង្គម ដែលហៅកាត់ថា **ម.ស.ស.** គឺជាស្ថាប័នប្រតិបត្តិករតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងនិងចាត់ចែងរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនដូចមានចែងនៅក្នុងអនុក្រឹត្យនេះ។

## ជំពូកទី៣
## លក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីក្នុងរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច

**មាត្រា៥ .-**

និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលប្រើប្រាស់កម្មករនិយោជិតចាប់ពី១(មួយ)នាក់ឡើង ត្រូវមានកាតព្វកិច្ចចុះបញ្ជីក្នុង **ប.ស.ស**. ផ្នែកប្រាក់សោធនក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន លើកលែងតែសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងផ្នែកហានិភ័យការងាររួចហើយ។

ទម្រង់និងបែបបទនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៦ .-**

និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថានដូចមានចែងនៅក្នុងមាត្រា៥នៃអនុក្រឹត្យនេះត្រូវមានកាតព្វកិច្ចចុះបញ្ជីកម្មករនិយោជិតក្នុង**ប.ស.ស**. យ៉ាងយូរ៣(បី)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចូលបម្រើការងារ លើកលែងតែកម្មករនិយោជិតដែលបានចុះបញ្ជីរួចហើយ។ ការចុះបញ្ជីកម្មករនិយោជិតត្រូវអនុលោមតាមទិន្នន័យក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនសម្រាប់កម្មករនិយោជិតបរទេស។

នីតិវិធី ទម្រង់និងបែបបទនៃការចុះបញ្ជី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៧ .-**

**ប.ស.ស**. ត្រូវចេញប័ណ្ណសមាជិកដល់កម្មករនិយោជិតទាំងអស់ដែលបានចុះបញ្ជីដោយអនុលោមតាមទិន្នន័យក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែនសម្រាប់តែកម្មករនិយោជិតបរទេសប៉ុណ្ណោះ។

ប័ណ្ណសមាជិក **ប.ស.ស**. ត្រូវផ្តល់ជូនដោយឥតគិតថ្លៃ។ ក្នុងករណីបាត់ ឬខូចខាត សមាជិក **ប.ស.ស**. ត្រូវជូនដំណឹងជាបន្ទាន់ទៅនិយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថាន ឬ **ប.ស.ស**. និងស្នើសុំប័ណ្ណទុតិយតាយ៉ាងយូរ៣០(សាមសិប)ថ្ងៃ។

បែបបទនិងនីតិវិធីនៃការផ្តល់ប័ណ្ណទុតិយតានៃប័ណ្ណសមាជិក **ប.ស.ស**. ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ជំពូកទី៤
## អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទាន របបសន្តិសុខសង្គមផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច

**មាត្រា៨ .-**

ភាគទានផ្នែកប្រាក់សោធន ជាបន្ទុករួមគ្នារវាងនិយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត។ សម្រាប់រយៈពេល៥(ប្រាំ)ឆ្នាំដំបូង ភាគទាននេះត្រូវកំណត់ក្នុងអត្រាស្មើនឹង៤%(បួនភាគរយ)នៃប្រាក់ឈ្នួលជាប់ភាគទានដូចដែលបានកំណត់ខាងក្រោម៖

- ២%(ពីរភាគរយ)ជាបន្ទុកនិយោជក
- ២%(ពីរភាគរយ) ជាបន្ទុកកម្មករនិយោជិត។

ក្នុងករណីដែលសហគ្រាស គ្រឹះស្ថាន បើកប្រាក់ឈ្នួលជារូបិយប័ណ្ណបរទេស ប្រាក់ឈ្នួលប្រចាំខែត្រូវគិតជាប្រាក់រៀលតាមអត្រាប្តូរប្រាក់មធ្យមប្រចាំខែដោយផ្អែកតាមអត្រាប្តូរប្រាក់ធនាគារជាតិនៃកម្ពុជាដែលជូនដំណឹងដោយ **ប.ស.ស**.។

ប្រាក់ឈ្នួលជាប់ភាគទានដែលមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

**មាត្រា៩ ៈ-**

ការបង់ភាគទានផ្នែកប្រាក់សោធនត្រូវធ្វើឡើងជាប្រចាំខែ។ និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ត្រូវមានកាតព្វកិច្ចប្រមូលនិងបង់ភាគទានផ្នែកប្រាក់សោធនដែលជាចំណែករបស់ខ្លួន និងជាចំណែករបស់កម្មករនិយោជិតមកក្នុងគណនី **ប.ស.ស.** នៅធនាគារជាតិ យ៉ាងយូរត្រឹមថ្ងៃទី១៥(ដប់ប្រាំ)នៃខែបន្ទាប់។

ក្នុងករណីនិយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថាន មានលទ្ធភាពបង់ភាគទានប្រចាំឆ្នាំត្រូវស្នើសុំមក **ប.ស.ស.**។ ការបង់ភាគទានប្រចាំឆ្នាំនេះ ត្រូវធ្វើឡើងនៅខែបន្ទាប់គិតចាប់ពីកាលបរិច្ឆេទនៃខែដែលបានស្នើសុំបង់ភាគទាន។ ការបង់ភាគទានធ្វើឡើងជាប្រចាំឆ្នាំ និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវបង់ភាគទានតាមឆ្នាំនៃប្រតិទិន។ **ប.ស.ស.** ត្រូវធ្វើការកែតម្រូវចំនួនភាគទាននៅដើមឆ្នាំបន្ទាប់។

**មាត្រា១០ ៈ-**

និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលបង់ភាគទានប្រចាំខែ ត្រូវមានកាតព្វកិច្ចផ្តល់របាយការណ៍អំពីចំនួនកម្មករនិយោជិតទាំងអស់មក **ប.ស.ស.** យ៉ាងយូរត្រឹមថ្ងៃទី២០(ម្ភៃ)នៃខែបន្ទាប់។

និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលបង់ភាគទានប្រចាំឆ្នាំ ត្រូវមានកាតព្វកិច្ចផ្តល់របាយការណ៍អំពីចំនួនកម្មករនិយោជិតទាំងអស់មក **ប.ស.ស.** តាមកាលកំណត់ដូចខាងក្រោម៖

១. ក្នុងករណីមិនមានចលនាចេញ-ចូលបុគ្គលិករបស់ខ្លួន និយោជកត្រូវរាយការណ៍រៀងរាល់១២(ដប់ពីរ)ខែម្តង។

២. ក្នុងករណីមានចលនាចេញ-ចូលបុគ្គលិករបស់ខ្លួន និយោជកត្រូវរាយការណ៍យ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃបម្រែបម្រួល។

ទម្រង់និងបែបបទនៃការរាយការណ៍អំពីចំនួនកម្មករនិយោជិតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា១១ ៈ-**

និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវផ្តល់សៀវភៅបើកប្រាក់ឬតារាងបើកប្រាក់ឈ្នួលជាទម្រង់អេឡិចត្រូនិចឬឯកសារបើកប្រាក់ផ្សេងទៀតតាមខែនីមួយៗ ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងៗមក **ប.ស.ស.** ដើម្បីត្រួតពិនិត្យតាមការស្នើសុំ។

**មាត្រា១២ ៈ-**

និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារមានកាតព្វកិច្ចជូនដំណឹងមក **ប.ស.ស.** រាល់ការបិទ ការព្យួរ ការប្តូរទីតាំងសហគ្រាស គ្រឹះស្ថាន ឬការកែប្រែស្ថានភាពគតិយុត្តនៃនិយោជក ក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ មុនកាលបរិច្ឆេទនៃការបិទ ការព្យួរ ការប្តូរទីតាំងសហគ្រាស គ្រឹះស្ថាន ឬការកែប្រែស្ថានភាពគតិយុត្តនៃនិយោជក។

ទម្រង់និងបែបបទនៃការបិទ ការព្យួរ ការប្តូរទីតាំងសហគ្រាស គ្រឹះស្ថាន ឬការកែប្រែស្ថានភាពគតិយុត្តនៃនិយោជក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ជំពូកទី៥
## លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការទាមទារ និងការផ្តល់តាមការលិក ផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច

**មាត្រា១៣ ៈ-**

សមាជិក**ប.ស.ស.** ជាកម្មករនិយោជិត មានសិទ្ធិទទួលបានសោធនជរាភាព ប្រសិនបើសាមីជនបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១.បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន
២.មានអាយុយ៉ាងតិច៦០(ហុកសិប)ឆ្នាំ និង
៣.បានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច១២(ដប់ពីរ)ខែ។
សោធនជរាភាពដែលផ្តល់ឲ្យត្រូវគណនាតាមរូបមន្តដូចខាងក្រោម៖

| | | |
|---|---|---|
| សជ | = | អស x បឈម |
| សជ | | ជាសោធនជរាភាពរបស់សាមីជនដែលត្រូវទទួលបាន |
| អស | | ជាអត្រាសោធនដែលត្រូវទទួលបានដូចមានកំណត់ក្នុងឧបសម្ព័ន្ធ១នៃអនុក្រឹត្យនេះ |
| បឈម | | ជាប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទានរបស់សាមីជន។ |

ក្នុងករណីសមាជិក **ម.ស.ស**. ជាកម្មករនិយោជិត មិនបានបំពេញលក្ខខណ្ឌក្នុងចំណុច៣ នៃកថាខណ្ឌទី១ខាងលើ ត្រូវទទួលបានវិភាជន៍ជរាភាព។ វិភាជន៍ជរាភាពដែលផ្តល់ឲ្យត្រូវគណនាតាមរូបមន្តដូចខាងក្រោម៖

| | | |
|---|---|---|
| វភជ | = | ផភ (១+ សថ) |
| វភជ | | ជាវិភាជន៍ជរាភាពរបស់សាមីជនដែលត្រូវទទួលបាន |
| សថ | | ជាសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ផ្លូវការ |
| ផភ | | ជាផលបូកចំនួនភាគទានដែលបានបង់សម្រាប់របបប្រាក់សោធន។ |

**មាត្រា១៤ .-**

សមាជិក **ម.ស.ស**. ជាកម្មករនិយោជិត ដែលធ្លាក់ខ្លួនទុព្វលភាព មានសិទ្ធិទទួលបានសោធនទុព្វលភាព ប្រសិនបើសាមីជនបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖
១.បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន
២.បានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច៦០(ហុកសិប)ខែមុនកាលបរិច្ឆេទទទួលរងទុព្វលភាព។
សោធនទុព្វលភាពដែលផ្តល់ឲ្យត្រូវគណនាតាមរូបមន្តដូចខាងក្រោម៖

| | | |
|---|---|---|
| សទ | = | អស X បឈម |
| សទ | | ជាសោធនទុព្វលភាពរបស់សាមីជនដែលត្រូវទទួលបាន |
| អស | | ជាអត្រាសោធនដែលត្រូវទទួលបានដូចមានកំណត់ក្នុងឧបសម្ព័ន្ធ១នៃអនុក្រឹត្យនេះ |
| បឈម | | ជាប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទានរបស់សាមីជន។ |

កម្រិតអប្បបរមានៃសោធនទុព្វលភាពត្រូវកំណត់ស្មើនឹង៤៥% (សែសិបប្រាំភាគរយ) នៃប្រាក់ឈ្នួលមធ្យមបង់ភាគទានរបស់សាមីជន។

**មាត្រា១៥ .-**

សិទ្ធិវន្តនៃសោធនឧត្តរជីវី មានសិទ្ធិទទួលបានសោធនឧត្តរជីវី លុះត្រាតែមានការទទួលមរណភាពនៃសាមីជនជាសោធនិកជរាភាព ឬទុព្វលភាព ឬសមាជិក **ម.ស.ស**. បានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច៦០(ហុកសិប)ខែ។
សោធនឧត្តរជីវីដែលផ្តល់ឲ្យត្រូវគណនាតាមរូបមន្តដូចខាងក្រោម៖

| | | |
|---|---|---|
| សជវ | = | ៨៥% x សជ ឬ ៨៥% x សទ |
| សជវ | | ជាសោធនឧត្តរជីវីដែលសិទ្ធិវន្តត្រូវទទួលបាន |
| សជ | | ជាសោធនជរាភាព |
| សទ | | ជាសោធនទុព្វលភាព។ |

ចំណែកសោធននិវត្តន៍ជីវី ត្រូវបានបែងចែកដូចខាងក្រោម៖

-សម្រាប់សហព័ទ្ធ៥០% (ហាសិបភាគរយ)

-សម្រាប់កូន៥០% (ហាសិបភាគរយ)

-ក្នុងករណីដែលសិទ្ធិវន្តមានតែសហព័ទ្ធ ឬកូន ត្រូវទទួលបាន១០០% (មួយរយភាគរយ)។

**មាត្រា១៦ .-**

សិទ្ធិវន្តនៃសោធននិវត្តន៍ជីវីមានសិទ្ធិទទួលបានវិភាជន៍បូជាសព នៅពេលដែលសោធនិកជរាភាព ឬ ទុព្វលភាពសាមីទទួលមរណភាព។ ប្រសិនបើករណីយកិច្ចនេះមិនបានបំពេញដោយសិទ្ធិវន្តនៃសោធននិវត្តន៍ជីវី វិភាជន៍បូជាសពអាចត្រូវបានផ្តល់ដល់ជនណាដែលជាអ្នកចាត់ចែងបូជាសពសាមីជនផ្ទាល់។

លក្ខខណ្ឌនៃការទទួលបានវិភាជន៍បូជាសពត្រូវកំណត់ដូចខាងក្រោម៖

- ជូនដំណឹងមក **ប.ស.ស.** អំពីមរណភាពរបស់សោធនិកជរាភាព ឬទុព្វលភាព ក្នុងរយៈពេលយ៉ាងយូរ២(ពីរ)សប្តាហ៍ គិតចាប់ពីកាលបរិច្ឆេទទទួលមរណភាព

- បំពេញទម្រង់ស្នើសុំវិភាជន៍បូជាសពដោយភ្ជាប់ជាមួយនូវសំបុត្រមរណភាព ឬឯកសារផ្សេងៗដែលទទួលស្គាល់ដោយ **ប.ស.ស.**។

**ប.ស.ស.** ត្រូវចេញសេចក្តីសម្រេចផ្តល់វិភាជន៍បូជាសព ក្នុងរយៈពេលមិនលើស២(ពីរ)សប្តាហ៍ គិតចាប់ពីកាលបរិច្ឆេទទទួលពាក្យស្នើសុំ។

នីតិវិធីនិងបែបបទនៃការផ្តល់តាវកាលិកវិភាជន៍បូជាសពត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.**។

**មាត្រា១៧ .-**

សមាជិក **ប.ស.ស.** ដែលបានបំពេញលក្ខខណ្ឌដើម្បីទទួលបានតាវកាលិកសោធនជរាភាពត្រូវបំពេញទម្រង់ទាមទារតាវកាលិកនេះ ក្នុងអំឡុងពេល៣(បី)ខែ មុនកាលបរិច្ឆេទដែលសាមីជនមានសិទ្ធិទាមទារ។ ក្នុងករណីសមាជិក **ប.ស.ស.** ដែលត្រូវទទួលបានវិភាជន៍ជរាភាព ត្រូវបំពេញទម្រង់ទាមទារវិភាជន៍ជរាភាព ក្នុងអំឡុងពេល១(មួយ)ខែ ក្រោយពេលអាយុ៦០(ហុកសិប)ឆ្នាំ។

សមាជិក **ប.ស.ស.** ដែលបានបំពេញលក្ខខណ្ឌដើម្បីទទួលបានតាវកាលិកសោធនទុព្វលភាព ត្រូវបំពេញទម្រង់ទាមទារតាវកាលិកនេះ ក្នុងអំឡុងពេល១(មួយ)ខែ គិតចាប់ពីកាលបរិច្ឆេទធ្លាក់ខ្លួនទុព្វលភាព។ ក្នុងករណីដែលទុព្វលជនមិនមានលទ្ធភាពក្នុងការទាមទារតាវកាលិក ដោយសារមានភាពទ្រុឌទ្រោមធ្ងន់ធ្ងរ ការស្នើសុំត្រូវធ្វើដោយអ្នកតំណាងស្របច្បាប់នៃទុព្វលជននោះ។

សិទ្ធិវន្តនៃសោធននិវត្តន៍ជីវីត្រូវបំពេញទម្រង់ទាមទារតាវកាលិកនេះក្នុងអំឡុងពេល៣(បី)ខែ បន្ទាប់ពីកាលបរិច្ឆេទទទួលមរណភាពនៃសាមីជនជាសោធនិកជរាភាព ឬទុព្វលភាព ឬសមាជិក **ប.ស.ស.** ដែលបានបង់ភាគទានយ៉ាងតិច៦០(ហុកសិប)ខែ។

សិទ្ធិវន្តនៃសោធននិវត្តន៍ជីវី ឬបុគ្គលដែលចាត់ចែងបូជាសពសោធនិកជរាភាព ឬទុព្វលភាពត្រូវបំពេញទម្រង់ទាមទារតាវកាលិកវិភាជន៍បូជាសពយ៉ាងយូរ៣(បី)ខែ បន្ទាប់ពីកាលបរិច្ឆេទសោធនិកជរាភាពឬទុព្វលភាពទទួលមរណភាព។

តាវកាលិកសោធនជរាភាព ទុព្វលភាព និងសោធននិវត្តន៍ជីវី ត្រូវគិតចាប់ពីកាលបរិច្ឆេទនៃការទាមទារ។ ក្នុងករណីនកខានការទាមទារ ដោយករណីប្រធានសក្តិ សាមីជនអាចទាមទាររំលស់ជ្ជា។ អវសិដ្ឋនេះត្រូវផ្តល់ជូនតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.**។

ទម្រង់នៃការទាមទារតាវកាលិកនីមួយៗត្រូវកំណត់ដោយអគ្គនាយក **ប.ស.ស.**។

## ជំពូកទី៦
## របបសន្តិសុខសង្គមផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត

**មាត្រា១៨ -**

សមាជិក **ប.ស.ស.** ដែលបានបំពេញលក្ខខណ្ឌណាមួយដូចខាងក្រោម មានសិទ្ធិស្នើសុំមក **ប.ស.ស.** ដើម្បីចូលរួមក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត៖

១.បាត់បង់ការងារដែលមានប្រាក់ឈ្នួលមុនអាយុ៦០(ហុកសិប)ឆ្នាំ និងមានលទ្ធភាពបង់ភាគទានបន្ត។

២.មានអាយុ៦០(ហុកសិប)ឆ្នាំ និងមានបំណងបង់ភាគទានបន្តដើម្បីទទួលបានសោធនជរាភាពខ្ពស់ជាងសោធនជរាភាពជាក់ស្តែង ដែលសាមីជនត្រូវទទួលបានតាមរបបភាគទានជាកាតព្វកិច្ច។

៣.មានប្រាក់ចំណូលខ្ពស់ជាងប្រាក់ឈ្នួលពិតាន ដែលសាមីជនជាប់កាតព្វកិច្ចក្នុងរបបភាគទានជាកាតព្វកិច្ច។ ប្រាក់ឈ្នួលពិតាន ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

**មាត្រា១៩ -**

សមាជិក **ប.ស.ស.** អាចស្នើសុំចុះបញ្ជីផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តនៅ **ប.ស.ស.** ដោយសាមីជនផ្ទាល់។ ទម្រង់និងបែបបទនៃការចុះបញ្ជីកម្មករនិយោជិតត្រូវកំណត់ដោយអគ្គនាយក **ប.ស.ស.**។ **ប.ស.ស.**ត្រូវចេញវិញ្ញាបនបត្ររដ្ឋបាល បញ្ជាក់អំពីអត្តសញ្ញាណសោធនស្ម័គ្រចិត្ត។

**មាត្រា២០ -**

ភាគទានផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តជាបន្ទុកផ្ទាល់របស់សាមីជនដែលបានចុះបញ្ជីក្នុងផ្នែកនេះ។ អត្រាភាគទានផ្នែកនេះត្រូវកំណត់ស្មើនឹងអត្រាភាគទានតាមរបបភាគទានជាកាតព្វកិច្ច។ ចំនួនទឹកប្រាក់ជាប់ភាគទានត្រូវអនុវត្តតាមប្រាក់ស្នើសុំជាប់ភាគទានរបស់សាមីជនផ្ទាល់។

ប្រាក់ស្នើសុំជាប់ភាគទានសម្រាប់សមាជិក **ប.ស.ស.** ដែលបាត់បង់ការងារមុនអាយុ៦០(ហុកសិប)ឆ្នាំ និងមានលទ្ធភាពបង់ភាគទានបន្ត ត្រូវកំណត់ស្មើនឹងប្រាក់ឈ្នួលមធ្យម៦(ប្រាំមួយ)ខែចុងក្រោយ គិតចាប់ពីកាលបរិច្ឆេទបាត់បង់ការងារ។

ចំពោះសមាជិក **ប.ស.ស.** ដែលបានបំពេញលក្ខខណ្ឌក្នុងចំណុច១ឬ២នៃមាត្រា១៨ នៃអនុក្រឹត្យនេះ ត្រូវអនុវត្តនីតិវិធីនៃការបង់ភាគទានក្នុងផ្នែកនេះយ៉ាងតិចចាប់ពី៦(ប្រាំមួយ)ខែឡើង។

ចំពោះសមាជិក **ប.ស.ស.** ដែលបានបំពេញលក្ខខណ្ឌក្នុងចំណុច៣នៃមាត្រា១៨ នៃអនុក្រឹត្យនេះ ត្រូវអនុវត្តតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញ។

**មាត្រា២១ -**

សមាជិក **ប.ស.ស.** ដែលបានចូលរួមក្នុងរបបប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តមានកាតព្វកិច្ចបង់ភាគទាន ដោយផ្ទេរតាមលេខអត្តសញ្ញាណសោធនស្ម័គ្រចិត្តដែលចេញដោយ **ប.ស.ស.** មកក្នុងគណនី **ប.ស.ស.**នៅធនាគារដៃគូ។

យន្តការបង់ភាគទាននៃផ្នែកនេះត្រូវប្រើប្រាស់ដូចគ្នានឹងយន្តការបង់ភាគទានផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ចដូចមានចែងក្នុងមាត្រា៩នៃអនុក្រឹត្យនេះ។

**មាត្រា២២ -**

សមាជិក **ប.ស.ស.**នៃផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត ត្រូវមានកាតព្វកិច្ចជូនដំណឹងមក **ប.ស.ស.** រាល់ការឈប់ ឬការព្យួរការបង់ភាគទាននៃផ្នែកនេះ យ៉ាងយូរ៣០(សាមសិប)ថ្ងៃ។

ទម្រង់និងបែបបទនៃការស្នើសុំឈប់ឬព្យួរការបង់ភាគទានត្រូវកំណត់ដោយសេចក្តីសម្រេចរបស់អគ្គនាយក **ប.ស.ស.** ។

**មាត្រា២៣ .-**

សមាជិក **ម.ស.ស**. ជាកម្មករនិយោជិតដែលបានចុះបញ្ជីក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត ហើយបានបំពេញលក្ខខណ្ឌក្នុងចំណុច១ឬ២នៃមាត្រា១៨ នៃអនុក្រឹត្យនេះ មានសិទ្ធិទទួលបានសោធនជរាភាព សោធនទុព្វលភាព សោធនឧត្តរជីវី និងវិភាជន៍ឬជាសព។

ការគណនាគារកាលិកសោធនជរាភាព សោធនទុព្វលភាព និងសោធនឧត្តរជីវី ត្រូវអនុវត្តដូចផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច។

**មាត្រា២៤ .-**

សមាជិក **ម.ស.ស**. ជាកម្មករនិយោជិត ដែលបានចុះបញ្ជីក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត ហើយបានបំពេញលក្ខខណ្ឌក្នុងចំណុច៣នៃមាត្រា១៨នៃអនុក្រឹត្យនេះ មានសិទ្ធិទទួលបានតែសោធនជរាភាពតែមួយគត់ប៉ុណ្ណោះ។ សោធនជរាភាពត្រូវបែងចែកដូចខាងក្រោម៖

- ១/៣(មួយភាគបី)នៃចំនួនភាគទានដែលបានបង់សរុប ដោយរួមបញ្ចូលទាំងផលនៃការវិនិយោគ ត្រូវបើកផ្តល់ប្រាក់វិភាជន៍ជូនសោធនិកតែម្តងគត់នៅពេលចូលនិវត្តន៍
- ២/៣(ពីរភាគបី)នៃចំនួនភាគទានដែលបង់សរុបដែលរួមបញ្ចូលទាំងផលនៃការវិនិយោគ ត្រូវបើកផ្តល់ជាប្រចាំខែជូនសោធនិកតាមរូបមន្តដូចខាងក្រោម៖

| | | |
|---|---|---|
| សជ | = | បស / ចខរ |
| ចខរ | = | (អយ-អច) x ១២ |
| ចខរ | | ចំនួនខែដែលសាមីជនរំពឹងរស់បានក្រោយអាយុចូលនិវត្តន៍ |
| សជ | | ជាសោធនជរាភាពរបស់សាមីជនដែលត្រូវទទួលបាន |
| បស | | ជាប្រាក់ដែលនៅសល់២/៣ នៃចំនួនប្រាក់ភាគទានដែលបានបង់សរុប ដោយបូកនឹងផលនៃការវិនិយោគ |
| អយ | | ជាអាយុរំពឹងទុក |
| អច | | ជាអាយុចូលនិវត្តន៍ដែលកំណត់ដោយច្បាប់។ |

អាយុរំពឹងទុកត្រូវអនុលោមតាមស្ថិតិដែលចេញដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។

ក្រុមប្រឹក្សាភិបាលនៃ **ម.ស.ស**. ត្រូវកំណត់ផលនៃការវិនិយោគរបស់មូលនិធិប្រាក់សោធនតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញជាប្រចាំឆ្នាំ អនុលោមតាមគោលការណ៍ណែនាំស្តីពីការវិនិយោគរបស់និយ័តករសន្តិសុខសង្គម។

**មាត្រា២៥ .-**

សន្តតិជននៃសមាជិក **ម.ស.ស**. ឬសន្តតិជននៃសោធនិកជរាភាពក្នុងផ្នែកប្រាក់សោធនតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភតែម្តងគត់។

ប្រាក់ដែលសន្តតិជនត្រូវទទួលបាន គឺជាចំនួនប្រាក់ភាគទានសរុបរបស់មតកជនបានបង់ភាគទានតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញ ដោយរួមបញ្ចូលទាំងផលនៃការវិនិយោគនៃប្រាក់ភាគទានរបស់សមាជិក **ម.ស.ស**.ឬសោធនិកជរាភាពនៃប្រព័ន្ធហិរញ្ញប្បទានពេញលេញសរុបដែលនៅសល់ បន្ទាប់ពីការទទួលមរណភាពនៃមតកជន។

**មាត្រា២៦ .-**

សមាជិក **ម.ស.ស**. ដែលបានបំពេញលក្ខខណ្ឌក្នុងចំណុច១ឬ២នៃមាត្រា១៨ នៃអនុក្រឹត្យនេះត្រូវបំពេញទម្រង់ទាមទារគារកាលិកសោធនជរាភាព ទុព្វលភាព ឧត្តរជីវី និងវិភាជន៍ឬជាសពដូចមានចែងក្នុងមាត្រា១៩នៃអនុក្រឹត្យនេះ។

សមាជិក **ប.ស.ស.** ដែលបានបំពេញលក្ខខណ្ឌក្នុងចំណុចគនៃមាត្រា១៨ នៃអនុក្រឹត្យនេះ ដើម្បីទទួលសោធនជរាភាពតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញ ត្រូវបំពេញទម្រង់ទាមទារតាវកាលិកសោធនជរាភាពក្នុងអំឡុងពេល៣(បី)ខែមុនកាលបរិច្ឆេទដែលសាមីជនមានសិទ្ធិទាមទារ។

សន្តតិជននៃសមាជិក **ប.ស.ស.** ឬសោធនិកជរាភាពផ្នែកប្រាក់សោធនតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញ ត្រូវបំពេញទម្រង់ទាមទារមត៌ក យ៉ាងយូរ៣(បី)ខែ បន្ទាប់ពីកាលបរិច្ឆេទនៃមរណភាពរបស់មតកជន។

តាវកាលិកសោធនជរាភាព ទុព្វលភាព និងសោធននន្តរជីវី ត្រូវគិតចាប់ពីកាលបរិច្ឆេទនៃការទាមទារ។ ក្នុងករណីខកខានការទាមទារដោយករណីប្រធានសក្តិ សាមីជនអាចទាមទារអវសិដ្ឋ។ អវសិដ្ឋនេះត្រូវផ្តល់ជូនតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.**។

ទម្រង់នៃការទាមទារតាវកាលិកនីមួយៗត្រូវកំណត់ដោយអគ្គនាយក **ប.ស.ស.**។

## ជំពូកទី៧
## សមាទិនាន

**មាត្រា២៧ --**

ប្រាក់សោធននៃតាវកាលិក សោធនជរាភាព សោធនទុព្វលភាព និងសោធននន្តរជីវី ត្រូវគណនាជាប្រចាំខែ។ **ប.ស.ស.** ត្រូវរៀបចំបើកផ្តល់តាវកាលិកប្រចាំខែផ្នែកប្រាក់សោធនជាអឌ្ឍមាស ដោយការបើកជាអឌ្ឍមាសទី១ យ៉ាងយូរនៅថ្ងៃទី១៥(ដប់ប្រាំ)នៃខែនីមួយៗ និងអឌ្ឍមាសទី២ យ៉ាងយូរនៅថ្ងៃទី៣០(សាមសិប)នៃខែនីមួយៗ។ ប្រសិនបើកាលបរិច្ឆេទនៃការចូលនិវត្តន៍មិនស្ថិតចំថ្ងៃដើមខែ ថ្ងៃដែលនៅសល់ត្រូវប្តូកបញ្ចូលទៅខែបន្ទាប់។

**មាត្រា២៨ --**

ក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ **ប.ស.ស.** ត្រូវមានភារកិច្ចក្នុងការវាយតម្លៃឬសម្រេចអំពីស្ថានភាពទុព្វលភាព។ ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ **ប.ស.ស.** ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

**មាត្រា២៩ --**

**ប.ស.ស.** ត្រូវធ្វើការសិក្សា វិភាគវាយតម្លៃហានិភ័យហិរញ្ញវត្ថុផ្នែកប្រាក់សោធន យ៉ាងយូរ៥(ប្រាំ)ឆ្នាំ ម្តង។ **ប.ស.ស.**មានសិទ្ធិស្នើសុំទិន្នន័យដែលទាក់ទងនឹងការវិភាគវាយតម្លៃហានិភ័យហិរញ្ញវត្ថុពីស្ថាប័ន ឬ អង្គភាពដែលពាក់ព័ន្ធ។

**មាត្រា៣០ --**

តាវកាលិកផ្នែកប្រាក់សោធន ត្រូវធ្វើការកែសម្រួលជារៀងរាល់ឆ្នាំ ផ្អែកតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** អនុលោមតាមសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ផ្លូវការរបស់ក្រសួងផែនការ។ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ផ្លូវការប្រចាំឆ្នាំត្រូវគណនាដោយយកផលបូកនៃសន្ទស្សន៍រៀងរាល់ខែក្នុងឆ្នាំចែកនឹងដប់ពីរ។

ការកែសម្រួលតាវកាលិកផ្នែកប្រាក់សោធនត្រូវធ្វើឡើងនៅឆ្នាំបន្ទាប់ គិតចាប់ពីសាមីជនបើកប្រាក់សោធននៅឆ្នាំដំបូង។ ការកែសម្រួលត្រូវគណនាតាមរូបមន្តដូចខាងក្រោម៖

$តវ_{ឆ} = តវ_{ឆ-១} (១+ សថ_{ឆ})$

$តវ_{ឆ}$ ជាតាវកាលិកដែលត្រូវកែសម្រួលនៅក្នុងឆ្នាំបន្ទាប់

$តវ_{ឆ-១}$ ជាតាវកាលិកដែលបានកែសម្រួលក្នុងឆ្នាំមុន

$សថ_{ឆ}$ ជាសន្ទស្សន៍ថ្លៃទំនិញក្នុងឆ្នាំបន្ទាប់។

**មាត្រា៣១ .-**

សមាជិក **ប.ស.ស.** ដែលធ្វើការងារចាប់ពី ២ (ពីរ)កន្លែងឡើងទៅ ត្រូវបង់ភាគទានក្នុងខែតែមួយ។ ឆ្នាំភាគទានត្រូវគណនាដោយរាប់បញ្ចូលចំនួនខែទាំងអស់ដែលសមាជិក **ប.ស.ស.** បានបង់ភាគទាន។

**មាត្រា៣២ .-**

អត្រាសមាច័យសោធនជរាភាព និងអត្រាសមាច័យសោធនទុព្វលភាព ត្រូវកំណត់ស្មើ១,៧៥% (មួយក្បៀសចិតសិបប្រាំភាគរយ) សម្រាប់១៥(ដប់ប្រាំ)ឆ្នាំភាគទានដំបូង និង១,២៥%(មួយក្បៀសម្ភៃប្រាំភាគរយ) សម្រាប់ឆ្នាំភាគទានបន្តបន្ទាប់។

ចំពោះសមាជិក **ប.ស.ស.** ដែលជាកម្មករនិយោជិតដែលមានចែងក្នុងចំណុច១ឬ២នៃមាត្រា២០ នៃអនុក្រឹត្យនេះ ឆ្នាំភាគទានដែលត្រូវគណនាអត្រាសមាច័យសោធនជរាភាព និងសោធនទុព្វលភាព ត្រូវរាប់បញ្ចូលទាំងរបបភាគទានជាកាតព្វកិច្ច និងទាំងរបបភាគទានដោយស្ម័គ្រចិត្ត។

**មាត្រា៣៣ .-**

កាលបរិច្ឆេទនៃការចាប់ផ្ដើមបង់ភាគទាននៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនទាំងរបបភាគទានជាកាតព្វកិច្ច និងរបបភាគទានដោយស្ម័គ្រចិត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.**។

**មាត្រា៣៤ .-**

អត្រាភាគទាននៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន ត្រូវបានកំណត់តាមវិធីសាស្ត្របុព្វលាភជណ្តើរ ដូចខាងក្រោម៖

- ដំណាក់កាលទី១ ៖ ភាគទានត្រូវកំណត់ស្មើនឹង៤%(បួនភាគរយ) នៃប្រាក់ឈ្នួលជាប់ភាគទាន ឬប្រាក់ស្មើសុំជាប់ភាគទានក្នុងរយៈពេល៥(ប្រាំ)ឆ្នាំដំបូង គិតចាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមបង់ភាគទាន ដូចមានចែងក្នុងមាត្រា៣៣ខាងលើ
- ដំណាក់កាលទី២ ៖ ភាគទានត្រូវកំណត់ស្មើនឹង៨%(ប្រាំបីភាគរយ) នៃប្រាក់ឈ្នួលជាប់ភាគទាន ឬប្រាក់ស្មើសុំជាប់ភាគទានក្នុងរយៈពេល៥(ប្រាំ)ឆ្នាំ បន្ទាប់ពីដំណាក់កាលទី១
- ដំណាក់កាលទី៣៖ អត្រាភាគទានត្រូវដំឡើង២,៧៥%(ពីរក្បៀសចិតសិបប្រាំភាគរយ) នៃប្រាក់ឈ្នួលជាប់ភាគទានឬប្រាក់ស្មើសុំជាប់ភាគទាន ក្នុងរយៈពេល១០(ដប់)ឆ្នាំ និងដំណាក់កាល១០(ដប់)ឆ្នាំបន្តបន្ទាប់។

ការកែសម្រួលវិធីសាស្ត្រនៃការកំណត់អត្រាភាគទានខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** ដោយមានការគាំទ្រពីនិយ័តករសន្តិសុខសង្គម និងមានការយល់ព្រមពីក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ជំពូកទី៤
## ទោសប្បញ្ញត្តិ

**មាត្រា៣៥ .-**

ជនដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយណានៃអនុក្រឹត្យនេះ នឹងត្រូវទទួលទោសតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម និងបទប្បញ្ញត្តិជាធរមានដទៃផ្សេងទៀត។

## ជំពូកទី៩
## អន្តរប្បញ្ញត្តិ

**មាត្រា៣៦ --**

សមាជិក **ប.ស.ស.** ជាកម្មករនិយោជិតមានសិទ្ធិទទួលបានសោធនជរាភាពអយ្យកប្បញ្ញត្តិ ត្រូវបំពេញលក្ខខណ្ឌគិតចាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមដំណើរការដំបូង នៃផ្នែកប្រាក់សោធនដូចខាងក្រោម៖

- មានអាយុលើសពី៣០(សាមសិប)ឆ្នាំ
- បានបង់ភាគទានយ៉ាងតិច២៤(ម្ភៃបួន)ខែ ក្នុងរយៈពេល៣៦(សាមសិបប្រាំមួយ)ខែ។

សោធនជរាភាពអយ្យកប្បញ្ញត្តិដែលផ្តល់ឲ្យត្រូវគណនាតាមរូបមន្តដូចខាងក្រោម៖

| | | |
|---|---|---|
| សជអ | = | អស x បឈម |
| អស | = | ឆក+អប |
| អប | = | ( អសប- ៣០)/២ |

| | |
|---|---|
| សជអ | ជាសោធនជរាភាពអយ្យកប្បញ្ញត្តិរបស់សាមីជនដែលត្រូវទទួលបាន |
| បឈម | ជាប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទានរបស់សាមីជន |
| អស | ជាអត្រាសោធនដែលត្រូវទទួលបានដូចមានកំណត់ក្នុងឧបសម្ព័ន្ធ១នៃអនុក្រឹត្យនេះ |
| ឆក | ជាចំនួនឆ្នាំដែលបានបង់ភាគទាន |
| អប | ជាចំនួនឆ្នាំដែលត្រូវបន្ថែមសម្រាប់សោធនជរាភាពអយ្យកប្បញ្ញត្តិ ដែលមានកម្រិតអតិបរមា១៥ឆ្នាំ |
| អសប | ជាអាយុរបស់សមាជិក **ប.ស.ស.** ដែលចូលបម្រើការងារដំបូងគិតចាប់ពីកាលបរិច្ឆេទដំណើរការដំបូងនៃផ្នែកប្រាក់សោធន។ |

**មាត្រា៣៧ --**

សមាជិក **ប.ស.ស.** ជាបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដែលមានអាយុចាប់ពី៥៤(ហាសិបប្រាំបួន)ឆ្នាំឡើង គិតចាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមដំណើរការដំបូងនៃផ្នែកប្រាក់សោធន មានសិទ្ធិបង់ភាគទានបង្គ្រប់លក្ខខណ្ឌដូចមានចែងក្នុងមាត្រា៣៦នៃអនុក្រឹត្យនេះ ដើម្បីទទួលបានសោធនជរាភាពអយ្យកប្បញ្ញត្តិ។ ការបង់ភាគទានបង្គ្រប់សម្រាប់សោធនជរាភាពអយ្យកប្បញ្ញត្តិនេះជាបន្ទុកផ្ទាល់របស់សាមីជន។

**មាត្រា៣៨ --**

សមាជិក **ប.ស.ស.** ជាបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលចុះបញ្ជីក្នុងផ្នែកប្រាក់សោធននេះ ក៏ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងផ្នែកហានិភ័យការងារដែលកំពុងដំណើរការ។

## ជំពូកទី១០
## អវសានប្បញ្ញត្តិ

**មាត្រា៣៩ --**

កាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា៤០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង អគ្គនាយកបេឡាជាតិសន្តិសុខសង្គម គ្រប់អង្គភាព ស្ថាប័ន ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៦រោច ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ មីនា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីសម្រេចគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

| **ឧបនាយករដ្ឋមន្ត្រី<br>រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រី<br>ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ** |
|---|---|
| **អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** | **អ៊ិត សំហេង** |

**កន្លែងទទួល** :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៤០
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ១ នៃអនុក្រឹត្យលេខ...៣៧......អនក្រ.បក ចុះថ្ងៃទី...៤....ខែ មីនា ឆ្នាំ២០២១
ស្ដីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅ
ក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ

| ឆ្នាំ | អត្រាសោធន | រូបមន្ត |
|---|---|---|
| ១ | ១,៧៥% | ១×១,៧៥% |
| ២ | ៣,៥០% | ២×១,៧៥% |
| ៣ | ៥,២៥% | ៣×១,៧៥% |
| ៤ | ៧,០០% | ៤×១,៧៥% |
| ៥ | ៨,៧៥% | ៥×១,៧៥% |
| ៦ | ១០,៥០% | ៦×១,៧៥% |
| ៧ | ១២,២៥% | ៧×១,៧៥% |
| ៨ | ១៤,០០% | ៨×១,៧៥% |
| ៩ | ១៥,៧៥% | ៩×១,៧៥% |
| ១០ | ១៧,៥០% | ១០×១,៧៥% |
| ១១ | ១៩,២៥% | ១១×១,៧៥% |
| ១២ | ២១,០០% | ១២×១,៧៥% |
| ១៣ | ២២,៧៥% | ១៣×១,៧៥% |
| ១៤ | ២៤,៥០% | ១៤×១,៧៥% |
| ១៥ | ២៦,២៥% | ១៥×១,៧៥% |
| ១៦ | ២៧,៥០% | ១៥×១,៧៥%+១×១,២៥% |
| ១៧ | ២៨,៧៥% | ១៥×១,៧៥%+២×១,២៥% |
| ១៨ | ៣០,០០% | ១៥×១,៧៥%+៣×១,២៥% |
| ១៩ | ៣១,២៥% | ១៥×១,៧៥%+៤×១,២៥% |
| ២០ | ៣២,៥០% | ១៥×១,៧៥%+៥×១,២៥% |
| ២១ | ៣៣,៧៥% | ១៥×១,៧៥%+៦×១,២៥% |
| ២២ | ៣៥,០០% | ១៥×១,៧៥%+៧×១,២៥% |
| ២៣ | ៣៦,២៥% | ១៥×១,៧៥%+៨×១,២៥% |
| ២៤ | ៣៧,៥០% | ១៥×១,៧៥%+៩×១,២៥% |

| | | |
|---|---|---|
| ២៥ | ៣៨,៧៥% | ១៥×១,៧៥%+១០×១,២៥% |
| ២៦ | ៤០,០០% | ១៥×១,៧៥%+១១×១,២៥% |
| ២៧ | ៤១,២៥% | ១៥×១,៧៥%+១២×១,២៥% |
| ២៨ | ៤២,៥០% | ១៥×១,៧៥%+១៣×១,២៥% |
| ២៩ | ៤៣,៧៥% | ១៥×១,៧៥%+១៤×១,២៥% |
| ៣០ | ៤៥,០០% | ១៥×១,៧៥%+១៥×១,២៥% |
| ៣១ | ៤៦,២៥% | ១៥×១,៧៥%+១៦×១,២៥% |
| ៣២ | ៤៧,៥០% | ១៥×១,៧៥%+១៧×១,២៥% |
| ៣៣ | ៤៨,៧៥% | ១៥×១,៧៥%+១៨×១,២៥% |
| ៣៤ | ៥០,០០% | ១៥×១,៧៥%+១៩×១,២៥% |
| ៣៥ | ៥១,២៥% | ១៥×១,៧៥%+២០×១,២៥% |
| ៣៦ | ៥២,៥០% | ១៥×១,៧៥%+២១×១,២៥% |
| ៣៧ | ៥៣,៧៥% | ១៥×១,៧៥%+២២×១,២៥% |
| ៣៨ | ៥៥,០០% | ១៥×១,៧៥%+២៣×១,២៥% |
| ៣៩ | ៥៦,២៥% | ១៥×១,៧៥%+២៤×១,២៥% |
| ៤០ | ៥៧,៥០% | ១៥×១,៧៥%+២៥×១,២៥% |
| ៤១ | ៥៨,៧៥% | ១៥×១,៧៥%+២៦×១,២៥% |
| ៤២ | ៦០,០០% | ១៥×១,៧៥%+២៧×១,២៥% |
| ៤៣ | ៦១,២៥% | ១៥×១,៧៥%+២៨×១,២៥% |
| ៤៤ | ៦២,៥០% | ១៥×១,៧៥%+២៩×១,២៥% |
| ៤៥ | ៦៣,៧៥% | ១៥×១,៧៥%+៣០×១,២៥% |
| ៤៦ | ៦៥,០០% | ១៥×១,៧៥%+៣១×១,២៥% |
| ៤៧ | ៦៦,២៥% | ១៥×១,៧៥%+៣២×១,២៥% |
| ៤៨ | ៦៧,៥០% | ១៥×១,៧៥%+៣៣×១,២៥% |
| ៤៩ | ៦៨,៧៥% | ១៥×១,៧៥%+៣៤×១,២៥% |
| ៥០ | ៧០,០០% | ១៥×១,៧៥%+៣៥×១,២៥% |

- អត្រាសមាច័យ ១,៧៥% នៃ១៥ឆ្នាំភាគទានដំបូង
- អត្រាសមាច័យ ១,២៥% នៃឆ្នាំភាគទានបន្តបន្ទាប់

២/២

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកំណត់ប្រាក់ឈ្នួលឬប្រាក់បៀវត្សជាប់ឃាតទាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៧/០០៤ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៧០៧/០២០ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា១៣៩ និងមាត្រា១៤៨នៃច្បាប់ស្ដីពីការងារដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦១៨/០១០ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា៨៧ ចំណងជើងចំណុច«គ» ផ្នែកទី៣ នៃជំពូកទី៨ មាត្រា៨៩ មាត្រា៩០ មាត្រា៩១ មាត្រា៩៨ មាត្រា១១០ មាត្រា១២០ មាត្រា១២២នៃច្បាប់ស្ដីពីការងារដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈនិងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០១ ស្ដីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៨/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៨ ស្ដីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៤០០/០៧៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៥០០/០៩៦ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៣ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៣៩ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ស្ដីពីលក្ខន្តិកៈដោយឡែកក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មនៃអាជ្ញាធរសវនកម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៥/៦៤៨ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៨៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្ដីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៨៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១៩៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ស្តីពីបែបបទនៃការទទួលសិទ្ធិនិងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំនៃយោធិនអាជីព និងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍
- បានឃើញអនុក្រឹត្យលេខ១៥១ អនក្រ.បក ចុះថ្ងៃទី២៨ខែសីហា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៣០ ជំពូកទី៣នៃអនុក្រឹត្យលេខ ១៥៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ស្តីពីបែបបទនៃការទទួលសិទ្ធិនិងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំនៃយោធិនអាជីព និងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍
- បានឃើញអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់មន្រ្តីជាប់កិច្ចសន្យា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់ប្រាក់ឈ្នួលឬប្រាក់បៀវត្សជាប់ភាគទានតាមរបបភាគទានជាកាតព្វកិច្ចក្នុងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព ផ្នែកប្រាក់សោធន និងផ្នែកនិកម្មភាពការងារ ដូចមានចែងក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គមដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះប្រាក់ឈ្នួលឬប្រាក់បៀវត្សជាប់ភាគទានរបស់បុគ្គលដូចខាងក្រោម៖

១.បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈដែលមាន៖

- មន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈដែលបម្រើការងារនៅតាមក្រសួង ស្ថាប័ន អង្គភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- មន្ត្រីរាជការដែលស្ថិតនៅក្រោមច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិ លើកលែងតែផ្នែកប្រាក់សោធន
- មន្ត្រីរាជការដែលបម្រើការងារនៅក្នុងស្ថាប័នតុលាការ
- មន្ត្រីនគរបាលជាតិនិងមន្ត្រីពន្ធនាគារ ចំពោះតែគាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រក្នុងផ្នែកថែទាំសុខភាព
- មន្ត្រីដែលបម្រើការងារនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- មន្ត្រីរាជការដែលបម្រើការងារនៅក្នុងអាជ្ញាធរសវនកម្មជាតិ
- អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន
- មន្ត្រីជាប់កិច្ចសន្យាដែលបម្រើការនៅតាមក្រសួង ស្ថាប័ន អង្គភាព នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដែលមានការទទួលស្គាល់ដោយក្រសួងមុខងារសាធារណៈ
- បុគ្គលនៃវិស័យសាធារណៈផ្សេងទៀតដែលត្រូវកំណត់ដោយអនុក្រឹត្យ។

២.បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដោយរួមបញ្ចូលទាំងបុគ្គលធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ។

## ជំពូកទី២
## ប្រាក់ឈ្នួលឬប្រាក់បៀវត្សជាប់ភាគទាន

**មាត្រា៣ .-**

ប្រាក់បៀវត្សជាប់ភាគទានផ្នែកប្រាក់សោធនសម្រាប់បុគ្គលនៃវិស័យសាធារណៈត្រូវកំណត់ដោយ អនុក្រឹត្យដោយឡែក។

ប្រាក់បៀវត្សជាប់ភាគទានក្នុងផ្នែកហានិភ័យការងារនិងផ្នែកថែទាំសុខភាពសម្រាប់បុគ្គលនៃវិស័យសាធារណៈ ត្រូវអនុវត្តតាមការកំណត់ដែលមានក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ប្រាក់បៀវត្សជាប់ភាគទានគឺជាបៀវត្សរបស់បុគ្គលនៃវិស័យសាធារណៈដែលតម្រូវឱ្យជាប់ភាគទានតាមច្បាប់ឬប្រាក់ធនលាភរបស់បុគ្គលនៃវិស័យសាធារណៈដែលបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ចាប់ពី២០%(ម្ភៃភាគរយ)ឡើង ឬប្រាក់សោធនរបស់អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន ដែលតម្រូវឱ្យជាប់ភាគទានផ្នែកថែទាំសុខភាព។

**មាត្រា៤ .-**

ប្រាក់ឈ្នួលជាប់ភាគទានអប្បបរមាត្រូវកំណត់ស្មើនឹងចំនួន៤០០ ០០០(បួនសែន)រៀល និងប្រាក់ឈ្នួលជាប់ភាគទានពិតានស្មើនឹងចំនួន១ ២០០ ០០០(មួយលានពីរសែន)រៀល។

ប្រាក់ឈ្នួលជាប់ភាគទានគឺជាប្រាក់ឈ្នួលរបស់កម្មករនិយោជិតដែលតម្រូវឱ្យជាប់ភាគទានតាមច្បាប់ឬប្រាក់ធនលាភរបស់កម្មករនិយោជិតដែលបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ចាប់ពី២០%(ម្ភៃភាគរយ)ឡើង ឬប្រាក់សោធនរបស់កម្មករនិយោជិតដែលតម្រូវឱ្យជាប់ភាគទានផ្នែកថែទាំសុខភាព។

ការកែសម្រួលកម្រិតអប្បបរមានិងពិតាននៃប្រាក់ឈ្នួលជាប់ភាគទានត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ**ប.ស.ស.**។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា៥ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងការងារ**
**និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ: ១៦៥/២៣ ក.ប/ប្រ.ក.ប.ស.ស

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- យោងតាមការចាំបាច់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់កាលបរិច្ឆេទសម្រាប់ការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដូចមានចែងក្នុងមាត្រា៣៩ នៃអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**ប្រការ២.-**

របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារត្រូវដាក់ឱ្យអនុវត្តចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ តទៅ។

**ប្រការ៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន បេឡាជាតិសន្តិសុខសង្គម និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៥រោច ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ ....១៤៨/២២....ក.ប/ប្រ.ក.ប.ស.ស

# ប្រកាស
## ស្តីពី
## បែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងការបង់ភាគទាន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ ក្នុងបេឡាជាតិសន្តិសុខសង្គម

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ១៤០ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៧ នៃអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

- បានឃើញអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**ប្រការ១ .-**

ប្រកាសនេះមានគោលបំណងកំណត់អំពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងការបង់ភាគទាន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារក្នុងបេឡាជាតិសន្តិសុខសង្គមដែលសរសេរជាអក្សរកាត់ថា **ប.ស.ស.** ដើម្បីធានាបានប្រសិទ្ធភាព និងបង្កលក្ខណៈងាយស្រួលដល់ការអនុវត្តរបបសន្តិសុខសង្គម។

**ប្រការ២ .-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន និងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារក្នុងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធន។

**ប្រការ៣ .-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើនៅក្នុងប្រកាសនេះ មាននិយមន័យដូចខាងក្រោម៖

- *សហគ្រាស* សំដៅដល់ស្ថាប័ន ឬអង្គភាព ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សេវាកម្ម កសិកម្ម សិប្បកម្ម ទោះជាប្រយោជន៍សាធារណៈ ពាក់កណ្តាលសាធារណៈ ឬឯកជន ក្រៅសាសនា ឬក្នុងសាសនាក៏ដោយ ទោះមានលក្ខណៈជាការបង្រៀនវិជ្ជាជីវៈ ឬជាការកុសលក៏ដោយ ព្រមទាំងវិជ្ជាជីវៈសេរីនៃសមាគម ឬក្រុមប្រភេទណាក៏ដោយ។ សហគ្រាសអាចមានគ្រឹះស្ថានច្រើន ហើយគ្រឹះស្ថាននីមួយៗមានប្រើមនុស្សឱ្យធ្វើការងារក្នុងទីកន្លែងណាមួយប្រាកដ ដូចជាក្នុងរោងចក្រ រោងជាង ការដ្ឋាន។ល។ ក្រោមការគ្រប់គ្រង និងដឹកនាំរបស់និយោជក។ គ្រឹះស្ថានស្ថិតនៅក្រោមឱវាទសហគ្រាសមួយជានិច្ច។ គ្រឹះស្ថានអាចមានប្រើមនុស្សតែម្នាក់ក៏បានដែរ។ ករណីគ្រឹះស្ថាននេះមានតែមួយឯកឯង និងមិននៅក្រោមសហគ្រាសណាទេ គ្រឹះស្ថាននោះត្រូវចាត់ទុកជាសហគ្រាស។
- *និយោជក* សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលសាធារណៈ ឬឯកជន ដែលដឹកនាំគ្រប់គ្រង និងប្រើកម្មករនិយោជិតម្នាក់ ឬច្រើននាក់ ទោះជាមិនជាប់លាប់ក្តីដោយមានផ្តល់ប្រាក់កម្រៃជាទៀងទាត់ និងម្ចាស់ផ្ទះដែលប្រើអ្នកបម្រើក្នុងផ្ទះក៏ត្រូវចាត់ទុកជានិយោជកដែរ។

- *កម្មករនិយោជិត* សំដៅដល់កម្មករនិយោជិតគ្រប់ប្រភេទ និងគ្រប់សញ្ជាតិនៃវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដែលរួមមានបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។
- *ភាគទាន* សំដៅដល់ប្រាក់ដែលសមាជិក **ប.ស.ស.** និយោជក ឬរដ្ឋបានបង់មក **ប.ស.ស.** ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម ដែលជាទូទៅគិតជាភាគរយនៃប្រាក់ឈ្នួលឬប្រាក់បៀវត្សរបស់សមាជិកម្នាក់ៗទុកសម្រាប់ការចំណាយក្នុងការផ្តល់គាវកាលិកដល់សមាជិក និងការចំណាយប្រតិបត្តិការនៃរបបសន្តិសុខសង្គមតាមផ្នែកនីមួយៗ។

## ជំពូកទី២
## ការចុះបញ្ជី និងការបិទបញ្ជីសហគ្រាស គ្រឹះស្ថាន
## ផ្នែកទី១
## ការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន

**ប្រការ៤ ..**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលស្ថិតនៅក្នុងវិសាលភាពអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម ត្រូវមានកាតព្វកិច្ចមកចុះបញ្ជីសហគ្រាស គ្រឹះស្ថានរបស់ខ្លួននៅ **ប.ស.ស.** តាមការកំណត់ដូចខាងក្រោម៖

- ចំពោះនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលកំពុងដំណើរការ និងមិនទាន់បានចុះបញ្ជីនៅ **ប.ស.ស.** ត្រូវមានកាតព្វកិច្ចមកចុះបញ្ជីរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីប្រកាសនេះចូលជាធរមាន។
- ចំពោះនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលបើកដំណើរការថ្មី ក្រោយពីប្រកាសនេះបានចូលជាធរមានត្រូវមានកាតព្វកិច្ចមកចុះបញ្ជីនៅ **ប.ស.ស.** រយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមបើកសហគ្រាស គ្រឹះស្ថាន។
- ចំពោះនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជីនៅ **ប.ស.ស.** ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពរួច មិនតម្រូវឱ្យចុះបញ្ជីសហគ្រាស គ្រឹះស្ថាន ឡើងវិញទេ។

**ប្រការ៥ ..**

ការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន ត្រូវធ្វើតាមទម្រង់ "**បញ្ជីកាសហគ្រាស គ្រឹះស្ថាន**" ឬហៅថាទម្រង់ "១.០១" ដែលមានចែងក្នុងឧបសម្ព័ន្ធ១ នៃប្រកាសនេះ។ ឯកសារភ្ជាប់សម្រាប់ចុះបញ្ជីមានដូចខាងក្រោម៖

- ចំពោះនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវភ្ជាប់មកជាមួយទម្រង់ "១.០១" នូវវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មដែលចេញដោយក្រសួងពាណិជ្ជកម្ម ឬលិខិតឧបករណ៍គតិយុត្តសមមូលដទៃទៀត និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់និយោជក ឬអ្នកតំណាង។

- ចំពោះនិយោជក ឬម្ចាស់ផ្ទះដែលមានអ្នកបម្រើក្នុងផ្ទះ ត្រូវភ្ជាប់មកជាមួយទម្រង់ "១.០១" នូវសៀវភៅស្នាក់នៅ ឬលិខិតតួបករណ៍គតិយុត្តសមមូលដទៃទៀត និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់និយោជក។

## ផ្នែកទី២
## អត្តសញ្ញាណកម្មសហគ្រាស គ្រឹះស្ថាន

**ប្រការ៦.-**

**ប.ស.ស.** ត្រូវផ្តល់ "វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន" ជូនទៅនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីរួច។ វិញ្ញាបនបត្រនេះចាំបាច់ត្រូវមានចុះលេខ "**អត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន**" និងកាលបរិច្ឆេទចុះបញ្ជី។ និយោជកត្រូវដាក់តាំងវិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន នៅនឹងការិយាល័យបើកប្រាក់ឈ្នួលរបស់សហគ្រាស គ្រឹះស្ថាន។

## ផ្នែកទី៣
## ការមិនព្យួរសហគ្រាស គ្រឹះស្ថាន

**ប្រការ៧.-**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវមានកាតព្វកិច្ចជូនដំណឹងមក **ប.ស.ស.** ក្នុងពេលយ៉ាងយូរ ៣០(សាមសិប)ថ្ងៃ មុនកាលបរិច្ឆេទនៃការបិទ ការព្យួរ ការបើកដំណើរការឡើងវិញ ការប្តូរទីតាំងសហគ្រាស គ្រឹះស្ថាន ឬការកែប្រែស្ថានភាពគតិយុត្តនៃនិយោជក ដោយត្រូវបំពេញតាមទម្រង់ដែលកំណត់ដោយអគ្គនាយក **ប.ស.ស.**។

## ជំពូកទី៣
## ការចុះបញ្ជីកម្មករនិយោជិត
## ផ្នែកទី១
## ការចុះបញ្ជីកម្មករនិយោជិត

**ប្រការ៨.-**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវមានកាតព្វកិច្ចចុះបញ្ជីកម្មករនិយោជិតមកក្នុង **ប.ស.ស.** យ៉ាងយូរ៣(បី)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចូលបម្រើការងារ លើកលែងតែកម្មករនិយោជិតដែលមានប័ណ្ណសមាជិក **ប.ស.ស.** រួចហើយ។

**ប្រការ៩.-**

ការចុះបញ្ជីកម្មករនិយោជិត ត្រូវធ្វើតាមទម្រង់ "**សណាកប័ត្រព័ត៌មានសមាជិក ប.ស.ស.**" ឬហៅថាទម្រង់ "១.០២" ដែលមានចែងក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ ។ ឯកសារភ្ជាប់សម្រាប់ចុះបញ្ជីមានដូចខាងក្រោម៖

- ត្រូវមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលិខិតបញ្ជាក់ការងារពីនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ចំពោះកម្មករនិយោជិតសញ្ជាតិខ្មែរ

- ត្រូវមានលិខិតឆ្លងដែន និងលិខិតបញ្ជាក់ការងារពីនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ចំពោះកម្មករនិយោជិតជនបរទេស។

## ផ្នែកទី២
## អត្តសញ្ញាណកម្មករនិយោជិត

**ប្រការ១០ .-**

**ប.ស.ស.** ត្រូវផ្តល់ "ប័ណ្ណសមាជិក ប.ស.ស." ដែលបញ្ជាក់ពីអត្តសញ្ញាណសមាជិក និងលេខអត្តសញ្ញាណសមាជិក **ប.ស.ស.** ជូនកម្មករនិយោជិតដោយឥតគិតថ្លៃ។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ឬសមាជិក **ប.ស.ស.** ត្រូវស្នើសុំប័ណ្ណទុតិយតាក្នុងករណីប័ណ្ណសមាជិក **ប.ស.ស.** ខូចឬបាត់បង់។ ការស្នើសុំនេះ ត្រូវធ្វើឡើងតាមទម្រង់ដែលកំណត់ដោយអគ្គនាយក **ប.ស.ស.**។ ការផ្តល់ប័ណ្ណទុតិយតានេះ សាមីជនត្រូវបង់ប្រាក់ចំនួន ៥,០០០ (ប្រាំពាន់) រៀល ជូនទៅ **ប.ស.ស.**។

## ជំពូកទី៤
## ការបង់ភាគទាន
## ផ្នែកទី១
## ការបង់ភាគទាន

**ប្រការ១១ .-**

ការបង់ភាគទានត្រូវធ្វើឡើងជាប្រចាំខែ។ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ត្រូវមានកាតព្វកិច្ចប្រមូលនិងបង់ភាគទានដែលជាចំណែករបស់ខ្លួន និងជាចំណែករបស់កម្មករនិយោជិត មកក្នុងគណនី **ប.ស.ស.** នៅតាមធនាគារដែលបានកំណត់យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥(ដប់ប្រាំ)នៃខែបន្ទាប់។

ក្នុងករណីនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានមានលទ្ធភាពបង់ភាគទានប្រចាំឆ្នាំត្រូវស្នើសុំមក **ប.ស.ស.**។ ការបង់ភាគទានប្រចាំឆ្នាំនេះ ត្រូវធ្វើឡើងនៅខែបន្ទាប់គិតចាប់ពីកាលបរិច្ឆេទនៃខែដែលបានស្នើសុំបង់ភាគទាន។ ការបង់ភាគទានធ្វើឡើងជាប្រចាំឆ្នាំ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវបង់ភាគទានតាមឆ្នាំនៃប្រតិទិន។ **ប.ស.ស.** ត្រូវធ្វើការកែតម្រូវទូទាត់ចំនួនភាគទាននៅដើមឆ្នាំបន្ទាប់។

ការមិនព្រមបង់ភាគទាន ឬការបង់ភាគទានក្រោយថ្ងៃទី៣០ ត្រូវចាត់ទុកជាការមិនបង់ភាគទាន។

ក្នុងករណីដែលសហគ្រាស គ្រឹះស្ថាន បើកប្រាក់ឈ្នួលជារូបិយប័ណ្ណបរទេស ប្រាក់ឈ្នួលប្រចាំខែត្រូវគិតជាប្រាក់រៀល តាមអត្រាប្តូរប្រាក់មធ្យមប្រចាំខែដោយផ្អែកតាមអត្រាប្តូរប្រាក់ធនាគារជាតិនៃកម្ពុជា ដែលជូនដំណឹងដោយ **ប.ស.ស.**។

**ប្រការ១២ .-**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវបង់ភាគទានចូលទៅក្នុងគណនីរបស់ **ប.ស.ស.** ដែលស្ថិតនៅក្នុងធនាគារដែលបានកំណត់។ ការបង់ភាគទានត្រូវបានអនុវត្តតាមរបៀបដូចខាងក្រោម៖

- បង់ផ្ទាល់នៅធនាគារដែលបានកំណត់។ ការបង់ភាគទានរបៀបនេះ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវបំពេញតាមទម្រង់ "**លិខិតប្រកាសបង់ភាគទានរបបសន្តិសុខសង្គម**" ឬហៅថាទម្រង់ "**១.០៤**" ដែលមានចែងក្នុងឧបសម្ព័ន្ធ៤ នៃប្រកាសនេះ
- បង់តាមរយៈសេវាកម្មអ៊ីនធឺណែតប៊ែងឃីង ការចំណាយលើសេវាកម្មនេះ គឺជាបន្ទុករបស់និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន
- បង់តាមរយៈសេវាកម្មដទៃផ្សេងទៀតតាមការណែនាំរបស់ **ប.ស.ស**.។

បេឡាជាតិសន្តិសុខសង្គម ត្រូវចេញ "**លិខិតបញ្ជាក់ការបង់ភាគទាន**" បន្ទាប់ពីបានទទួលឯកសារដូចខាងក្រោម៖

- លិខិតប្រកាសបង់ភាគទានរបបសន្តិសុខសង្គម (ទម្រង់ ១.០៤)
- បង្កាន់ដៃបង់ភាគទាននៅធនាគារ
- របាយការណ៍ចំនួនកម្មករនិយោជិត (ទម្រង់ ១.០៣ ឬ ទម្រង់អេឡិចត្រូនិក) និង
- តារាងបើកប្រាក់ឈ្នួល ឬឯកសារចាំបាច់ផ្សេងៗ។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវយកឯកសារដូចបានរៀបរាប់ខាងលើមកដាក់ដោយផ្ទាល់នៅ **ប.ស.ស**. ឬផ្ញើតាមសារអេឡិចត្រូនិក contribution@nssf.gov.kh។

## ផ្នែកទី២
## របាយការណ៍កម្មករនិយោជិត

**ប្រការ១៣**.-

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលបង់ភាគទានប្រចាំខែ ត្រូវមានកាតព្វកិច្ចផ្តល់របាយការណ៍អំពីចំនួនកម្មករនិយោជិតទាំងអស់ទៅ **ប.ស.ស**. យ៉ាងយូរបំផុតត្រឹមថ្ងៃទី២០(ម្ភៃ)នៃខែបន្ទាប់។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលបង់ភាគទានប្រចាំឆ្នាំ ត្រូវមានកាតព្វកិច្ចផ្តល់របាយការណ៍អំពីចំនួនកម្មករនិយោជិតទាំងអស់ទៅ **ប.ស.ស**. តាមកាលកំណត់ដូចខាងក្រោម៖

១.ក្នុងករណីមិនមានចលនាចេញ-ចូលបុគ្គលិករបស់ខ្លួន និយោជកត្រូវរាយការណ៍រៀងរាល់ ១២(ដប់ពីរ)ខែម្តង។

២.ក្នុងករណីមានចលនាចេញ-ចូលបុគ្គលិករបស់ខ្លួន និយោជកត្រូវរាយការណ៍រៀងរាល់១៥ (ដប់ប្រាំ)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃបម្រែបម្រួល។

របាយការណ៍អំពីចំនួនកម្មករនិយោជិត ត្រូវបញ្ជាក់អំពីចំនួនកម្មករនិយោជិតទាំងអស់ដែលមាននៅក្នុងខែដែលត្រូវរាយការណ៍ ដោយត្រូវធ្វើតាមទម្រង់ "**របាយការណ៍កម្មករនិយោជិត**" ឬហៅថាទម្រង់"១.០៣" ឬ "**ទម្រង់អេឡិចត្រូនិក**" ដែលមានចែងក្នុងឧបសម្ព័ន្ធ៣ នៃប្រកាសនេះ។

**ប្រការ១៤**.-

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវផ្តល់សៀវភៅបើកប្រាក់ ឬតារាងបើកប្រាក់ឈ្នួលតាមខែនីមួយៗ បញ្ជីឈ្មោះកម្មករនិយោជិត និងឯកសារពាក់ព័ន្ធផ្សេងៗជូន **ប.ស.ស**. ដើម្បីត្រួតពិនិត្យនៅពេលចាំបាច់។

## ជំពូកទី៥
## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ១៥.-**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ដែលត្រូវចុះបញ្ជី និងបង់ភាគទានរបបសន្តិសុខសង្គម ត្រូវមានកាតព្វកិច្ចអនុវត្តក្នុងពេលដំណាលគ្នាទាំងផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធន។

**ប្រការ១៦.-**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជីផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពរួចហើយ ការចាប់ផ្ដើមបង់ភាគទានដំបូងសម្រាប់ផ្នែកប្រាក់សោធន ត្រូវកំណត់ដោយអគ្គនាយក **ប.ស.ស**.។

**ប្រការ១៧.-**

សមាជិក **ប.ស.ស**. ដែលមានអាយុចាប់ពី៦០(ហុកសិប)ឆ្នាំឡើង និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន មិនមានកាតព្វកិច្ចបង់ភាគទានចំពោះផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ចទៀតទេ។

កម្មករនិយោជិតដែលជាសមាជិក **ប.ស.ស**. ដែលមានអាយុចាប់ពី៦០(ហុកសិប)ឆ្នាំឡើង គិតត្រឹមថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ មានសិទ្ធិស្នើសុំចុះបញ្ជី និងបង់ភាគទានផ្នែកប្រាក់សោធនតាមរបបភាគទានស្ម័គ្រចិត្ត ដើម្បីទទួលបានសោធនជរាភាពអយ្យកប្បញ្ញត្តិ។ ការស្នើសុំនេះមានរយៈពេល១២(ដប់ពីរ)ខែ គិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃប្រកាសនេះ។

**ប្រការ១៨.-**

ប្រាក់ឈ្នួលជាប់ភាគទានដែលត្រូវយកមកគណនាភាគទានសម្រាប់របបសន្តិសុខសង្គមផ្នែកនីមួយៗ ត្រូវអនុលោមតាមអនុក្រឹត្យលេខ១៤៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ស្ដីពីការកំណត់ប្រាក់ឈ្នួល ឬប្រាក់បៀវត្សជាប់ភាគទាន។

**ប្រការ១៩.-**

សមាជិក **ប.ស.ស**. ដែលមានបំណងចុះបញ្ជី និងបង់ភាគទានក្នុងរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនតាមរបបភាគទានស្ម័គ្រចិត្ត ត្រូវអនុវត្តតាមទម្រង់ដែលកំណត់ដោយអគ្គនាយក **ប.ស.ស**.។

## ជំពូកទី៦
## ទោសប្បញ្ញត្តិ

**ប្រការ២០.-**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលមិនចុះបញ្ជីសហគ្រាស គ្រឹះស្ថាន ឬមិនចុះបញ្ជីកម្មករនិយោជិត ឬមិនបង់ភាគទានក្នុងរបបសន្តិសុខសង្គមនីមួយៗ ឬរាយការណ៍ចំនួនកម្មករនិយោជិតមិនគ្រប់តាមចំនួនជាក់ស្ដែង ត្រូវទទួលការពិន័យអន្តរការណ៍ដូចមានកំណត់នៅក្នុងមាត្រា៩៨ នៃច្បាប់ស្ដីពីរបបសន្តិសុខសង្គម។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**ប្រការ២១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ២២.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបេឡាជាតិសន្តិសុខសង្គម និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៧កើត ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ២២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ ......១៦៥/២២......ក.ប/ប្រ.ក.ប.ស.ស

# ប្រកាស

## ស្តីពី

## របបបង់ និងនីតិវិធីនៃការផ្តល់វិភាគទានបុព្វលាភនៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៨៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)

- បានឃើញអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះមានគោលបំណងកំណត់បែបបទ និងនីតិវិធីនៃការផ្តល់វិភាជន៍បូជាសពនៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដើម្បីធានាបាននូវប្រសិទ្ធភាព និងប្រសិទ្ធផលនៃការអនុវត្តរបបសន្តិសុខសង្គម។

**ប្រការ២ .-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះវិភាជន៍បូជាសពនៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។ វិភាជន៍បូជាសពគិតទាំងអ្នកដែលជាសមាជិក **ប.ស.ស**. ទាំងសមាជិកជាកាតព្វកិច្ច និងសមាជិកស្ម័គ្រចិត្ត។

**ប្រការ៣ .-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងប្រកាសនេះមានកំណត់និយមន័យដូចខាងក្រោម៖

- *សិទ្ធិវន្តនៃវិភាជន៍បូជាសព* សំដៅដល់បុគ្គលដែលមានសិទ្ធិទទួលបានវិភាជន៍បូជាសពមានជាអាទិ៍ សិទ្ធិវន្តនៃសោធនឧត្តរជីវី ឬអ្នកចាត់ចែងបូជាសព។
- *សោធនិកជរាភាព* សំដៅដល់បុគ្គលដែលបានបំពេញលក្ខខណ្ឌទទួលបានប្រាក់សោធនជរាភាព។
- *សោធនិកទុព្វលភាព* សំដៅដល់បុគ្គលដែលបានបំពេញលក្ខខណ្ឌទទួលបានប្រាក់សោធនទុព្វលភាព។
- *វិភាជន៍បូជាសព* សំដៅដល់ប្រាក់ឧបត្ថម្ភសម្រាប់ការចាត់ចែងបូជាសពសោធនិកជរាភាព ឬសោធនិកទុព្វលភាព។

## ជំពូកទី២
## ការផ្តល់វិភាជន៍បូជាសព

**ប្រការ៤ .-**

វិភាជន៍បូជាសពផ្នែកប្រាក់សោធន ត្រូវកំណត់ស្មើនឹង៥(ប្រាំ)ខែនៃប្រាក់សោធនចុងក្រោយរបស់សាមីខ្លួន។ វិភាជន៍បូជាសពនៃសោធនិកជរាភាព ឬសោធនិកទុព្វលភាព ត្រូវកំណត់អប្បបរមាស្មើនឹង ២,០០០,០០០ (ពីរលាន)រៀល។

**ប្រការ៥ ..**

សិទ្ធិវន្តនៃវិភាជន៍បុជាសពត្រូវបំពេញទម្រង់ទាមទារ "**តាវកាលិកផ្នែកប្រាក់សោធន**" និងភ្ជាប់ជាមួយនូវសេចក្តីចម្លងសំបុត្រមរណភាព ឬឯកសារផ្សេងៗដែលទទួលស្គាល់ដោយ **ប.ស.ស.**។

ទម្រង់នៃការទាមទារ "**តាវកាលិកផ្នែកប្រាក់សោធន**" ត្រូវកំណត់ដោយអគ្គនាយក **ប.ស.ស.**។

សិទ្ធិវន្តនៃវិភាជន៍បុជាសពដែលចាត់ចែងបុជាសពរបស់សោធនិកជរាភាព ឬសោធនិកទុព្វលភាពត្រូវបំពេញទម្រង់ទាមទារវិភាជន៍បុជាសពក្នុងអំឡុងពេល៣(បី)ខែបន្ទាប់ពីកាលបរិច្ឆេទទទួលមរណភាពរបស់សោធនិក។

**ប្រការ៦ ..**

សិទ្ធិវន្តនៃវិភាជន៍បុជាសព ឬអ្នកចាត់ចែងបុជាសព ត្រូវជូនដំណឹងមក **ប.ស.ស.** ក្នុងរយៈពេលយ៉ាងយូរ ២(ពីរ)សប្តាហ៍គិតចាប់ពីកាលបរិច្ឆេទនៃសោធនិកជរាភាព ឬសោធនិកទុព្វលភាពទទួលមរណភាព។

វិភាជន៍បុជាសពដែលត្រូវផ្តល់ជូនដល់សិទ្ធិវន្តនៃសោធនឧត្តរជីវី ត្រូវទូទាត់ជាមួយតាវកាលិកសោធនជរាភាព ឬសោធនទុព្វលភាពដែលបានបើកឱ្យដល់សាមីជនក្រោយទទួលមរណភាព។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**ប្រការ៧ ..**

នាយកឧទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបេឡាជាតិសន្តិសុខសង្គម និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៧កើត ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ ...១៧០/២២... ក.ប/ប្រ.ក.ប.ស.ស

**ប្រកាស**

**ស្តីពី**

**កាលបរិច្ឆេទនៃការចាប់ផ្តើមបង់ភាគទាននៃរបបសន្តិសុខសង្គម**
**ផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច និងរបបភាគទានដោយស្ម័គ្រចិត្ត**

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- យោងតាមការចាំបាច់របស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ




អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ (០២៣) ៨៨ ៨៣ ៨៨ និងទូរសារ (០២៣) ៨៨ ២៧ ២៥

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីកាលបរិច្ឆេទនៃការចាប់ផ្តើមបង់ភាគទាននៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច និងរបបភាគទានដោយស្ម័គ្រចិត្ត ដូចមានចែងក្នុងមាត្រា៣៣ នៃអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**ប្រការ២.-**

កាលបរិច្ឆេទនៃការចាប់ផ្តើមបង់ភាគទាននៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច និងរបបភាគទានដោយស្ម័គ្រចិត្ត ត្រូវដាក់ឱ្យអនុវត្តចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២២ តទៅ។

**ប្រការ៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៧កើត ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

នស/រកម/១១១៩/ ០១៨

# ព្រះរាជក្រម

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីរបបសន្តិសុខសង្គម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ច្បាប់

## ស្ដីពី

# របបសន្តិសុខសង្គម



## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ _ គោលបំណង**

ច្បាប់នេះមានគោលបំណងបង្កើតឲ្យមានរបបសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាឲ្យមានសមធម៌និងសាមគ្គីធម៌សង្គម និងដើម្បីលើកកម្ពស់សុខុមាលភាពនិងជីវភាពរបស់ប្រជាពលរដ្ឋ។

**មាត្រា២ _ គោលដៅ**

ច្បាប់នេះមានគោលដៅកំណត់អំពីគោលការណ៍ទូទៅ បែបបទ យន្តការអនុវត្ត និងប្រព័ន្ធគ្រប់គ្រងរបបសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមានផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកនិកម្មភាពការងារ។

**មាត្រា៣ _ វិសាលភាព**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះបុគ្គលទាំងអស់ដូចខាងក្រោម៖

១. បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈរួមមាន៖
- មន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដែលបម្រើការងារនៅតាមក្រសួង ស្ថាប័ន អង្គភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- មន្ត្រីរាជការដែលស្ថិតនៅក្រោមច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ លើកលែងផ្នែកប្រាក់សោធន
- មន្ត្រីរាជការដែលបម្រើការងារនៅក្នុងស្ថាប័នតុលាការ
- មន្ត្រីនគរបាលជាតិនិងមន្ត្រីពន្ធនាគារ ចំពោះតែគាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រក្នុងផ្នែកថែទាំសុខភាព
- មន្ត្រីដែលបម្រើការងារនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- មន្ត្រីរាជការដែលបម្រើការងារនៅក្នុងអាជ្ញាធរសវនកម្មជាតិ
- អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន
- មន្ត្រីជាប់កិច្ចសន្យាដែលបម្រើការនៅតាមក្រសួង ស្ថាប័ន អង្គភាព នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដែលមានការទទួលស្គាល់ដោយក្រសួងមុខងារសាធារណៈ
- បុគ្គលនៃវិស័យសាធារណៈផ្សេងទៀត ដែលត្រូវកំណត់ដោយអនុក្រឹត្យ។

២. បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ។

៣. បុគ្គលស្វ័យនិយោជន៍។

ច្បាប់នេះមិនមានវិសាលភាពអនុវត្តលើយោធិននៃកងយោធពលខេមរភូមិន្ទ ដែលមានកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា៤ .. និយមន័យ**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះមានកំណត់និយមន័យដូចមានចែងនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២

## គោលការណ៍ទូទៅនៃរបបសន្តិសុខសង្គម

**មាត្រា៥ .. ផ្នែកប្រាក់សោធន**

របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលនៃវិស័យសាធារណៈ ត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលរដ្ឋនិងបុគ្គលនៃវិស័យសាធារណៈមានកាតព្វកិច្ចរួមគ្នាក្នុងការបង់ភាគទាន។

របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលនិយោជកនិងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ មានកាតព្វកិច្ចរួមគ្នាក្នុងការបង់ភាគទាន។

របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលស្វ័យនិយោជន៍ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦ .. ផ្នែកថែទាំសុខភាព**

របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ ត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលរដ្ឋ បុគ្គលនៃវិស័យសាធារណៈ អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន មានកាតព្វកិច្ចរួមគ្នាក្នុងការបង់ភាគទាន។

របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលនិយោជកនិងបុគ្គលទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ មានកាតព្វកិច្ចរួមគ្នាក្នុងការបង់ភាគទាន។

របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់បុគ្គលស្វ័យនិយោជន៍ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៧ .. ផ្នែកហានិភ័យការងារ**

របបសន្តិសុខសង្គម ផ្នែកហានិភ័យការងារសម្រាប់បុគ្គលនៃវិស័យសាធារណៈត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលរដ្ឋត្រូវមានកាតព្វកិច្ចក្នុងការបង់ភាគទានផ្នែកនេះ។

របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវា

សមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលនិយោជក ត្រូវមានកាតព្វកិច្ចក្នុងការបង់ភាគទានផ្នែកនេះ។

**មាត្រា៨ .- ផ្នែកនិកម្មភាពការងារ**

របបសន្តិសុខសង្គមផ្នែកនិកម្មភាពការងារត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ច ដែលនិយោជកនិងកម្មករនិយោជិតត្រូវមានកាតព្វកិច្ចរួមគ្នាក្នុងការបង់ភាគទានផ្នែកនេះ។

**មាត្រា៩ .- ចំណែកនៃភាគទានសម្រាប់របបភាគទានជាកាតព្វកិច្ច**

ចំណែកនៃភាគទានរបស់បុគ្គលនៃវិស័យសាធារណៈនិងបុគ្គលទាំងឡាយដែលស្ថិត នៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះសម្រាប់របបភាគទានជាកាតព្វកិច្ច ក្នុងផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព និងនិកម្មភាពការងារមិនត្រូវលើសពី៥០%(ហាសិបភាគរយ)នៃភាគទានសរុបឡើយ។

ប្រាក់ឈ្នួលឬប្រាក់បៀវត្សជាប់ភាគទានត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៣

## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា១០ .- ក្រុមប្រឹក្សាជាតិគាំពារសង្គម**

រាល់ប្រតិបត្តិការសន្តិសុខសង្គមត្រូវស្ថិតនៅក្រោមការសម្របសម្រួល តាមដាន និង តម្រង់ទិសក្នុងកម្រិតគោលនយោបាយនិងយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គមត្រូវកំណត់ដោយ ព្រះរាជក្រឹត្យ។

**មាត្រា១១ .- និយ័តករសន្តិសុខសង្គម**

ត្រូវបានបង្កើតនិយ័តករសន្តិសុខសង្គមដែលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

១. កំណត់បទប្បញ្ញត្តិប្រុងប្រយ័ត្ន ស្តង់ដារប្រតិបត្តិការ វិធានចាំបាច់នានា និងគោលការណ៍ណែនាំស្តីពីវិនិយោគមូលនិធិសន្តិសុខសង្គម។

២. តាមដានស្ថានភាពហិរញ្ញវត្ថុរបស់ស្ថាប័នប្រតិបត្តិករសន្តិសុខសង្គម។

៣. បង្កើតយន្តការការពារសមាជិកនិងផ្សះផ្សាវិវាទនៅពេលមានទំនាស់។

៤. ត្រួតពិនិត្យអនុលោមភាព ដើម្បីធានាថាប្រតិបត្តិការនៅក្នុងការផ្តល់សេវាសន្តិសុខសង្គមប្រព្រឹត្តទៅដោយតម្លាភាព គណនេយ្យភាព និងចីរភាពហិរញ្ញវត្ថុ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់និយ័តករសន្តិសុខសង្គមត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១២ .- បេឡាជាតិសន្តិសុខសង្គម**

បេឡាជាតិសន្តិសុខសង្គមដែលសរសេរជាអក្សរកាត់ថា **ប.ស.ស.** ជាស្ថាប័នប្រតិបត្តិករ តែមួយគត់ដែលធ្វើប្រតិបត្តិការរបបសន្តិសុខសង្គម ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ។

**ប.ស.ស.** ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលត្រូវបង្កើតដោយព្រះរាជក្រឹត្យ ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម និងស្ថិតក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## មាត្រា១៣ _ ភារកិច្ចរបស់បេឡាជាតិសន្តិសុខសង្គម

**ប.ស.ស.** មានភារកិច្ចដូចខាងក្រោម៖

១. គ្រប់គ្រងនិងចាត់ចែងផ្នែកទាំងអស់នៃរបបសន្តិសុខសង្គមដែលកំណត់ដោយច្បាប់នេះ។

២. ធានាផ្តល់តាវកាលិកសន្តិសុខសង្គមសម្រាប់សមាជិក **ប.ស.ស.** ក្នុងគោលដៅជួយសម្រាលការលំបាកក្នុងជីវភាពនៅពេលជួបប្រទះហានិភ័យជាយថាហេតុនានាជាអាទិ៍ ជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ និកម្មភាពការងារ មាតុភាព ជំងឺ ឬគ្រោះថ្នាក់ ព្រមទាំងយថាភាពដទៃផ្សេងទៀត។

៣. ប្រមូលនិងគ្រប់គ្រងភាគទានរបបសន្តិសុខសង្គមនៃផ្នែកនីមួយៗព្រមទាំងប្រភពចំណូលដទៃផ្សេងទៀត។

៤. ចុះបញ្ជីនិងគ្រប់គ្រងលេខសម្គាល់សមាជិក **ប.ស.ស.**។

៥. ត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិនៃច្បាប់នេះ ដោយសហគ្រាស គ្រឹះស្ថាន ឬអង្គភាពពាក់ព័ន្ធដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ **ប.ស.ស.**។

៦. អប់រំ ផ្សព្វផ្សាយ និងត្រួតពិនិត្យការអនុវត្តវិធានការបង្ការហានិភ័យការងារ និងបង្ការសុខភាពសម្រាប់សមាជិក **ប.ស.ស.**។

៧. សិក្សា ស្រាវជ្រាវ និងអង្កេតហានិភ័យការងារ។

៨. សិក្សាស្រាវជ្រាវនិងរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការកំណត់ប្រភេទជំងឺវិជ្ជាជីវៈ។

៩. ចុះកិច្ចព្រមព្រៀងនិងត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាល។

១០. សិក្សា វិភាគ និងវាយតម្លៃហិរញ្ញវត្ថុលើផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម។

១១. អនុវត្តសកម្មភាពពាក់ព័ន្ធនឹងសុខភាពនិងសង្គម ដែលពាក់ព័ន្ធនឹងអត្ថប្រយោជន៍នៃសមាជិក **ប.ស.ស.**។

១២. ចាត់ចែងនិងគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម។

## មាត្រា១៤ _ ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម

**ប.ស.ស.** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម | ប្រធាន |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | សមាជិក |
| - តំណាងក្រសួងមុខងារសាធារណៈ១រូប | សមាជិក |
| - តំណាងក្រសួងសុខាភិបាល១រូប | សមាជិក |
| - តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា១រូប | សមាជិក |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី១រូប | សមាជិក |
| - តំណាងនិយោជក២រូប | សមាជិក |
| - តំណាងសមាជិក **ប.ស.ស.** ២រូប | សមាជិក |
| - អគ្គនាយក **ប.ស.ស.** | សមាជិកអចិន្ត្រៃយ៍។ |

**មាត្រា១៥ ៈ អង្គភាពប្រតិបត្តិនៃបេឡាជាតិសន្តិសុខសង្គម**

**ប.ស.ស.** ត្រូវចាត់ចែង គ្រប់គ្រងការងារប្រចាំថ្ងៃដោយអគ្គនាយក១(មួយ)រូបដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ និងអគ្គនាយករងមួយចំនួនជាជំនួយការ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ **ប.ស.ស.** ដែលមានកំណត់ក្នុងច្បាប់នេះ ជាសមត្ថកិច្ចរបស់អធិការសន្តិសុខសង្គម។ ការតែងតាំងនិងតួនាទីភារកិច្ចរបស់អធិការសន្តិសុខសង្គម ត្រូវកំណត់ដោយអនុក្រឹត្យ។

បុគ្គលិករបស់ **ប.ស.ស.** ជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដែលត្រូវបានផ្ទេរឬជ្រើសរើសថ្មីតាមសំណើរបស់អគ្គនាយកនៃ **ប.ស.ស.** និងបុគ្គលិកជាប់កិច្ចសន្យាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុងនិងលក្ខន្តិកៈបុគ្គលិកនៃ **ប.ស.ស.** ស្របតាមច្បាប់ស្តីពីការងារ។

**មាត្រា១៦ ៈ ការគ្រប់គ្រងមូលនិធិសន្តិសុខសង្គម**

ការគ្រប់គ្រងមូលនិធិរបស់ផ្នែកនីមួយៗនៃរបបសន្តិសុខសង្គមត្រូវស្ថិតនៅក្រោមក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃ **ប.ស.ស.**។ ក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃ **ប.ស.ស.** ត្រូវរៀបចំគោលការណ៍នៃការគ្រប់គ្រងមូលនិធិ ការគ្រប់គ្រងការវិនិយោគ ផែនការវិនិយោគ និងកញ្ចប់វិនិយោគដាក់ជូនក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** ពិនិត្យនិងអនុម័តដោយអនុលោមតាមគោលការណ៍ណែនាំស្តីពីការវិនិយោគរបស់និយ័តករសន្តិសុខសង្គម ដើម្បីស្នើសុំការសម្រេចចុងក្រោយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្នុងការបំពេញតួនាទីរបស់ខ្លួន ក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃ **ប.ស.ស.** ត្រូវធ្វើរបាយការណ៍ស្តីពីការរក្សានិងការគ្រប់គ្រងមូលនិធិសន្តិសុខសង្គមគ្រប់ផ្នែកជូនក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** និយ័តករសន្តិសុខសង្គម និងអគ្គនាយកនៃ **ប.ស.ស.** ជាទៀងទាត់។

សមាសភាព គុណវុឌ្ឍិ ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គម ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៤
## របបសន្តិសុខសង្គមផ្នែកប្រាក់សោធន
### ផ្នែកទី១
### គោលការណ៍រួម

**មាត្រា១៧ ៈ បុគ្គលត្រូវគាំពារ**

បុគ្គលដែលត្រូវគាំពារក្នុងផ្នែកប្រាក់សោធនមានដូចខាងក្រោម៖

១. បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ។

២. បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ។

៣. បុគ្គលស្វ័យនិយោជន៍។

**មាត្រា១៨ .. គាវកាលិកផ្នែកប្រាក់សោធន**

គាវកាលិកផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច រួមមាន សោធនជរាភាព សោធនទុព្វលភាព សោធនឧត្តរជីវី និងវិភាជន៍មួយដង។

គាវកាលិកផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៩ .. ភាគទានផ្នែកប្រាក់សោធន**

អត្រាភាគទានផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវកំណត់ដោយអនុក្រឹត្យ។

អត្រាភាគទានផ្នែកប្រាក់សោធនសម្រាប់បុគ្គលស្វ័យនិយោជន៍ត្រូវកំណត់ដោយអនុក្រឹត្យ។

អត្រាភាគទានផ្នែកប្រាក់សោធនត្រូវដំឡើងតាមវិធីសាស្រ្តបុព្វលាភជណ្តើរឬវិធីសាស្រ្តសមស្របមួយដែលអនុម័តដោយក្រុមប្រឹក្សាជាតិគាំពារសង្គម។

**មាត្រា២០ .. សិទ្ធិវន្តនៃសោធនឧត្តរជីវី**

សិទ្ធិវន្តនៃសោធនឧត្តរជីវី រួមមាន សហព័ទ្ធនិងកូននៅក្នុងបន្ទុកផ្ទាល់របស់សាមីជនដែលត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. មិនមានប្រកបការងារឬមុខរបរមានប្រាក់ចំណូលលើបន្ទាត់នៃភាពក្រីក្រ។

២. ចំពោះសហព័ទ្ធ ត្រូវចុះសំបុត្រអាពាហ៍ពិពាហ៍មុនកាលបរិច្ឆេទដែលសាមីជនធ្លាក់ខ្លួនឈឺឬគ្រោះថ្នាក់ជាយថាហេតុ ដែលបណ្តាលឲ្យទទួលមរណភាព។

៣. ចំពោះកូន ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មិនទាន់រៀបអាពាហ៍ពិពាហ៍
- មានអាយុមិនលើសពី១៨(ដប់ប្រាំបី)ឆ្នាំ

កូនពិការឬមានជំងឺរ៉ាំរ៉ៃ ហើយមិនអាចប្រកបការងារឬមុខរបរដែលមានប្រាក់ចំណូលត្រូវផ្តល់សោធនឧត្តរជីវីអស់មួយជីវិត។ ការកំណត់ស្ថានភាពពិការឬជំងឺរ៉ាំរ៉ៃត្រូវបញ្ជាក់ដោយគ្រូពេទ្យឯកទេស និងមានការយល់ព្រមពីក្រុមប្រឹក្សាវេជ្ជសាស្រ្តនៃ**ប.ស.ស.**។ ក្រុមប្រឹក្សាវេជ្ជសាស្រ្តនៃ **ប.ស.ស.** អាចវាយតម្លៃឡើងវិញលើស្ថានភាពពិការឬជំងឺរ៉ាំរ៉ៃ ក្នុងករណីចាំបាច់។

សិទ្ធិទទួលបានសោធនឧត្តរជីវីត្រូវផុតរលត់ក្នុងករណីដូចខាងក្រោម៖

- សិទ្ធិវន្តទទួលមរណភាព
- សហព័ទ្ធរៀបអាពាហ៍ពិពាហ៍ជាថ្មីស្របតាមនីតិវិធីច្បាប់ដែលមានជាធរមាន។ ក្នុងករណីនេះ សាមីជនត្រូវជូនដំណឹងមក **ប.ស.ស.**យ៉ាងយូរ៣០(សាមសិប) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការរៀបអាពាហ៍ពិពាហ៍ថ្មី។

**មាត្រា២១ .. ប្រភពធនធានផ្នែកប្រាក់សោធន**

ធនធានផ្នែកប្រាក់សោធនមានប្រភពមកពី៖

- ការបង់ភាគទានពីរដ្ឋ និយោជក និងសមាជិក **ប.ស.ស.**
- ផលដែលបានមកពីការវិនិយោគ

- អំណោយឬអច្ច័យទាននិងប្រភពស្របច្បាប់ដទៃផ្សេងទៀត។

**មាត្រា២២ .- ការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុផ្នែកប្រាក់សោធន**

ការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុផ្នែកប្រាក់សោធនត្រូវធ្វើការត្រួតពិនិត្យនិងវិភាគឡើងវិញយ៉ាងយូរ៥(ប្រាំ)ឆ្នាំម្តង។

**មាត្រា២៣ .- ការកែសម្រួលតាមកាលិកផ្នែកប្រាក់សោធន**

តាវកាលិកផ្នែកប្រាក់សោធនត្រូវកែសម្រួលរៀងរាល់ឆ្នាំស្របតាមសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ផ្លូវការ។

**មាត្រា២៤ .- ប្រាក់ត្រៀមបម្រុងផ្នែកប្រាក់សោធន**

ប្រាក់ត្រៀមបម្រុងផ្នែកប្រាក់សោធនត្រូវកំណត់ស្មើនឹងប្រាក់ចំណាយសម្រាប់តាវកាលិកផ្នែកប្រាក់សោធនក្នុងកំលុងពេល៣(បី)ឆ្នាំចុងក្រោយ។

**មាត្រា២៥ .- ការកំណត់ស្ថានភាពទុព្វលភាព**

ស្ថានភាពទុព្វលភាពត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ **ប.ស.ស.**។ ការពិនិត្យឡើងវិញអំពីស្ថានភាពទុព្វលភាពត្រូវធ្វើជារៀងរាល់ឆ្នាំ។ សោធនទុព្វលភាពត្រូវបានព្យួរក្នុងករណីសាមីខ្លួនមិនបានចូលខ្លួនមកពិនិត្យសុខភាពតាមកាលកំណត់។

## ផ្នែកទី២

## ផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច

### កថាភាគទី១

### ផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច សម្រាប់បុគ្គលនៃវិស័យសាធារណៈ

**មាត្រា២៦ .- សោធនជរាភាព**

សមាជិក **ប.ស.ស.** ជាបុគ្គលនៃវិស័យសាធារណៈទាំងពីរភេទត្រូវដាក់ឲ្យចូលនិវត្តន៍ ជាកំហិត ពេលដល់អាយុ៦០(ហុកសិប)ឆ្នាំ និងមានសិទ្ធិទទួលសោធនជរាភាព ប្រសិនបើសាមីជនបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន។

២. បានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច១២(ដប់ពីរ)ខែ។

សមាជិក **ប.ស.ស.** ដែលមិនបានបំពេញលក្ខខណ្ឌក្នុងចំណុចទី២នៃកថាខណ្ឌទី១ខាងលើត្រូវទទួលបានវិភាជន៍ជរាភាព។

អាយុចូលនិវត្តន៍របស់បុគ្គលនៃវិស័យសាធារណៈទាំងពីរភេទអាចត្រូវបានកែប្រែដោយព្រះរាជក្រឹត្យ អាស្រ័យដោយការប្រែប្រួលនៃអាយុរំពឹងទុក ស្ថានភាពសេដ្ឋកិច្ចនិងសង្គមជាក់ស្តែង។

**មាត្រា២៧ .- សោធនទុព្វលភាព**

សមាជិក **ប.ស.ស.** ជាបុគ្គលនៃវិស័យសាធារណៈដែលធ្លាក់ខ្លួនក្នុងទុព្វលភាព មានសិទ្ធិទទួលបានសោធនទុព្វលភាព ប្រសិនបើសាមីជនបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន។

២. បានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច៦០(ហុកសិប)ខែ មុនកាលបរិច្ឆេទទទួលរងទុព្វលភាព។

**មាត្រា២៨ .- សោធនឧត្តរជីវី**

សិទ្ធិវន្តនៃសោធនឧត្តរជីវីត្រូវទទួលបានសោធនឧត្តរជីវី លុះត្រាតែមានការទទួលមរណភាពនៃសាមីជនជាសោធនិកជរាភាពឬទុព្វលភាព ឬសមាជិក **ប.ស.ស.** ដែលបានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច៦០(ហុកសិប)ខែ។

អត្រាសោធនឧត្តរជីវីអប្បបរមាត្រូវកំណត់ស្មើនឹង៤៥%(សែសិបប្រាំភាគរយ)នៃប្រាក់សោធនជរាភាពឬទុព្វលភាពរបស់សាមីជន។

ចំណែកសោធនឧត្តរជីវីត្រូវបានបែងចែកដូចខាងក្រោម៖

- សម្រាប់សហព័ទ្ធ៥០%(ហាសិបភាគរយ)
- សម្រាប់កូន៥០%(ហាសិបភាគរយ)
- ក្នុងករណីដែលសិទ្ធិវន្តមានតែសហព័ទ្ធឬកូន ត្រូវទទួលបាន១០០%(មួយរយភាគរយ)។

**មាត្រា២៩ .- វិភាជន៍បូជាសព**

សិទ្ធិវន្តនៃសោធនឧត្តរជីវីមានសិទ្ធិទទួលបានវិភាជន៍បូជាសព នៅពេលដែលសោធនិកជរាភាពឬទុព្វលភាពសាមីទទួលមរណភាព។ ប្រសិនបើករណីយកិច្ចនេះមិនបានបំពេញដោយសិទ្ធិវន្តនៃសោធនឧត្តរជីវី វិភាជន៍បូជាសពអាចត្រូវបានផ្តល់ដល់ជនណាដែលជាអ្នកចាត់ចែងបូជាសពសាមីជនផ្ទាល់។

**មាត្រា៣០ .- លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្ត**

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្តផ្នែកប្រាក់សោធន សម្រាប់បុគ្គលនៃវិស័យសាធារណៈត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

## កថាភាគទី២

## ផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ចសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ

**មាត្រា៣១ .- សោធនជរាភាព**

សមាជិក **ប.ស.ស.** ជាបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រព្រមទាំងអ្នកបម្រើក្នុងផ្ទះដែលមានអាយុយ៉ាងតិច៦០(ហុកសិប)ឆ្នាំ មានសិទ្ធិទទួលសោធនជរាភាព ប្រសិនបើសាមីជនបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន។

២. បានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច១២(ដប់ពីរ)ខែ។

សមាជិក **ប.ស.ស.** ដែលមិនបានបំពេញលក្ខខណ្ឌក្នុងចំណុចទី២នៃកថាខណ្ឌទី១ខាងលើ ត្រូវទទួលបានវិភាជន៍ជរាភាពដែលត្រូវកំណត់ដោយអនុក្រឹត្យ។

អត្រា[illegible]ាច័យជរាភាពអតិបរមាស្មើនឹង១,៧៥%(មួយក្បៀសចិតសិបប្រាំភាគរយ)ក្នុង

មួយឆ្នាំភាគទាន។ អត្រាសមាច័យសោធនជរាភាពនេះត្រូវកំណត់ដោយអនុក្រឹត្យ។

សោធនជរាភាពត្រូវគណនាជាអនុគមន៍នៃប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទានរបស់សាមីខ្លួន។

**មាត្រា៣២ .. សោធនទុព្វលភាព**

សមាជិក **ប.ស.ស.** ជាបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រព្រមទាំងអ្នកបម្រើក្នុងផ្ទះដែលធ្លាក់ខ្លួនក្នុងទុព្វលភាព មានសិទ្ធិទទួលបានសោធនទុព្វលភាព ប្រសិនបើសាមីជនបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន។

២. បានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច៦០(ហុកសិប)ខែ មុនកាលបរិច្ឆេទទទួលរងទុព្វលភាព។

អត្រាសមាច័យទុព្វលភាពអតិបរមាស្មើនឹង១,៧៥%(មួយក្បៀសចិតសិបប្រាំភាគរយ)ក្នុងមួយឆ្នាំភាគទាន។ កម្រិតអប្បបរមានៃសោធនទុព្វលភាពត្រូវស្មើនឹង៤៥%(សែសិបប្រាំភាគរយ)នៃប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទានរបស់សាមីជន។ អត្រាសមាច័យសោធនទុព្វលភាពនេះត្រូវកំណត់ដោយអនុក្រឹត្យ។

សោធនទុព្វលភាពត្រូវគណនាជាអនុគមន៍នៃប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទានរបស់សាមីខ្លួន។

**មាត្រា៣៣ .. សោធនឧត្តរជីវី**

សិទ្ធិវន្តនៃសោធនឧត្តរជីវីត្រូវទទួលបានសោធនឧត្តរជីវី លុះត្រាតែមានការទទួលមរណភាពនៃសាមីជនជាសោធនិកជរាភាពឬទុព្វលភាព ឬសមាជិក **ប.ស.ស.** ដែលបានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច៦០(ហុកសិប)ខែ។

អត្រាសោធនឧត្តរជីវីអប្បបរមាត្រូវកំណត់ស្មើនឹង៤៥%(សែសិបប្រាំភាគរយ)នៃប្រាក់សោធនជរាភាពឬទុព្វលភាពរបស់សាមីជន។

ចំណែកសោធនឧត្តរជីវីត្រូវបានបែងចែកដូចខាងក្រោម៖

- សម្រាប់សហព័ទ្ធ៥០%(ហាសិបភាគរយ)
- សម្រាប់កូន៥០%(ហាសិបភាគរយ)
- ក្នុងករណីដែលសិទ្ធិវន្តមានតែសហព័ទ្ធឬកូន ត្រូវទទួលបាន១០០%(មួយរយភាគរយ)។

**មាត្រា៣៤ .. វិភាជន៍បូជាសព**

សិទ្ធិវន្តនៃសោធនឧត្តរជីវីមានសិទ្ធិទទួលបានវិភាជន៍បូជាសព នៅពេលដែលសោធនិកជរាភាពឬទុព្វលភាពសាមីទទួលមរណភាព។ ប្រសិនបើករណីយកិច្ចនេះមិនបានបំពេញដោយសិទ្ធិវន្តនៃសោធនឧត្តរជីវី វិភាជន៍បូជាសពអាចត្រូវបានផ្តល់ដល់ជនណាដែលជាអ្នកចាត់ចែងបូជាសពសាមីជនផ្ទាល់។

វិភាជន៍បូជាសពត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.**។

## ផ្នែកទី៣
## ផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត
### កថាភាគទី១
### ផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ

**មាត្រា៣៥.- លក្ខខណ្ឌនិងសិទ្ធិនៃការចូលរួមក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត**

បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ អាចចូលរួមក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត ក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- បាត់បង់ការងារដែលមានប្រាក់ឈ្នួលមុនអាយុ៦០(ហុកសិប)ឆ្នាំ
- មានលទ្ធភាពបង់ភាគទានបន្ត។

បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ដែលមានអាយុគ្រប់៦០(ហុកសិប)ឆ្នាំនិងមានបំណងបង់ភាគទានបន្ត ដើម្បីទទួលបានសោធនជរាភាពខ្ពស់ជាងសោធនជរាភាពជាក់ស្តែង ដែលសាមីខ្លួនត្រូវទទួលបានតាមរបបភាគទានជាកាតព្វកិច្ច អាចចូលរួមក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តបាន។ ក្នុងករណីនេះ សោធនជរាភាពត្រូវបើកផ្តល់តាមកាលបរិច្ឆេទជាក់លាក់ ដែលសាមីខ្លួនអស់លទ្ធភាពចូលរួមក្នុងផ្នែកនេះ។

បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ដែលមានប្រាក់ចំណូលខ្ពស់ជាងប្រាក់ឈ្នួលពិតានដែលសាមីជនជាប់កាតព្វកិច្ចក្នុងរបបភាគទានជាកាតព្វកិច្ច អាចចូលរួមក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តបាន។ ការបង់ភាគទានក្នុងផ្នែកនេះត្រូវអនុវត្តចំពោះតែចំណែកនៃប្រាក់ឈ្នួលដែលខ្ពស់ជាងប្រាក់ឈ្នួលពិតានតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញ។

ការបង់ភាគទានផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តជាបន្ទុកផ្ទាល់របស់សាមីជន។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្តផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវកំណត់ដោយអនុក្រឹត្យ។

### អនុផ្នែកទី២
### ផ្នែកប្រាក់សោធនសម្រាប់បុគ្គលស្វ័យនិយោជន៍

**មាត្រា៣៦ .- លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្ត**

បុគ្គលស្វ័យនិយោជន៍អាចចូលរួមក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដែលត្រូវកំណត់ដោយអនុក្រឹត្យ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការចូលរួមសម្រាប់បុគ្គលស្វ័យនិយោជន៍ត្រូវកំណត់ដោយអនុក្រឹត្យ។

### អនុផ្នែកទី៣
### ផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់ បុគ្គលនៃវិស័យសាធារណៈ

**មាត្រា៣៧ .- លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្ត**

បុគ្គលនៃវិស័យសាធារណៈអាចចូលរួមក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត។

យន្តការនៃការកំណត់អត្រាភាគទានក្នុងផ្នែកនេះត្រូវអនុវត្តដូចគ្នានឹងផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការចូលរួមដោយស្ម័គ្រចិត្តសម្រាប់បុគ្គលនៃវិស័យសាធារណៈត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៥
## របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព
### ផ្នែកទី១
### គោលការណ៍រួម

**មាត្រា៣៨ .- បុគ្គលត្រូវគាំពារ**

បុគ្គលដែលត្រូវគាំពារក្នុងផ្នែកថែទាំសុខភាព រួមមាន៖

១. បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ។

២. បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ។

៣- បុគ្គលស្វ័យនិយោជន៍។

**មាត្រា៣៩ .- តាវកាលិកផ្នែកថែទាំសុខភាព**

តាវកាលិកផ្នែកថែទាំសុខភាពរួមមាន៖

- ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ
- ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ

- ប្រាក់បំណាច់មាតុភាព និង
- វិភាជន៍ឬជាសព។

**មាត្រា៤០.- ភាគទានផ្នែកថែទាំសុខភាព**

អត្រាភាគទានផ្នែកថែទាំសុខភាពត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤១.- ប្រភពធនធានផ្នែកថែទាំសុខភាព**

ធនធានផ្នែកថែទាំសុខភាពមានប្រភពមកពី៖

- ការបង់ភាគទានពីរដ្ឋ និយោជក និងសមាជិក **ប.ស.ស.**
- ផលដែលបានមកពីការវិនិយោគ
- អំណោយឬអច្ច័យទាននិងប្រភពស្របច្បាប់ដទៃផ្សេងទៀត។

**មាត្រា៤២.- ការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុ**

ការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុនៃផ្នែកថែទាំសុខភាពត្រូវធ្វើការត្រួតពិនិត្យនិងវិភាគឡើងវិញជារៀងរាល់ឆ្នាំ។

**មាត្រា៤៣.- ការពិនិត្យកែសម្រួលតាវកាលិកផ្នែកថែទាំសុខភាព**

តាវកាលិកផ្នែកថែទាំសុខភាពត្រូវធ្វើការពិនិត្យកែសម្រួលស្របតាមស្ថានភាពផ្នែកសុខាភិបាលជាក់ស្តែង។

យន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាពត្រូវអនុលោមតាមយន្តការទូទាត់ថ្លៃតាមករណីនិង/ឬតាមថ្លៃសេវា។ ការកែប្រែយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាពតាមយន្តការដទៃផ្សេងទៀតត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤៤.- ប្រាក់ត្រៀមបម្រុងផ្នែកថែទាំសុខភាព**

ប្រាក់ត្រៀមបម្រុងអប្បបរមាផ្នែកថែទាំសុខភាពត្រូវស្មើនឹងប្រាក់ចំណាយសម្រាប់តាវកាលិកផ្នែកថែទាំសុខភាពក្នុងកំលុងពេល១(មួយ)ឆ្នាំចុងក្រោយ។

**មាត្រា៤៥.- ការទទួលស្គាល់មូលដ្ឋានសុខាភិបាល**

ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រត្រូវផ្តល់ដោយមូលដ្ឋានសុខាភិបាលដែលមានការទទួលស្គាល់ពីក្រសួងសុខាភិបាលនិងបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស.**។

**មាត្រា៤៦.- ការត្រួតពិនិត្យគុណភាពសេវារបស់មូលដ្ឋានសុខាភិបាល**

ការទទួលស្គាល់គុណភាពសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រត្រូវអនុវត្តស្របតាមលិខិតបទដ្ឋានគតិយុត្តដែលចេញដោយក្រសួងសុខាភិបាល។

**មាត្រា៤៧.- ក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃបេឡាជាតិសន្តិសុខសង្គម**

ក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ **ប.ស.ស.** មានតួនាទីត្រួតពិនិត្យ តាមដាន ការអនុវត្តកិច្ចព្រមព្រៀងរបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស.**។

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ **ប.ស.ស.** ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី២
## ផ្នែកថែទាំសុខភាពតាមរបបភាគទានជាភាគព្វកិច្ច
## កថាភាគទី១
## ផ្នែកថែទាំសុខភាពសម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ

### មាត្រា៤៨.- សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ

បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈមានសិទ្ធិទទួលបានសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ លុះត្រាតែបានចុះបញ្ជីនិងបង់ភាគទានក្នុងផ្នែកថែទាំសុខភាព។

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រមានដូចខាងក្រោម៖

១. ការផ្តល់សេវាព្យាបាលដោយសម្រាកក្នុងមូលដ្ឋានសុខាភិបាលដែលរួមមាន៖
- សេវាព្យាបាលនិងថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងៗទៀត
- ឧបករណ៍ផ្នែកសល្យសាស្ត្រនិងសម្ភារៈបរិក្ខារផ្នែកវេជ្ជសាស្ត្រផ្សេងៗតាមតម្រូវការចាំបាច់សម្រាប់ការព្យាបាល
- ឱសថតាមវេជ្ជបញ្ជា
- បន្ទប់សម្រាកព្យាបាល។

២. ការផ្តល់សេវាពិគ្រោះជំងឺក្រៅដែលរួមមាន៖
- សេវាព្យាបាលនិងថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងៗទៀត
- ឧបករណ៍ផ្នែកសល្យសាស្ត្រនិងសម្ភារៈបរិក្ខារផ្នែកវេជ្ជសាស្ត្រផ្សេងៗតាមតម្រូវការចាំបាច់សម្រាប់ការព្យាបាល
- ឱសថតាមវេជ្ជបញ្ជា។

៣. ការផ្តល់សេវាសម្រាលកូន សេវាព្យាបាលថែទាំមុននិងក្រោយសម្រាល។

៤. ការផ្តល់សេវាព្យាបាលដោយស្តារ ដោយចលនា ឬសេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រដទៃទៀត។

៥. ការផ្តល់សេវាសង្គ្រោះបន្ទាន់។ ក្នុងករណីសង្គ្រោះបន្ទាន់ សាមីជនរងគ្រោះអាចទៅព្យាបាលនៅមូលដ្ឋានសុខាភិបាលដែលស្ថិតនៅជិតបំផុត។ ប្រសិនបើមូលដ្ឋានសុខាភិបាលនោះមិនមានកិច្ចព្រមព្រៀងជាមួយ **ប.ស.ស.** សាមីជនឬអ្នកតំណាងត្រូវជូនដំណឹងបន្ទាន់មក **ប.ស.ស.**។

៦. ការផ្តល់សេវាបង្ការសុខភាព។

៧. ការផ្តល់សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះនិងសេវាបញ្ជូនសព។

ការផ្តល់សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះត្រូវផ្តល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់និងដោយប្រើយានយន្តគិលានសង្គ្រោះរបស់មូលដ្ឋានសុខាភិបាលតែប៉ុណ្ណោះ។

ការផ្តល់សេវាបញ្ជូនអ្នកជំងឺធ្ងន់ធ្ងរមិនអាចព្យាបាលជាឬសេវាបញ្ជូនសពត្រូវផ្តល់ស្របតាមតម្រូវរបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស.**។

៨. សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ។

ការផ្តល់សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ សម្រាប់គាំទ្រដល់ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ឬសម្រាប់ជួយសម្រួលដល់អ្នកជំងឺឬជនរងគ្រោះក្នុងកំលុងពេលសម្រាកព្យាបាល។

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រដូចមានចែងក្នុងចំណុចទី១ ទី២ ទី៣ និងទី៤ ខាងលើ ត្រូវបានផ្តល់តែនៅក្នុងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស**. ប៉ុណ្ណោះ។ ការប្រើប្រាស់សេវានៅមូលដ្ឋានសុខាភិបាលដទៃផ្សេងទៀត មិនត្រូវបានផ្តល់ជូនឡើយ វៀរលែងតែករណីសង្គ្រោះបន្ទាន់។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សេវាស្តារនីតិសម្បទា ការកំណត់សេវា ឬការព្យាបាល និងការថែទាំវេជ្ជសាស្ត្រដែលមិនរាប់បញ្ចូលនូវការផ្តល់សេវាបង្ការសុខភាពនិងការកំណត់បញ្ជីជំងឺរ៉ាំរ៉ៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម។

**មាត្រា៤៩.- ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ**

ក្នុងរយៈពេលនៃការសម្រាកព្យាបាលជំងឺ បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ ត្រូវបានរក្សាប្រាក់បៀវត្សដដែល។

**មាត្រា៥០.- ប្រាក់បំណាច់មាតុភាព**

បុគ្គលនៃវិស័យសាធារណៈជាស្ត្រីមានសិទ្ធិទទួលបានប្រាក់បៀវត្សពេញក្នុងរយៈពេលសម្រាកមាតុភាពឬក្នុងរយៈពេលព្យាបាលថែទាំសុខភាពមុននិងក្រោយពេលសម្រាល ដូចមានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៥១.- វិភាជន៍បូជាសព**

វិភាជន៍បូជាសពត្រូវបានផ្តល់ដល់សិទ្ធិវន្តនៃសមាជិក **ប.ស.ស**. ដែលទទួលមរណភាពដោយសារជំងឺឬគ្រោះថ្នាក់ជាយថាហេតុ ដែលមិនពាក់ព័ន្ធនឹងការងារ។

វិភាជន៍បូជាសពត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**.។

**មាត្រា៥២.- សុពលភាពនៃការទទួលបានសេវាផ្នែកថែទាំសុខភាព**

សុពលភាពនៃការទទួលបានសេវាផ្នែកថែទាំសុខភាព សម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យ។

## កថាភាគទី២

## ផ្នែកថែទាំសុខភាព

## សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ

### មាត្រា៥៣.- សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រសម្រាប់សមាជិក **ប.ស.ស.** ជាបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវអនុវត្តដូចគ្នានឹងការផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រសម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈដូចមានចែងក្នុងមាត្រា៤៨នៃច្បាប់នេះ។

### មាត្រា៥៤.- ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ

សមាជិក **ប.ស.ស.** ជាបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ មានសិទ្ធិទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ លុះត្រាតែ៖

- បានចុះបញ្ជីផ្នែកថែទាំសុខភាព
- បានបង់ភាគទាន២(ពីរ)ខែជាប់គ្នាឬ៦(ប្រាំមួយ)ខែ ក្នុងរយៈពេល១២(ដប់ពីរ)ខែចុងក្រោយ
- បានសម្រាកព្យាបាលនៅតាមមូលដ្ឋានសុខាភិបាលចាប់ពី៨(ប្រាំបី)ថ្ងៃឡើង។

ប្រាក់បំណាច់ប្រចាំថ្ងៃត្រូវផ្តល់ដោយគិតពីថ្ងៃផ្អាកការងារដំបូង ដោយការចូលសម្រាកព្យាបាលជំងឺនៅតាមមូលដ្ឋានសុខាភិបាល។

ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលនៅតាមមូលដ្ឋានសុខាភិបាលត្រូវកំណត់ស្មើនឹង៧០%(ចិតសិបភាគរយ)នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃដែលបានបង់ភាគទានសម្រាប់រយៈពេលជាក់ស្តែងមិនលើស៦(ប្រាំមួយ)ខែ មុនខែដែលមានបញ្ហាសុខភាព។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលព្យាបាលជំងឺត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.**។

### មាត្រា៥៥.- ប្រាក់បំណាច់មាតុភាព

សមាជិក **ប.ស.ស.** ជាបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះជាស្ត្រី មានសិទ្ធិទទួលបានប្រាក់បំណាច់មាតុភាព លុះត្រាតែ៖

- បានចុះបញ្ជីផ្នែកថែទាំសុខភាព

- បានបង់ភាគទានយ៉ាងតិច៥(ប្រាំបួន)ខែក្នុងរយៈពេល១២(ដប់ពីរ)ខែចុងក្រោយគិតមកទល់កាលបរិច្ឆេទនៃការសម្រាលកូន។

ប្រាក់បំណាច់មាតុភាពត្រូវកំណត់ស្មើនឹង៧០%(ចិតសិបភាគរយ)នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃជាប់ភាគទានក្នុងរយៈពេលជាក់ស្តែងមិនលើស៦(ប្រាំមួយ)ខែ មុនខែសម្រាលកូន ចំនួន៩០(កៅសិប)ថ្ងៃ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់ប្រាក់បំណាច់មាតុភាពត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.**។

## ផ្នែកទី៣

## ផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត

### មាត្រា៥៦.- លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្ត

បុគ្គលស្វ័យនិយោជន៍អាចចូលរួមក្នុងផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្តផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តក្នុងផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត ដូចមានចែងក្នុងមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៦

## របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ

## ផ្នែកទី១

## គោលការណ៍រួម

### មាត្រា៥៧.- បុគ្គលត្រូវគាំពារ

បុគ្គលដែលត្រូវគាំពារក្នុងផ្នែកហានិភ័យការងារ រួមមាន៖

១. បុគ្គលនៃវិស័យសាធារណៈ។

២. បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ។

### មាត្រា៥៨.- តាវកាលិកផ្នែកហានិភ័យការងារ

តាវកាលិកផ្នែកហានិភ័យការងារ រួមមាន ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ការផ្តល់ប្រាក់បំណាច់សម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ការផ្តល់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ការផ្តល់ធនលាភឧត្តរជីវី វិភាជន៍បូជាសព និងការផ្តល់សេវាស្តារនីតិសម្បទា។

ចំពោះគ្រោះថ្នាក់បង្កឡើងដោយចេតនាផ្ទាល់ខ្លួន មិនត្រូវទទួលបានតាវកាលិកផ្នែកហានិភ័យការងារទេ។

### មាត្រា៥៩.- ភាគទានផ្នែកហានិភ័យការងារ

អត្រាភាគទានផ្នែកហានិភ័យការងារត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦០.- ប្រភពធនធានផ្នែកហានិភ័យការងារ**

ធនធានផ្នែកហានិភ័យការងារ មានប្រភពមកពី៖

- ការបង់ភាគទានពីរដ្ឋនិងនិយោជក
- ផលដែលបានមកពីការវិនិយោគ
- អំណោយឬអច្ច័យទាននិងប្រភពស្របច្បាប់ដទៃផ្សេងទៀត។

**មាត្រា៦១.- ការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុ**

ការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុផ្នែកហានិភ័យការងារត្រូវធ្វើការត្រួតពិនិត្យនិងវិភាគឡើងវិញយ៉ាងយូរ៣(បី)ឆ្នាំម្តង។

**មាត្រា៦២.- ការកែសម្រួលតាវកាលិកផ្នែកហានិភ័យការងារ**

តាវកាលិកផ្នែកហានិភ័យការងារជាធនលាភត្រូវធ្វើការពិនិត្យនិងកែសម្រួលស្របតាមសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ផ្លូវការ។

យន្តការទូទាត់ថ្លៃសេវាផ្នែកហានិភ័យការងារសម្រាប់មូលដ្ឋានសុខាភិបាល ត្រូវអនុលោមតាមយន្តការទូទាត់ថ្លៃតាមសេវា។ ការកែប្រែយន្តការទូទាត់ថ្លៃសេវាផ្នែកហានិភ័យការងារត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦៣.- ប្រាក់ត្រៀមបម្រុងផ្នែកហានិភ័យការងារ**

ប្រាក់ត្រៀមបម្រុងអប្បបរមាផ្នែកហានិភ័យការងារត្រូវស្មើនឹងប្រាក់ចំណាយសម្រាប់ធនលាភដែលបានផ្តល់រួច បូកនឹង៥០%(ហាសិបភាគរយ)នៃប្រាក់ចំណាយសម្រាប់តាវកាលិកដទៃផ្សេងពីធនលាភក្នុងកំលុងពេល២(ពីរ)ឆ្នាំចុងក្រោយ។

**មាត្រា៦៤.- ការទទួលស្គាល់មូលដ្ឋានសុខាភិបាល**

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រផ្នែកហានិភ័យការងារត្រូវផ្តល់ដោយមូលដ្ឋានសុខាភិបាលដែលមានការទទួលស្គាល់ពីក្រសួងសុខាភិបាល និងបានចុះកិច្ចព្រមព្រៀងជាមួយ**ប.ស.ស.**។

**មាត្រា៦៥.- ការត្រួតពិនិត្យគុណភាពសេវារបស់មូលដ្ឋានសុខាភិបាល**

ការទទួលស្គាល់គុណភាពសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រត្រូវអនុវត្តស្របតាមលិខិតបទដ្ឋានគតិយុត្តដែលចេញដោយក្រសួងសុខាភិបាល។ គុណភាពសេវារបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស.** ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ តាមដានវាយតម្លៃរបស់ក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ **ប.ស.ស.**។

**មាត្រា៦៦.- ភារកិច្ចរាយការណ៍ហានិភ័យការងារ**

ជនរងគ្រោះដោយគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ក្នុងពេលធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈ ឬក៏អ្នកតំណាងជនរងគ្រោះ ត្រូវជូនដំណឹងជាបន្ទាន់ទៅ **ប.ស.ស.** និយោជក ឬអ្នកតំណាងនិយោជក អំពីគ្រោះថ្នាក់ដែលធ្លាក់មកលើខ្លួន លើកលែងតែក្នុងករណីប្រធានសក្តិ។

បែបបទនៃការជូនដំណឹងពីហានិភ័យការងារ ការអង្កេតហានិភ័យការងារ និងការត្រួតពិនិត្យការអនុវត្តភារកិច្ចរបស់និយោជក មូលដ្ឋានសុខាភិបាល និងជនរងគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ក្នុងពេលធ្វើដំណើរ និងជំងឺវិជ្ជាជីវៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.**។

ភាពងជំងឺវិជ្ជាជីវៈត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦៧.- កម្មវិធីបង្ការហានិភ័យការងារ**

**ប.ស.ស**. ត្រូវរៀបចំឲ្យមានកម្មវិធីបង្ការហានិភ័យការងារ ដើម្បីធានានូវសុវត្ថិភាពនិងសុខភាពការងារ ដោយគិតរួមទាំងកម្មវិធីបង្ការគ្រោះថ្នាក់ពេលធ្វើដំណើររបស់សមាជិក **ប.ស.ស**.។

**មាត្រា៦៨.- សិទ្ធិវន្តនៃធនលាភឧត្តរជីវី**

សិទ្ធិវន្តនៃធនលាភឧត្តរជីវី រួមមាន សហព័ទ្ធនិងកូន ព្រមទាំងឪពុកម្តាយឬមនុស្សចាស់ជរាដែលរស់នៅក្នុងបន្ទុកផ្ទាល់របស់សាមីជនមុនពេលទទួលមរណភាព និងត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. សម្រាប់ប្តីឬប្រពន្ធ ត្រូវចុះសំបុត្រអាពាហ៍ពិពាហ៍មុនកាលបរិច្ឆេទនៃហានិភ័យការងារ ឬមុនពេលទទួលមរណភាពដោយហានិភ័យការងារ។

២. ចំពោះកូន ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មិនទាន់រៀបអាពាហ៍ពិពាហ៍
- ជាកូនបង្កើត
- ក្នុងករណីមានការលែងលះឬករណីមរណភាពនៃប្តីឬប្រពន្ធ កូននៃគូស្រករក្រោយដែលនៅក្នុងបន្ទុកផ្ទាល់របស់សាមីជន ក៏មានសិទ្ធិដូចកូននៃអាពាហ៍ពិពាហ៍មុនដែរ
- កូនសុំរបស់សាមីជនរងគ្រោះ ដែលបានសុំស្របតាមបទប្បញ្ញត្តិជាធរមាន ឬក្មេងកំព្រារស់នៅក្នុងបន្ទុកផ្ទាល់របស់សាមីជនរងគ្រោះ
- មានអាយុមិនលើសពី២១(ម្ភៃមួយ)ឆ្នាំ។

កូនពិការឬមានជំងឺរ៉ាំរ៉ៃ ហើយមិនអាចប្រកបការងារឬមុខរបរដែលមានប្រាក់ចំណូល ត្រូវផ្តល់ធនលាភឧត្តរជីវីអស់មួយជីវិត។ ការកំណត់ស្ថានភាពពិការឬជំងឺរ៉ាំរ៉ៃត្រូវបញ្ជាក់ដោយគ្រូពេទ្យឯកទេស និងមានការយល់ព្រមពីក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ **ប.ស.ស**.។

៣. ឪពុកម្តាយឬមនុស្សចាស់ជរានៅក្នុងបន្ទុកផ្ទាល់របស់ជនរងគ្រោះដែលមានអាយុយ៉ាងតិច៦០(ហុកសិប)ឆ្នាំ គិតត្រឹមកាលបរិច្ឆេទនៃការទទួលមរណភាពរបស់ជនរងគ្រោះនិងមិនមានប្រកបមុខរបរដែលមានប្រាក់ចំណូល ឬប្រាក់សោធននិវត្តន៍ ឬសោធនជរាភាព។ ចំពោះឪពុកម្តាយឬមនុស្សចាស់ជរាដែលមានជំងឺរ៉ាំរ៉ៃ ព្យាបាលមិនជា ឬមានទុព្វលភាព និងមិនមានប្រាក់ចំណូល ឬប្រាក់សោធននិវត្តន៍ ឬសោធនជរាភាព មិនត្រូវបានកំណត់អាយុឡើយ។

៤. សិទ្ធិទទួលបានធនលាភឧត្តរជីវីត្រូវផុតរលត់ក្នុងករណីដូចខាងក្រោម៖

- សាមីជនទទួលមរណភាព

ប្តីឬប្រពន្ធរៀបអាពាហ៍ពិពាហ៍ជាថ្មី ស្របតាមនីតិវិធីច្បាប់ដែលមានជាធរមាន។ ក្នុងករណីនេះ សាមីជនត្រូវជូនដំណឹងមក **ប.ស.ស**. យ៉ាងយូរ ៣០(សាមសិប) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការរៀបអាពាហ៍ពិពាហ៍ថ្មី។

## ផ្នែកទី២
## ផ្នែកហានិភ័យការងារសម្រាប់បុគ្គលនៃវិស័យសាធារណៈ

### មាត្រា៦៩.- សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រផ្នែកហានិភ័យការងារសម្រាប់បុគ្គលនៃវិស័យសាធារណៈ មានដូចខាងក្រោម៖

- ការព្យាបាលនិងថែទាំមុខរបួសឬជំងឺដែលបណ្ដាលមកពីហានិភ័យការងារតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ រហូតជាសះស្បើយ ទោះអ្នករងគ្រោះសម្រាកឬមិនសម្រាកព្យាបាលនៅតាមមូលដ្ឋានសុខាភិបាលក្ដី
- ការផ្ដល់សេវាសង្គ្រោះបន្ទាន់
- ការផ្គត់ផ្គង់ឱសថសម្រាប់ការព្យាបាលនិងសម្ភារៈប្រើប្រាស់បន្ទាប់បន្សំសម្រាប់ការព្យាបាល
- ការផ្ដល់សេវាដឹកសពឬសេវាបញ្ជូនជនរងគ្រោះដែលត្រូវសង្គ្រោះបន្ទាន់
- ការផ្ដល់ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំអ្នករងគ្រោះ ក្នុងពេលសម្រាកព្យាបាលសម្រាប់ករណីធ្ងន់ធ្ងរដែលសាមីជនរងគ្រោះមិនអាចបម្រើខ្លួនឯងបាន។

### មាត្រា៧០.- ប្រាក់បំណាច់សម្រាប់ការបាត់បង់សមត្ថភាពការងារបណ្ដោះអាសន្ន

ក្នុងរយៈពេលនៃការសម្រាកព្យាបាលមុខរបួសឬជំងឺដែលបណ្ដាលមកពីហានិភ័យការងារនៅតាមមូលដ្ឋានសុខាភិបាល និងរយៈពេលសម្រាកក្រោយការចេញពីមូលដ្ឋានសុខាភិបាល តាមវេជ្ជបញ្ជាដែលចេញដោយគ្រូពេទ្យផ្លូវការឬគ្រូពេទ្យទទួលស្គាល់ដោយ **ប.ស.ស**. ប្រាក់បៀវត្សរបស់សាមីជនរងគ្រោះត្រូវបានរក្សាទុកដដែល។

### មាត្រា៧១.- ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍

សមាជិក **ប.ស.ស**. ជាបុគ្គលនៃវិស័យសាធារណៈដែលទទួលរងហានិភ័យការងារបណ្ដាលឲ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ក្នុងកម្រិតចាប់ពី២០%(ម្ភៃភាគរយ)ឡើង មានសិទ្ធិទទួលបានធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍។ បែបបទនិងនីតិវិធីស្ដីពីការគណនាធនលាភ ការកំណត់កម្រិតនៃការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ និងការផ្ដល់ធនលាភ ត្រូវកំណត់ដោយអនុក្រឹត្យ។

សមាជិក **ប.ស.ស**. ជាបុគ្គលនៃវិស័យសាធារណៈដែលកំពុងទទួលធនលាភដោយការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ដោយផ្នែក ប៉ុន្តែត្រូវទទួលរងហានិភ័យការងារជាថ្មី ត្រូវទទួលបានធនលាភស្របតាមកម្រិតនៃការបាត់បង់សមត្ថភាពការងារសរុប។ កម្រិតនៃការបាត់បង់សមត្ថភាពការងារសរុបត្រូវស្មើនឹងកម្រិតបាត់បង់សមត្ថភាពការងារដើមដំបូងបូកនឹងកម្រិតបាត់បង់សមត្ថភាពការងារបន្តបន្ទាប់នៃសរីរាង្គផ្សេងទៀត ប៉ុន្តែមិនត្រូវលើសពី១០០%(មួយរយភាគរយ)ឡើយ។

ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ត្រូវចាត់ទុកជាប្រាក់បណ្ដោះអាសន្នជានិច្ច។ **ប.ស.ស**. ត្រូវរៀបចំឲ្យមានការពិនិត្យសុខភាពនិងវាយតម្លៃកម្រិតបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះជាទៀងទាត់។ ក្នុងករណីពិនិត្យឃើញមានការ

ប្រែប្រួលចំពោះកម្រិតនៃការបាត់បង់សមត្ថភាពការងារ ត្រូវមានការវាយតម្លៃនិងសើរើចំនួនប្រាក់ធនលាភដែលត្រូវផ្តល់ឡើងវិញ។

ជនរងគ្រោះមិនអាចជំទាស់នឹងការពិនិត្យសុខភាពដូចកំណត់ខាងលើបានទេ។ ក្នុងករណីដែលសាមីជនមិនបានចូលខ្លួនមកពិនិត្យតាមកាលកំណត់ **ប.ស.ស**. អាចផ្អាកការផ្តល់ធនលាភរហូតដល់មានការបង្ហាញខ្លួនរបស់សាមីជន។

## មាត្រា៧២ .- វិភាគទានសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍

សមាជិក **ប.ស.ស**. ជាបុគ្គលនៃវិស័យសាធារណៈ ដែលទទួលរងហានិភ័យការងារបណ្តាលឲ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ក្នុងកម្រិតតិចជាង ២០% (ម្ភៃភាគរយ) មានសិទ្ធិទទួលបានវិភាគទានសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍។

វិភាគទានសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ត្រូវបានបើកផ្តល់ជូនតែម្តងគត់។

បែបបទនិងនីតិវិធីនៃការគណនាវិភាគទានបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ត្រូវកំណត់ដោយអនុក្រឹត្យ។

## មាត្រា៧៣ .- វិភាគទានបូជាសពនិងធនលាភឧត្តរជីវី

ក្នុងករណីដែលសមាជិក **ប.ស.ស**. ជាបុគ្គលនៃវិស័យសាធារណៈ ដែលទទួលរងគ្រោះដោយហានិភ័យការងាររហូតដល់បាត់បង់ជីវិត **ប.ស.ស**. ត្រូវផ្តល់វិភាគទានបូជាសពនិងធនលាភឧត្តរជីវី។

វិភាគទានបូជាសពត្រូវផ្តល់ជូនសិទ្ធិវន្តដែលនៅក្នុងបន្ទុកផ្ទាល់នៃជនរងគ្រោះ ឬអ្នកដែលបានចាត់ចែងបូជាសពជនរងគ្រោះដោយផ្ទាល់។ ចំនួនវិភាគទានបូជាសពត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**.។

ធនលាភឧត្តរជីវីត្រូវផ្តល់ជូនសិទ្ធិវន្តដែលនៅក្នុងបន្ទុកផ្ទាល់នៃជនរងគ្រោះ។ ការគណនា បែបបទនិងនីតិវិធីនៃការផ្តល់ធនលាភឧត្តរជីវីត្រូវកំណត់ដោយអនុក្រឹត្យ។

## មាត្រា៧៤ .- សេវាស្តារនីតិសម្បទា

សមាជិក **ប.ស.ស**. ជាបុគ្គលនៃវិស័យសាធារណៈ ដែលទទួលរងហានិភ័យការងារបណ្តាលឲ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ មានសិទ្ធិទទួលបានសេវាស្តារនីតិសម្បទាដែលរួមមាន សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ ឬសេវាបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ ឬសេវាសង្គម។

សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ ត្រូវបានផ្តល់សម្រាប់គាំទ្រដល់ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រឬសម្រាប់ជួយសម្រួលដល់ជនរងគ្រោះដែលបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍។

សេវាបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ ត្រូវបានផ្តល់ជូនសមាជិក **ប.ស.ស**. ដែលធ្លាក់ខ្លួនពិការដោយហានិភ័យការងារ ដើម្បីមានឱកាសទទួលបានការងារឬមុខរបរថ្មី ស្របតាមកាយសម្បទារបស់ខ្លួន។

ជនពិការដោយហានិភ័យការងារ មានសិទ្ធិទទួលបាននូវការប្រឹក្សា ការតម្រង់ទិស ការអប់រំចិត្តសាស្ត្រ និងសេវាសង្គមនានា ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងនូវផ្នែកចិត្តសាស្ត្រសង្គម ទទួលបានភាពម្ចាស់ការ ស្របតាមស្ថានភាពរស់នៅប្រចាំថ្ងៃ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់សេវាស្តារនីតិសម្បទាត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៣

## ផ្នែកហានិភ័យការងារសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ

### មាត្រា៧៥ .- សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រផ្នែកហានិភ័យការងារ សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវអនុវត្តដូចគ្នានឹងការផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រផ្នែកហានិភ័យការងារ សម្រាប់បុគ្គលនៃវិស័យសាធារណៈ ដែលមានចែងក្នុងមាត្រា៦៩នៃច្បាប់នេះ។

### មាត្រា៧៦ .- ប្រាក់បំណាច់សម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន

ក្នុងរយៈពេលនៃការសម្រាកព្យាបាលមុខរបួសឬជំងឺដែលបណ្តាលមកពីហានិភ័យការងារនៅតាមមូលដ្ឋានសុខាភិបាល និងរយៈពេលសម្រាកក្រោយការចេញពីមូលដ្ឋានសុខាភិបាល តាមវេជ្ជបញ្ជាដែលចេញដោយគ្រូពេទ្យផ្លូវការឬគ្រូពេទ្យទទួលស្គាល់ដោយ **ប.ស.ស.** សាមីជនរងគ្រោះមានសិទ្ធិទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន។

ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវគិតចាប់ពីថ្ងៃទីពីរដែលសាមីជនរងគ្រោះថ្នាក់រហូតមុខរបួសឬជំងឺជាសះស្បើយ ឬទទួលមរណភាព ដោយគិតរួមទាំងរយៈពេលដែលគ្រូពេទ្យព្យាបាលអនុញ្ញាតឲ្យឈប់សម្រាកបន្ទាប់ពីចេញពីមូលដ្ឋានសុខាភិបាលផងដែរ។ ប្រាក់ឈ្នួលរបស់សាមីជនសម្រាប់ថ្ងៃផ្អាកការងារដំបូងជាបន្ទុករបស់និយោជក។

ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវស្មើនឹង៧០%(ចិតសិបភាគរយ)នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់សាមីជន ក្នុងរយៈពេល៦(ប្រាំមួយ)ខែចុងក្រោយ។ ក្នុងករណីដែលរយៈពេលបំពេញការងាររបស់សាមីជនតិចជាង៦(ប្រាំមួយ)ខែ ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ ត្រូវគិតតាមស្ថានភាពជាក់ស្តែង។

### មាត្រា៧៧ .- ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍

ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ត្រូវអនុវត្តដូចមានបញ្ញត្តក្នុងមាត្រា៧១នៃច្បាប់នេះ។

**មាត្រា៧៨ _ វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍**

វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ត្រូវអនុវត្តដូចមានបញ្ញត្តក្នុងមាត្រា៧២នៃច្បាប់នេះ។

**មាត្រា៧៩ _ វិភាជន៍បូជាសពនិងធនលាភឧត្តរជីវី**

វិភាជន៍បូជាសពនិងធនលាភឧត្តរជីវីត្រូវអនុវត្តដូចមានបញ្ញត្តក្នុងមាត្រា៧៣នៃច្បាប់នេះ។

**មាត្រា៨០ _ សេវាស្តារនីតិសម្បទា**

សេវាស្តារនីតិសម្បទាត្រូវអនុវត្តដូចមានបញ្ញត្តក្នុងមាត្រា៧៤នៃច្បាប់នេះ។

## ជំពូកទី៧
## របបសន្តិសុខសង្គមផ្នែកនិកម្មភាពការងារ

**មាត្រា៨១ _ លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្តផ្នែកនិកម្មភាពការងារ**

បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ មានសិទ្ធិទទួលបានតាវកាលិកផ្នែកនិកម្មភាពការងារ។

បទប្បញ្ញត្តិនេះមិនត្រូវបានអនុវត្តចំពោះមន្ត្រីជាប់កិច្ចសន្យាដែលបម្រើការនៅតាមក្រសួង ស្ថាប័ន អង្គភាព នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ទោះបីមានការទទួលស្គាល់ដោយក្រសួងមុខងារសាធារណៈក៏ដោយ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្តផ្នែកនិកម្មភាពការងារត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៨
## សហវិធាន
## ផ្នែកទី១
## វិធានប្រតិបត្តិការងារ

**មាត្រា៨២ _ វិធានប្រតិបត្តិការងារ**

និយោជកត្រូវមានកាតព្វកិច្ចចុះបញ្ជីសហគ្រាសគ្រឹះស្ថាន ចុះបញ្ជីកម្មករនិយោជិតក្នុង **ប.ស.ស**. និងរាយការណ៍ជាទៀងទាត់នូវចំនួនកម្មករនិយោជិត ព្រមទាំងប្រមូលភាគទានរបបសន្តិសុខសង្គម ដោយគិតទាំងផ្នែកនៃភាគទានជាបន្ទុករបស់ខ្លួនផ្ទាល់ បូករួមនឹងផ្នែកនៃភាគទានជាបន្ទុករបស់កម្មករនិយោជិតផង ដើម្បីបង់ចូលក្នុងគណនីនៃ **ប.ស.ស**. តាមកាលកំណត់។

បែបបទនៃការចូលរួមរបស់និយោជក ការចុះបញ្ជីសហគ្រាសគ្រឹះស្ថាន ការចុះបញ្ជីកម្មករនិយោជិត របាយការណ៍ចំនួនកម្មករនិយោជិត ការបង់ភាគទានដែលជាបន្ទុករបស់និយោជក បុគ្គលនៃវិស័យសាធារណៈ និងកម្មករនិយោជិត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម។

និយោជក បុគ្គលនៃវិស័យសាធារណៈ និងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ

ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវមានកាតព្វកិច្ចចូលរួមក្នុងការអនុវត្តរបបសន្តិសុខសង្គម តាមបទប្បញ្ញត្តិនៃច្បាប់នេះ។

បុគ្គលស្វ័យនិយោជន៍អាចចូលរួមដោយស្ម័គ្រចិត្តក្នុងផ្នែកថែទាំសុខភាពនិងផ្នែកប្រាក់សោធន។

### មាត្រា៨៣.- ការផ្តល់ឯកសារព្យាបាលវេជ្ជសាស្ត្ររបស់មូលដ្ឋានសុខាភិបាល

មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស.** ត្រូវផ្តល់ឯកសារព្យាបាលវេជ្ជសាស្ត្រនៃសមាជិក **ប.ស.ស.** ឬឯកសារចាំបាច់ដទៃទៀតដល់ **ប.ស.ស.** នៅពេលមានសំណើជាផ្លូវការឬនៅពេលមានតម្រូវការចាំបាច់ ដើម្បីទុកជាទិន្នន័យសម្រាប់ការស្រាវជ្រាវ វិភាគ និងវាយតម្លៃការអនុវត្តកិច្ចព្រមព្រៀងរបស់មូលដ្ឋានសុខាភិបាល។

ឯកសារទាំងអស់ខាងលើត្រូវទុកជាការសម្ងាត់។ បុគ្គលដែលចូលរួមក្នុងការស្រាវជ្រាវវិភាគនិងវាយតម្លៃការអនុវត្តកិច្ចព្រមព្រៀងនេះត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈនិងសិទ្ធិឯកជនរបស់បុគ្គល។

## ផ្នែកទី២

## សកម្មភាពសុខាភិបាលនិងសង្គមកិច្ច

### មាត្រា៨៤.- សកម្មភាពពាក់ព័ន្ធនឹងផ្នែកសុខភាពនិងសង្គម

ត្រូវបង្កើតឲ្យមានសកម្មភាពពាក់ព័ន្ធនឹងផ្នែកសុខភាពនិងសង្គមដើម្បីបំពេញបន្ថែមលើផ្នែកនីមួយៗនៃរបបសន្តិសុខសង្គមដែលមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ។

សកម្មភាពពាក់ព័ន្ធនឹងផ្នែកសុខភាពនិងសង្គម មានប្រភពមូលនិធិមកពី៖

- ប្រាក់ពិន័យនិយោជកទាក់ទងនឹងការខកខានឬមានកំហុសក្នុងការអនុវត្តតាមច្បាប់និងបទបញ្ជាផ្សេងៗ
- ថវិកាគ្រោងសម្រាប់ធ្វើសកម្មភាពពាក់ព័ន្ធនឹងផ្នែកសុខភាពនិងសង្គមនៃផ្នែកនីមួយៗក្នុងរបបសន្តិសុខសង្គម។

មូលនិធិសកម្មភាពពាក់ព័ន្ធនឹងផ្នែកសុខភាពនិងសង្គមត្រូវប្រើប្រាស់លើសកម្មភាពដូចខាងក្រោម៖

- ការបង្ការសុខភាពទូទៅ
- ការបង្ការហានិភ័យការងារ
- ការសិក្សា ស្រាវជ្រាវ និងធ្វើស្ថិតិសន្តិសុខសង្គម
- ការអប់រំ ផ្សព្វផ្សាយ បណ្តុះបណ្តាល
- ការផ្តល់ជំនួយខាងហិរញ្ញវត្ថុឬការចូលរួមជាមួយស្ថាប័នសាធារណៈឬឯកជនក្នុងផ្នែកពាក់ព័ន្ធសុខភាពនិងសង្គមដែលមានសកម្មភាពជាប្រយោជន៍សម្រាប់សមាជិក **ប.ស.ស.**។

## ផ្នែកទី៣
## សិទ្ធិនិងអត្ថប្រយោជន៍បន្ថែម

### មាត្រា៨៥ .- រយៈពេលដែលចាត់ទុកជារយៈពេលបង់ភាគទានផ្នែកប្រាក់សោធន

រយៈពេលដែលត្រូវចាត់ទុកថាសមាជិក **ប.ស.ស.** បានបង់ភាគទានរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន រួមមាន រយៈពេលបរិចារកិច្ចយោធា រយៈពេលសម្រាកព្យាបាលជំងឺតាមមូលដ្ឋានសុខាភិបាល រយៈពេលសម្រាកមាតុភាព និងរយៈពេលអាក់ខានធ្វើការដោយហានិភ័យការងារ។

### មាត្រា៨៦ .- ការបើកប្រាក់ធនលាភនិងប្រាក់សោធន

ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ចាប់ពី២០%(ម្ភៃភាគរយ) ឡើងនិងប្រាក់សោធនទាំងអស់ត្រូវបើកផ្តល់ប្រចាំខែ។

### មាត្រា៨៧ .- អាជ្ញាយុកាលនៃការទាមទារតាវកាលិក

សិទ្ធិនៃការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព ប្រាក់វិភាជន៍បូជាសព ប្រាក់បំណាច់មាតុភាព និងប្រាក់ព្យាបាលនិងថែទាំវេជ្ជសាស្ត្រក្នុងករណីសង្គ្រោះបន្ទាន់ ត្រូវអស់សុពលភាពត្រឹមរយៈពេល១(មួយ)ឆ្នាំ។

សិទ្ធិនៃការទាមទារប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍និងធនលាភឧត្តរជីវី ត្រូវអស់សុពលភាពត្រឹមរយៈពេល៥(ប្រាំ)ឆ្នាំ។

សិទ្ធិនៃការទាមទារប្រាក់សោធនជរាភាព ទុព្វលភាព និងសោធនឧត្តរជីវីត្រូវអស់សុពលភាពត្រឹមរយៈពេល៥(ប្រាំ)ឆ្នាំ។

### មាត្រា៨៨ .- សិទ្ធិទទួលបានអ្នកថែរក្សា

សមាជិក **ប.ស.ស.** ដែលទទួលបានប្រាក់ធនលាភដោយការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ឬទទួលបានសោធនទុព្វលភាព ដែលតម្រូវឲ្យមានអ្នកថែរក្សា មានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែរក្សាមានចំនួនស្មើនឹង៥០%(ហាសិបភាគរយ)នៃប្រាក់ធនលាភឬប្រាក់សោធនរបស់សាមីជន។

លក្ខខណ្ឌឬស្ថានភាពដែលតម្រូវឲ្យមានអ្នកថែរក្សាត្រូវសម្រេចដោយក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ **ប.ស.ស.**។

### មាត្រា៨៩ .- ភាពមិនអាចរឹបអូសឬផ្ទេរបាននៃតាវកាលិក

តាវកាលិកនៃរបបសន្តិសុខសង្គមទាំងអស់មិនអាចផ្ទេរឬរឹបអូសបានទេ លើកលែងតែមានការយល់ព្រមពីអត្ថគាហកផ្ទាល់។

### មាត្រា៩០ .- ភាពត្រួតគ្នានៃតាវកាលិក

ក្នុងករណីដែលមានតាវកាលិកត្រួតគ្នា ទោះជាតាវកាលិកផ្នែកប្រាក់សោធនជាកាតព្វកិច្ច ឬគនសោធនក្តី អនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ សាមីជនមានសិទ្ធិទទួលបានប្រាក់សោធន ឬប្រាក់ធនលាភណាមួយដែលមានចំនួនទឹកប្រាក់ខ្ពស់ជាង។

## ផ្នែកទី៤
## ការដោះស្រាយវិវាទ

### មាត្រា៩១._ ការដោះស្រាយវិវាទ

វិវាទឬបណ្តឹងដែលទាក់ទងនឹងការអនុវត្តបទប្បញ្ញត្តិនានានៃរបបសន្តិសុខសង្គមរវាងសមាជិក **ប.ស.ស**. និយោជក និង **ប.ស.ស**. ត្រូវដោះស្រាយដោយគណៈកម្មការដោះស្រាយវិវាទនៃ **ប.ស.ស**.។ ក្នុងករណីមិនមានការសះជាវិវាទឬបណ្តឹងនោះអាចត្រូវបានប្តឹងទៅនិយ័តករសន្តិសុខសង្គម ដែលសមាជិក **ប.ស.ស**. កំពុងធ្វើការងារ មុននឹងប្តឹងទៅសាលាដំបូងនៃរាជធានី ខេត្ត ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទនៃ **ប.ស.ស**. ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**. ។

## ផ្នែកទី៥
## យន្តការសម្របសម្រួល

### មាត្រា៩២._ ការបង្កើតយន្តការសម្របសម្រួល

ត្រូវបង្កើតឲ្យមានយន្តការសម្របសម្រួលរវាងផ្នែកនីមួយៗនៃរបបសន្តិសុខសង្គមសម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ បុគ្គលស្វ័យនិយោជន៍ និងបុគ្គលទាំងឡាយណាដែលមិនស្ថិតក្រោមវិសាលភាពនៃច្បាប់នេះ។

**ប.ស.ស**. អាចចុះកិច្ចព្រមព្រៀងជាមួយស្ថាប័នសន្តិសុខសង្គមនៃប្រទេសទទួលពលករដើម្បីបង្កើតយន្តការគាំពារផ្នែកសន្តិសុខសង្គមសម្រាប់កម្មករនិយោជិតទេសន្តរប្រវេសក៍និងតាមបែបបទនិងនីតិវិធីជាធរមាន។

បែបបទនៃការអនុវត្តយន្តការសម្របសម្រួលខាងលើត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៦
## បុព្វសិទ្ធិលើទ្រព្យសម្បត្តិនិងការគ្រប់គ្រងហិរញ្ញវត្ថុ

### មាត្រា៩៣._ ភាពមិនជាប់ភារកិច្ចពន្ធអាករ

ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន **ប.ស.ស**. ត្រូវរួចផុតពីការបង់ពន្ធនិងអាករគ្រប់ប្រភេទ។ ក្នុងករណីប្រតិបត្តិការរបស់បេឡានេះដែលមានចរិតជាពាណិជ្ជកម្មឬមានគោលដៅរកផលចំណេញ ត្រូវជាប់ពន្ធអាករតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

### មាត្រា៩៤._ បុព្វសិទ្ធិនៃការប្រមូលភាគទាន បំណុល និងទ្រព្យសម្បត្តិ

**ប.ស.ស**. មានបុព្វសិទ្ធិនៃអំណាចសាធារណៈក្នុងការប្រមូលភាគទានការឲ្យសងបំណុលនិងការការពារទ្រព្យសម្បត្តិ។

**ប.ស.ស**. មានឯកសិទ្ធិលើទ្រព្យទាំងអស់របស់កូនបំណុលក្នុងលំដាប់បន្ទាប់ពីសិទ្ធិលើបំណុលរបស់កម្មករនិយោជិត។

នីតិវិធីនៃការអនុវត្តបុព្វសិទ្ធិនិងការទារបំណុលរបស់ **ប.ស.ស.** ត្រូវកំណត់ដោយអនុក្រឹត្យ។

### មាត្រា៩៥ _ ការគ្រប់គ្រងនិងថែរក្សាមូលនិធិសន្តិសុខសង្គម

មូលនិធិសន្តិសុខសង្គមត្រូវរក្សាទុកនៅធនាគារនានាដែលស្របច្បាប់ តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** ដោយមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មូលនិធិសន្តិសុខសង្គមត្រូវដាក់ក្នុងគណនីធនាគារផ្សេងៗគ្នាតាមផ្នែកនិងវិស័យនីមួយៗ។

ក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃ **ប.ស.ស.** អាចប្រើប្រាស់មូលនិធិសល់ពីប្រាក់ត្រៀមបម្រុងនៃផ្នែកនីមួយៗសម្រាប់ការវិនិយោគ ដោយអនុលោមតាមគោលការណ៍ណែនាំស្តីពីការវិនិយោគរបស់និយ័តករសន្តិសុខសង្គម ដើម្បីស្នើសុំការសម្រេចចុងក្រោយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៧

## យន្តការត្រួតពិនិត្យការអនុវត្តការងារនៃ ប.ស.ស.

### មាត្រា៩៦ _ ការត្រួតពិនិត្យនិងសវនកម្មបេឡាជាតិសន្តិសុខសង្គម

**ប.ស.ស.** ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យនិងធ្វើសវនកម្មដោយអាជ្ញាធរសវនកម្មជាតិ។ ក្នុងករណីចាំបាច់ និយ័តករសន្តិសុខសង្គមឬក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** អាចស្នើឲ្យមានការធ្វើសវនកម្មពីស្ថាប័នសវនកម្មឯករាជ្យណាមួយ។

## ជំពូកទី៩

## ទោសប្បញ្ញត្តិ

### មាត្រា៩៧ _ ទណ្ឌកម្មរដ្ឋបាលនិងទោសប្បញ្ញត្តិ

ទណ្ឌកម្មក្នុងជំពូកនេះរួមមាន ការពិន័យអន្តរការណ៍ ការពិន័យជាប្រាក់ ឬការផ្តន្ទាទោសដាក់ពន្ធនាគារ។

ការពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់អគ្គនាយក **ប.ស.ស.**។

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឲ្យរលត់បណ្តឹងអាជ្ញា។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ សំណុំរឿងបទល្មើសត្រូវបញ្ជូនទៅតុលាការដើម្បីចាត់ការតាមនីតិវិធី។

បែបបទនិងនីតិវិធីក្នុងការពិន័យអន្តរការណ៍ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម។

### មាត្រា៩៨ _ ការមិនអនុវត្តកាតព្វកិច្ចបង់ភាគទាន

និយោជកនៃសហគ្រាស គ្រឹះស្ថានដែលមិនអនុវត្តកាតព្វកិច្ចនៃការបង់ភាគទានតាមកាលកំណត់ ឬមិនអនុវត្តកាតព្វកិច្ចរាយការណ៍ពីកម្មករនិយោជិតឲ្យបានត្រឹមត្រូវ ដូចមានចែងក្នុងមាត្រា៨២នៃច្បាប់នេះ ត្រូវបង់ប្រាក់ពិន័យអន្តរការណ៍ពី១០(ដប់)ដងទៅ៣០(សាមសិប)ដង

នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ។ ការពិន័យនេះត្រូវអនុវត្តស្មើនឹងចំនួនមនុស្សដែលនិយោជកបានប្រើប្រាស់ក្នុងលក្ខខណ្ឌផ្ទុយពីបទប្បញ្ញត្តិនៃច្បាប់នេះ។

**មាត្រា៩៩ ._ ការដកយកភាគទានមិនអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់**

និយោជកដែលបានដកយកភាគទានផ្នែកហានិភ័យការងារពីប្រាក់ឈ្នួលកម្មករនិយោជិត ឬបានដកយកភាគទានដែលជាបន្ទុករបស់ខ្លួនដោយការកាត់យកពីប្រាក់ឈ្នួលកម្មករនិយោជិត សម្រាប់បង់ភាគទានផ្នែកថែទាំសុខភាព ផ្នែកប្រាក់សោធន ឬផ្នែកនិកម្មភាពការងារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែដល់១(មួយ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី១២០(មួយរយម្ភៃ)ដងទៅ៣៦០(បីរយហុកសិប)ដងនៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ។ ការពិន័យនេះត្រូវអនុវត្តស្មើនឹងចំនួនមនុស្សដែលនិយោជកបានដកយកប្រាក់ភាគទានក្នុងលក្ខខណ្ឌដែលផ្ទុយពីបទប្បញ្ញត្តិនៃច្បាប់នេះ។

**មាត្រា១០០ ._ បទប្រឆាំងនឹងអធិការកិច្ចសន្តិសុខសង្គម**

ត្រូវផ្តន្ទាទោសតាមបញ្ញត្តិនៃមាត្រា៥០៣(បទប្រឆាំងនឹងអ្នករាជការសាធារណៈ)នៃក្រមព្រហ្មទណ្ឌ ចំពោះអំពើប្រឆាំងនឹងការអនុវត្តមុខងាររបស់អធិការកិច្ចសន្តិសុខសង្គមដែលធ្វើសកម្មភាពដើម្បីអនុវត្តច្បាប់។

**មាត្រា១០១ ._ បទប៉ះពាល់ដល់អាថ៌កំបាំងខាងវិជ្ជាជីវៈ**

ត្រូវផ្តន្ទាទោសតាមបញ្ញត្តិនៃមាត្រា៣១៤(បទប៉ះពាល់ដល់អាថ៌កំបាំងខាងវិជ្ជាជីវៈ)នៃក្រមព្រហ្មទណ្ឌ ចំពោះអធិការសន្តិសុខសង្គមឬមន្ត្រីសាធារណៈដែលបានបើកកកាយការសម្ងាត់អំពីរបៀបផលិតឬការសម្ងាត់នៃឯកសារវេជ្ជសាស្ត្រ។

## ជំពូកទី១០
## អន្តរប្បញ្ញត្តិ
## ផ្នែកទី១
## ផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច សម្រាប់បុគ្គលនៃវិស័យសាធារណៈ

**មាត្រា១០២ ._ ការចូលនិវត្តន៍មុនអាយុចូលនិវត្តន៍**

សមាជិក **ប.ស.ស.** ជាបុគ្គលនៃវិស័យសាធារណៈ ដែលបានបម្រើការងារអស់រយៈពេលយ៉ាងតិច៣០(សាមសិប)ឆ្នាំ មានសិទ្ធិស្នើសុំចូលនិវត្តន៍មុនអាយុចូលនិវត្តន៍៦០(ហុកសិប)ឆ្នាំ ដោយទទួលបានប្រាក់សោធនដែលត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

សិទ្ធិស្នើសុំចូលនិវត្តន៍មុនអាយុចូលនិវត្តន៍ មានសុពលភាពអនុវត្តក្នុងរយៈពេល៥(ប្រាំ)ឆ្នាំ បន្ទាប់ពីព្រះរាជក្រឹត្យស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្តផ្នែកប្រាក់សោធនសម្រាប់បុគ្គលនៃវិស័យសាធារណៈ ចូលជាធរមាន។

## ផ្នែកទី២
## សោធនជរាភាពអយ្យកប្បញ្ញត្តិ

**មាត្រា១០៣ ._ សោធនជរាភាពអយ្យកប្បញ្ញត្តិ**

សមាជិក **ប.ស.ស.** ជាបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ដែលមានអាយុលើសពី៣០(សាមសិប)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមដំណើរការដំបូងនៃផ្នែកប្រាក់សោធន មានសិទ្ធិទទួលបានសោធនជរាភាពអយ្យកប្បញ្ញត្តិ។ សោធនជរាភាពអយ្យកប្បញ្ញត្តិត្រូវបានផ្តល់ លុះត្រាតែសាមីជនបានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច២៤(ម្ភៃបួន)ខែ ក្នុងរយៈពេល៣៦(សាមសិបប្រាំមួយ)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមដំណើរការផ្នែកប្រាក់សោធន។

## ផ្នែកទី៣
## ផ្នែកសន្តិសុខសង្គមកំពុងដំណើរការ

**មាត្រា១០៤ ._ ផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងផ្នែកសោធននិវត្តន៍កំពុងដំណើរការ**

រដ្ឋនិងនិយោជកត្រូវបន្តបង់ភាគទានទាំងស្រុងសម្រាប់ផ្នែកថែទាំសុខភាពរហូតដល់មានការកំណត់ជាថ្មី។

រាល់លិខិតបទដ្ឋានគតិយុត្តដែលកំពុងអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ត្រូវទុកឲ្យអនុវត្តបន្តរហូតមានលិខិតបទដ្ឋានគតិយុត្តថ្មីដែលអនុលោមតាមច្បាប់នេះមកជំនួស។

ការផ្តល់សេវាថែទាំសុខភាពតាមរយៈមូលនិធិសមធម៌សុខាភិបាលត្រូវទុកឲ្យអនុវត្តបន្តរហូតមានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។ ប្រភពធនធានសម្រាប់ផ្នែកនេះជាបន្ទុករបស់រដ្ឋ។

រាល់លិខិតបទដ្ឋានគតិយុត្តដែលកំពុងអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធននិវត្តន៍សម្រាប់មន្ត្រីរាជការសាធារណៈ អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ត្រូវទុកឲ្យអនុវត្តបន្តរហូតមានលិខិតបទដ្ឋានគតិយុត្តថ្មីដែលអនុលោមតាមច្បាប់នេះមកជំនួស។

## ផ្នែកទី៤
## ការរួមបញ្ចូលរចនាសម្ព័ន្ធគ្រប់គ្រង

**មាត្រា១០៥ ._ ការរួមបញ្ចូលរចនាសម្ព័ន្ធគ្រប់គ្រងផ្នែកប្រាក់សោធន**

ការរួមបញ្ចូលរចនាសម្ព័ន្ធគ្រប់គ្រងផ្នែកប្រាក់សោធនសម្រាប់បុគ្គលនៃវិស័យសាធារណៈ ដែលបានចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជនមកក្នុង **ប.ស.ស.** ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី១១
## អវសានប្បញ្ញត្តិ

**មាត្រា១០៦ _ ការទុកជានិរាករណ៍**

ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០៧ _ ការប្រកាសជាការប្រញាប់**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃសៅរ៍ ៦កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ២០១៩

នស/រកម.១១១៩.០១៥

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៦០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## និយ័តកម្មប្រព័ន្ធសន្តិសុខសង្គម

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្ដីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្ដីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីគោលការណ៍ វិធាន នីតិវិធី និងយន្តការនៃការធ្វើនិយ័តកម្មដោយនិយ័តករសន្តិសុខសង្គម លើរាល់ប្រតិបត្តិការសន្តិសុខសង្គម ដើម្បីធានាបាននូវស័ក្តិសិទ្ធិភាព ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងភាពរឹងមាំផ្នែកហិរញ្ញវត្ថុ ។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះរាល់ប្រតិបត្តិការសន្តិសុខសង្គម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៣ .-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចខាងក្រោម៖

**១- ប្រធាន អ.ស.ហ** សំដៅដល់ប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

**២- ទំនាក់ទំនងពិសេស** សំដៅដល់ទំនាក់ទំនងរវាងបុគ្គលដែលជា៖

- ក- សហព័ទ្ធ ឬអតីតសហព័ទ្ធ
- ខ- ញាតិលោហិតខ្សែផ្ទាល់ក្នុងថ្នាក់ទី៣
- គ- សាខាញាតិលោហិតក្នុងថ្នាក់ទី៣
- ឃ- សាខាញាតិពន្ធក្នុងថ្នាក់ទី៣
- ង- ញាតិខ្សែផ្ទាល់របស់បុគ្គលដែលចូលក្នុងគ្រួសាររបស់បុគ្គលដើមក្នុងនាមជាកូនសុំ និងសហព័ទ្ធរបស់បុគ្គលនោះ
- ច- បុគ្គលដែលរស់នៅដោយពឹងផ្អែកលើប្រាក់ ឬទ្រព្យសម្បត្តិ ឬបុគ្គលដែលទទួលរបបអាហារកិច្ចពីបុគ្គលដើម និងបុគ្គលដែលរួមរស់ជាមួយបុគ្គលដើម

**៣- និយោជក** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលសាធារណៈ ឬឯកជនដែលដឹកនាំ គ្រប់គ្រង និងប្រើកម្មករនិយោជិតម្នាក់ ឬច្រើននាក់ ទោះជាមិនជាប់លាប់ក្តី ដោយមានផ្តល់ប្រាក់កម្រៃជាទៀងទាត់

**៤- ប្រតិបត្តិការសន្តិសុខសង្គម** សំដៅដល់រាល់សកម្មភាពពាក់ព័ន្ធនឹងប្រព័ន្ធសន្តិសុខសង្គម ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដោយរួមបញ្ចូលទាំងសកម្មភាពរបស់តួអង្គ បុគ្គល និង/ឬ ស្ថាប័នពាក់ព័ន្ធ ក្នុងប្រតិបត្តិការសន្តិសុខសង្គមតាមការកំណត់របស់និយ័តករសន្តិសុខសង្គម

**៥- មូលនិធិសន្តិសុខសង្គម** សំដៅដល់បណ្តុំនៃមូលនិធិដែលប្រមូលបានពីការបង់ភាគទានតាមផ្នែកនីមួយៗ នៃរបបសន្តិសុខសង្គម ដែលមានដូចជាមូលនិធិសន្តិសុខសង្គមផ្នែកប្រាក់សោធន មូលនិធិសន្តិសុខសង្គមផ្នែកថែទាំសុខភាព មូលនិធិសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងមូលនិធិសន្តិសុខសង្គមផ្នែកនិកម្មភាពការងារ

**៦- មូលដ្ឋានសុខាភិបាលឯកជន** សំដៅដល់អង្គភាពព្យាបាលឯកជនដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល ហើយបានចុះកិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាលជាមួយប្រតិបត្តិករសន្តិសុខសង្គម

**៧- សមាជិកប្រតិបត្តិករសន្តិសុខសង្គម** សំដៅដល់រូបវន្តបុគ្គលដែលទទួលបានភាពជាសមាជិកនៃបេឡាជាតិសន្តិសុខសង្គម ដោយការចុះបញ្ជី និងបាន ឬត្រូវបានបង់ភាគទានក្នុងផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម ដែលមានកំណត់ក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គម

**៨- ស្ថាប័នបញ្ជាក់ចំណាយសេវាសុខាភិបាល** សំដៅដល់ស្ថាប័នដែលមានសមត្ថកិច្ចក្នុងការបញ្ជាក់ចំណាយទូទាត់ប្រតិបត្តិការសន្តិសុខសង្គម លើរបបថែទាំសុខភាព និងរបបហានិភ័យការងារ ជូនមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយប្រតិបត្តិករសន្តិសុខសង្គម

**៩- ការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុ** សំដៅដល់ការសិក្សា វិភាគ និងវាយតម្លៃលើចីរភាពហិរញ្ញវត្ថុ នៃផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម។ រយៈពេលនៃការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុ សម្រាប់ផ្នែកប្រាក់សោធនត្រូវធ្វើឡើងយ៉ាងយូរ ៥(ប្រាំ)ឆ្នាំម្តង ផ្នែកហានិភ័យការងារយ៉ាងយូរ ៣(បី)ឆ្នាំម្តង និងផ្នែកថែទាំសុខភាពត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤ .-**

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារដែលសរសេរជាអក្សរកាត់ថា **អ.ស.ហ.** ជាបញ្ញត្តិករប្រព័ន្ធសន្តិសុខសង្គម ដែលមានតួនាទី និងភារកិច្ចដូចមានចែងក្នុងមាត្រា៤ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

និយ័តករសន្តិសុខសង្គម ដែលសរសេរជាអក្សរកាត់ថា **ន.ស.ស.** បំពេញមុខងារជាសេនាធិការឱ្យ **អ.ស.ហ.** លើការងារនិយ័តកម្មប្រព័ន្ធសន្តិសុខសង្គម ដែលមានតួនាទី និងភារកិច្ចដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវា

ហិរញ្ញវត្ថុមិនមែនធនាគារ និងមាត្រា២១ នៃអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

**មាត្រា៥ .-**

**ន.ស.ស.** មានសមត្ថកិច្ចក្នុងការស្នើនូវបទប្បញ្ញត្តិសម្រាប់ការធ្វើនិយ័តកម្មប្រព័ន្ធសន្តិសុខសង្គម ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ពាក់ព័ន្ធជាធរមាន និងអនុក្រឹត្យនេះជូនដល់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីអនុម័ត និងដាក់ឱ្យអនុវត្ត។

**ន.ស.ស.** មានសមត្ថកិច្ចត្រួតពិនិត្យប្រតិបត្តិការសន្តិសុខសង្គម ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ **ន.ស.ស.** ត្រូវចាត់មន្ត្រីដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍ប្រតិបត្តិការ និងឯកសារពាក់ព័ន្ធនានារបស់ប្រតិបត្តិករសន្តិសុខសង្គម មូលដ្ឋានសុខាភិបាលឯកជនដែលបានចុះកិច្ចព្រមព្រៀងជាមួយប្រតិបត្តិករសន្តិសុខសង្គម តួអង្គ បុគ្គល និង/ឬ ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ក្នុងប្រតិបត្តិការសន្តិសុខសង្គម។ ប្រតិបត្តិករសន្តិសុខសង្គម មូលដ្ឋានសុខាភិបាលឯកជនដែលបានចុះកិច្ចព្រមព្រៀងជាមួយប្រតិបត្តិករសន្តិសុខសង្គម តួអង្គ បុគ្គល និង/ឬ ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ក្នុងប្រតិបត្តិការសន្តិសុខសង្គម មានកាតព្វកិច្ចផ្តល់របាយការណ៍និងឯកសារតាមការស្នើសុំរបស់មន្ត្រី **ន.ស.ស.** ដើម្បីបំពេញការងារនិយ័តកម្ម។

**មាត្រា៦ .-**

បេឡាជាតិសន្តិសុខសង្គមដែលសរសេរជាអក្សរកាត់ថា **ប.ស.ស.** គឺជាប្រតិបត្តិករសន្តិសុខសង្គម ដែល **ន.ស.ស.** មានសមត្ថកិច្ចធ្វើនិយ័តកម្មដូចមានចែងក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គម អនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀត។

## ជំពូកទី៣

## ការត្រួតពិនិត្យប្រតិបត្តិការក្នុងប្រព័ន្ធសន្តិសុខសង្គម និងកាតព្វកិច្ចផ្តល់របាយការណ៍

**មាត្រា៧ .-**

ការត្រួតពិនិត្យប្រតិបត្តិការសន្តិសុខសង្គមដោយ **ន.ស.ស.** ត្រូវអនុវត្តផ្អែកលើផែនការត្រួតពិនិត្យ និងសៀវភៅណែនាំ ស្តីពីការត្រួតពិនិត្យដែលទទួលបានការសម្រេចពីប្រធាន **អ.ស.ហ.**។

**មាត្រា៨ .-**

**ប.ស.ស.** ត្រូវរៀបចំ និងដាក់ជូន **ន.ស.ស.** នូវផែនការសកម្មភាពប្រចាំឆ្នាំ សម្រាប់ឆ្នាំបន្ទាប់ យ៉ាងយូរត្រឹមថ្ងៃទី១៥ ខែឧសភា។

**មាត្រា៩ .-**

**ប.ស.ស.** ត្រូវរៀបចំ និងដាក់ជូន **ន.ស.ស.** នូវយន្តការគ្រប់គ្រងហានិភ័យ និងដោះស្រាយបញ្ហាគ្រាមានអាសន្ន ដើម្បីបង្ការ បញ្ចៀស ឬកាត់បន្ថយអានុភាពហានិភ័យ ដែលអាចកើតមានឡើងពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ខ្លួន និងត្រូវដាក់ជូន **ន.ស.ស.** យ៉ាងយូរ

**មាត្រា១៦ ..**

**ម.ស.ស.** ត្រូវផ្តល់របាយការណ៍ និងព័ត៌មានដូចមានចែងក្នុងអនុក្រឹត្យនេះជូន **គ.ស.ស.** ជាលាយលក្ខណ៍អក្សរ ឬតាមមធ្យោបាយផ្សេងទៀត ដែលកំណត់ដោយ **គ.ស.ស.**។

**មាត្រា១៧ ..**

**ម.ស.ស.** ត្រូវបង់កម្រៃសេវាត្រួតពិនិត្យជូន **គ.ស.ស.**។ អត្រា នីតិវិធីនៃការបង់ និងការចាត់ចែងកម្រៃសេវាត្រួតពិនិត្យ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **អ.ស.ហ.**។

## ជំពូកទី៤

## និយ័តកម្មលើការប្រើប្រាស់សេវារបស់មូលដ្ឋានសុខាភិបាល

**មាត្រា១៨ ..**

ការទូទាត់ចំណាយសេវាសុខាភិបាល ជូនមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ម.ស.ស.** ត្រូវឆ្លងកាត់ការពិនិត្យ និងបញ្ជាក់សំណើទូទាត់ជាមុនដោយស្ថាប័នបញ្ជាក់ចំណាយសេវាសុខាភិបាល ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែករបស់រាជរដ្ឋាភិបាល។

**មាត្រា១៩ ..**

ស្ថាប័នបញ្ជាក់ចំណាយសេវាសុខាភិបាល មានកាតព្វកិច្ចផ្តល់របាយការណ៍ស្តីពីការពិនិត្យ និងបញ្ជាក់សំណើទូទាត់ជូន **គ.ស.ស.**។ ប្រភេទ និងទម្រង់ នៃរបាយការណ៍ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ **គ.ស.ស.**។

**មាត្រា២០ ..**

**ម.ស.ស.** ត្រូវស្នើសុំការឯកភាពជាមុនពី **គ.ស.ស.** មុននឹងចុះកិច្ចព្រមព្រៀងប្រើប្រាស់សេវាសុខាភិបាល កែសម្រួល ឬបញ្ចប់កិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលឯកជន និងត្រូវផ្តល់ជូន **គ.ស.ស.** នូវកិច្ចព្រមព្រៀងដែលបានចុះរួច និងឯកសារពាក់ព័ន្ធផ្សេងទៀត។

**ម.ស.ស.** ត្រូវធានាថារាល់ការចុះកិច្ចព្រមព្រៀងប្រើប្រាស់ និងផ្តល់សេវាសុខាភិបាលជាមួយមូលដ្ឋានសុខាភិបាលឯកជន អនុវត្តទៅប្រកបដោយតម្លាភាព និងជៀសវាងទំនាស់ផលប្រយោជន៍។

លក្ខខណ្ឌតម្រូវសម្រាប់ **ម.ស.ស.** ក្នុងការចុះកិច្ចព្រមព្រៀងប្រើប្រាស់ និងផ្តល់សេវាសុខាភិបាល ជាមួយមូលដ្ឋានសុខាភិបាលឯកជន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **អ.ស.ហ.**។

**មាត្រា២១ ..**

ថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់ជាន់ថ្នាក់ របស់ **ម.ស.ស.** មិនត្រូវមានទំនាក់ទំនងពិសេសជាមួយមូលដ្ឋានសុខាភិបាលឯកជន ដែលត្រូវចុះកិច្ចព្រមព្រៀងប្រើប្រាស់សេវាសុខាភិបាលជាមួយ **ម.ស.ស.** ជាដាច់ខាត។



ﾉ

## ជំពូកទី៥
## និយ័តកម្មលើការវិនិយោគមូលនិធិសន្តិសុខសង្គម

**មាត្រា២២ .-**

ការវិនិយោគមូលនិធិសន្តិសុខសង្គម ត្រូវគោរពតាមគោលការណ៍ប្រុងប្រយ័ត្ន រួមមាន ការរក្សាសុវត្ថិភាពមូលនិធិវិនិយោគ ភាពរឹងមាំផ្នែកហិរញ្ញវត្ថុ និងផលចំណូលនៃការវិនិយោគមូលនិធិ។

ការវិនិយោគមូលនិធិសន្តិសុខសង្គម ត្រូវអនុលោមតាមគោលការណ៍ណែនាំ ស្តីពីការវិនិយោគមូលនិធិសន្តិសុខសង្គម។ យន្តការគ្រប់គ្រងមូលនិធិសន្តិសុខសង្គម និងគោលការណ៍ណែនាំ ស្តីពីការវិនិយោគមូលនិធិសន្តិសុខសង្គម ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

## ជំពូកទី៦
## ការដោះស្រាយវិវាទ

**មាត្រា២៣ .-**

វិវាទ ឬបណ្តឹងពាក់ព័ន្ធនឹងការអនុវត្តបទប្បញ្ញត្តិនានានៃរបបសន្តិសុខសង្គម រវាងសមាជិក **ប.ស.ស.** និយោជក និង **ប.ស.ស.** ត្រូវដោះស្រាយដោយគណៈកម្មការដោះស្រាយវិវាទនៃ **ប.ស.ស.**។ ក្នុងករណីមិនសះជាវិវាទ ឬបណ្តឹងនោះ អាចត្រូវបានប្តឹងទៅ **ន.ស.ស.** មុននឹងប្តឹងទៅតុលាការមានសមត្ថកិច្ច។

នីតិវិធី និងយន្តការនៃការដោះស្រាយវិវាទ ឬបណ្តឹងដោយ **ន.ស.ស.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **អ.ស.ហ.**។

## ជំពូកទី៧
## ទណ្ឌកម្ម

**មាត្រា២៤ .-**

បុគ្គល និងតួអង្គពាក់ព័ន្ធដែលប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មខាងវិន័យ និងទោស ដូចមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា២៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១១ កើត ខែ ស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ សីហា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** ៤៤៨ **ក.ប**/ប្រ.ក.ប.ន.ស

# ប្រកាស

## ស្តីពី

## បញ្ជីការសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១ .-**

ប្រកាសនេះមានគោលបំណងចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងបេឡាជាតិរបបសន្តិសុខសង្គម សម្រាប់របបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព។

**ប្រការ ២ .-**

ប្រកាសនេះមានគោលដៅកំណត់បែបបទ និងនីតិវិធី នៃការចុះបញ្ជិកាសហគ្រាស គ្រឹះ ស្ថាន និងកម្មករនិយោជិត ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងបេឡាជាតិរបបសន្តិសុខសង្គម សម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ។

**ប្រការ ៣ .-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ។

**ប្រការ ៤ .-**

វាក្យស័ព្ទសំខាន់ៗដែលប្រើនៅក្នុងប្រកាសនេះ មាននិយមន័យដូចខាងក្រោម ៖

- ***សហគ្រាស*** សំដៅដល់សហគ្រាស ឬគ្រឹះស្ថាន ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សេវាកម្ម កសិកម្ម សិប្បកម្ម ដឹកជញ្ជូនតាមផ្លូវគោក ឬតាមផ្លូវទឹក ទោះជាប្រយោជន៍សាធារណៈ ពាក់កណ្តាលសាធារណៈ ឬឯកជន ក្រៅសាសនា ឬក្នុងសាសនាក៏ដោយ ទោះមានលក្ខណៈជាបង្រៀនវិជ្ជាជីវៈឬជាការកុសលក៏ដោយ ព្រមទាំងវិជ្ជាជីវៈ សេរីនៃសមាគម ឬក្រុមប្រភេទណាក៏ដោយ ។ សហគ្រាសអាចមានគ្រឹះស្ថានច្រើន ហើយគ្រឹះស្ថាននីមួយៗ

មានប្រើមនុស្សឱ្យធ្វើការងារក្នុងទីកន្លែងណាមួយជាប្រាកដ ដូចជាក្នុងរោងចក្រ រោងជាង ការដ្ឋាន។ល។ ក្រោមការគ្រប់គ្រង និងដឹកនាំរបស់និយោជក ។ គ្រឹះស្ថានស្ថិតនៅក្រោមនិវាទសហគ្រាសមួយជានិច្ច ។ គ្រឹះស្ថានអាចមានប្រើមនុស្សតែម្នាក់ក៏បានដែរ ។ ករណីគ្រឹះស្ថាននេះមានតែមួយឯកឯង និងមិននៅក្រោមសហគ្រាសណាទេ គ្រឹះស្ថាននោះត្រូវចាត់ទុកជាសហគ្រាស ។

- ***និយោជក*** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ជាសាធារណៈ ឬឯកជន ដែលប្រើកម្មករនិយោជិតម្នាក់ ឬច្រើននាក់ ទោះជាកម្មករនិយោជិតជាប់លាប់ ឬម្តងម្កាល ។
- ***កម្មករនិយោជិត*** សំដៅដល់ជនគ្រប់ភេទ និងគ្រប់សញ្ជាតិ ដែលបានចុះកិច្ចសន្យា យកកំរៃជាសាធារណៈ ឬឯកជន ។ លក្ខណៈសម្បត្តិនៃកម្មករនិយោជិត មិនត្រូវគិតពីលក្ខន្តិកៈគតិយុត្តនៃនិយោជក ឬលក្ខន្តិកៈគតិយុត្តនៃកម្មករនិយោជិត ព្រមទាំងមិនត្រូវគិតពីប្រាក់ឈ្នួលតិច ឬច្រើន ។

## ជំពូកទី ២
## ការចុះបញ្ជី
### ផ្នែកទី១
### ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន

**ប្រការ ៥ .-**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលនៅក្នុងដែនអនុវត្ត នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចមកចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានរបស់ខ្លួន នៅបេឡាជាតិរបបសន្តិសុខសង្គម ។

រយៈពេលកំណត់នៃការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន មានដូចតទៅ ៖

- ចំពោះសហគ្រាស គ្រឹះស្ថាន ដែលកំពុងដំណើរការ និងមិនទាន់បានចុះបញ្ជិកានៅបេឡាជាតិរបបសន្តិសុខសង្គម ត្រូវមានកាតព្វកិច្ចមកចុះបញ្ជិកានៅបេឡាជាតិរបបសន្តិសុខសង្គម រយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីប្រកាសនេះចូលជាធរមាន ។
- ចំពោះសហគ្រាស គ្រឹះស្ថាន ដែលបើកដំណើរការថ្មី ក្រោយពីប្រកាសនេះចូលជាធរមាន ត្រូវមានកាតព្វកិច្ចមកចុះបញ្ជិកានៅបេឡាជាតិរបបសន្តិសុខសង្គម រយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមបើកសហគ្រាស គ្រឹះស្ថាន ។
- ចំពោះសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកានៅបេឡាជាតិរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព រួចហើយ មិនមានកាតព្វកិច្ចក្នុងការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ឡើងវិញទេ ។

**ប្រការ ៦ .-**

ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ត្រូវធ្វើតាមទម្រង់ "បញ្ជិកាសហគ្រាស គ្រឹះស្ថាន" ឬហៅថាទម្រង់ "១.០១" ដែលមានចែងក្នុងឧបសម្ព័ន្ធ ១ នៃប្រកាសនេះ ។ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវភ្ជាប់មកជាមួយទម្រង់ "១.០១" នូវវិញ្ញាបនបត្របញ្ជិកាពាណិជ្ជកម្ម ដែលចេញដោយក្រសួងពាណិជ្ជកម្ម ឬលិខិតូបករណ៍គតិយុត្តសមមូលដទៃទៀត ។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះកម្មករនិយោជិត ក្នុងពេលដំណាលគ្នានិងទម្រង់បញ្ជិកាសហគ្រាស គ្រឹះស្ថាន ។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវមានកាតព្វកិច្ចជូនដំណឹងមក ប.ស.ស ក្នុងរយៈពេលយ៉ាងយូរ ៣០ថ្ងៃ បន្ទាប់ពីមានការព្យួរ បិទ ឬ ផ្អាកសកម្មភាពអាជីវកម្ម ការប្តូរនិយោជក ឬម្ចាស់សហគ្រាស ឬអ្នកតំណាង អាសយដ្ឋាន ឬនាមករណ៍សហគ្រាស ។

## ផ្នែកទី ២
## ការចុះបញ្ជីកម្មករនិយោជិត

**ប្រការ ៧ .-**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវមានកាតព្វកិច្ចចុះបញ្ជីកម្មករនិយោជិត មកក្នុងបេឡាជាតិរបបសន្តិសុខសង្គម យ៉ាងយូររយៈពេល ៣ (បី) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទអនុញ្ញាតឱ្យចូលធ្វើការ លើកលែងតែកម្មករនិយោជិតដែលមានប័ណ្ណសមាជិក ប.ស.ស រួចហើយ ។

**ប្រការ ៨ .-**

នីតិវិធី និងបែបបទនៃការចុះបញ្ជីកម្មករនិយោជិត មកក្នុងបេឡាជាតិរបបសន្តិសុខសង្គម ត្រូវធ្វើតាមទម្រង់សលាកប័ត្រព័ត៌មានកម្មករនិយោជិត ឬហៅថាទម្រង់ "១.០២" ដែលមានចែងក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ ។

ដើម្បីចុះបញ្ជីក្នុង ប.ស.ស កម្មករនិយោជិតសញ្ជាតិខ្មែរត្រូវមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដោយឡែកចំពោះកម្មករនិយោជិតបរទេសត្រូវមានលិខិតឆ្លងដែន ។

## ផ្នែកទី ៣
## អត្តសញ្ញាណកម្មសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត

**ប្រការ ៩ .-**

បេឡាជាតិរបបសន្តិសុខសង្គម ត្រូវផ្តល់លេខអត្តសញ្ញាណសម្រាប់សហគ្រាស គ្រឹះស្ថាន នីមួយៗ បន្ទាប់ពីទទួលបានទម្រង់ "បញ្ជិកាសហគ្រាស គ្រឹះស្ថាន" ។ សហគ្រាស គ្រឹះស្ថាន

មួយត្រូវទទួលបានលេខអត្តសញ្ញាណតែមួយគត់ ដែលឱ្យឈ្មោះថា "លេខអត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន" ។

បេឡាជាតិរបបសន្តិសុខសង្គមត្រូវផ្តល់ "វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន" ជូនទៅសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិការួច ។ វិញ្ញាបនបត្រនេះចាំបាច់ត្រូវមានចុះលេខ "អត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន" និង កាលបរិច្ឆេទចុះបញ្ជិកា ។ និយោជកត្រូវដាក់តាំងវិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន នៅនឹងការិយាល័យបើកប្រាក់ឈ្នួលរបស់សហគ្រាស គ្រឹះស្ថាន ។

**ប្រការ ១០ ..**

បន្ទាប់ពីបានទទួលទម្រង់សលាកប័ត្រព័ត៌មានកម្មករនិយោជិត និងការកំណត់អត្តសញ្ញាណកម្មករនិយោជិតរួចហើយបេឡាជាតិរបបសន្តិសុខសង្គមត្រូវផ្តល់លេខអត្តសញ្ញាណកម្មករនិយោជិត និងចេញប័ណ្ណសមាជិក ប.ស.ស ជូនកម្មករនិយោជិតម្នាក់ៗដោយឥតគិតថ្លៃ ។ ប័ណ្ណសមាជិក ប.ស.ស ត្រូវប្រគល់ជូនកម្មករនិយោជិតតាមរយៈនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ។

ក្នុងករណីដែល "ប័ណ្ណសមាជិក ប.ស.ស" ខូច ឬបាត់បង់ សាមីជនដែលជាម្ចាស់ប័ណ្ណត្រូវជូនដំណឹងជាបន្ទាន់ទៅនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន និងត្រូវស្នើសុំទុតិយតា ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងខាងលើ ។ ការផ្តល់ប័ណ្ណទុតិយតាតម្រូវឱ្យសាមីជនបង់ប្រាក់ចំនួន **២,០០០ (ពីរពាន់) រៀល** ជូនទៅបេឡាជាតិរបបសន្តិសុខសង្គម ។

## ផ្នែកទី ៤
## របាយការណ៍កម្មករនិយោជិត

**ប្រការ ១១ ..**

រៀងរាល់ខែ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវផ្តល់របាយការណ៍អំពីចំនួនកម្មករនិយោជិតទៅបេឡាជាតិរបបសន្តិសុខសង្គម យ៉ាងយូរបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ ។

របាយការណ៍អំពីចំនួនកម្មករនិយោជិត ត្រូវបញ្ជាក់អំពីចំនួនកម្មករនិយោជិតទាំងអស់ដែលមាននៅក្នុងខែត្រូវរាយការណ៍ ។ របាយការណ៍អំពីចំនួនកម្មករនិយោជិត ដែលត្រូវផ្តល់ជូនបេឡាជាតិរបបសន្តិសុខសង្គម អាចធ្វើតាម "ទម្រង់ក្រដាស" ឬ "ទម្រង់អេឡិចត្រូនិច" ដោយមានភ្ជាប់លិខិតបញ្ជូន ចុះហត្ថលេខាដោយនិយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ។

## ជំពូកទី ៣
## ទោសប្បញ្ញត្តិ

**ប្រការ ១២ .-**

ជនដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលទោសដូចមានចែងក្នុងជំពូកទី៥ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**ប្រការ ១៣ .-**

ប្រកាសលេខ ០២១/០៨ ក.ប-ប្រ.ក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ក្នុងបេឡាជាតិរបបសន្តិសុខសង្គម ប្រកាសលេខ ២៨៥ ក.ប-ប្រ.ក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ និងប្រការ៥ នៃប្រកាសលេខ ០២១/០៨ ក.ប-ប្រ.ក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១៤ .-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួងពាក់ព័ន្ធ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
  "ដើម្បីជូនជ្រាប"
- គ្រប់អង្គភាពក្រោមឱវាទក្រសួង "ដើម្បីអនុវត្ត"
- សមាគមនិយោជក និងសមាគមពាណិជ្ជកម្មនៅកម្ពុជា
- គ្រប់សហព័ន្ធសហជីព
  "ដើម្បីផ្សព្វផ្សាយ"
- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ